# អូម៉ូចា

## ការបំផ្លាស់បំប្រែសហគមន៍

## មគ្គុទេសក៍អ្នកសម្របសម្រួល

រៀបចំប្រែសំរួលដោយៈ បណ្ដាញមីកាកម្ពុជា

Réseau Michée
Rede Miquéias
Red Miqueas
Micah Network

# សេចក្តីផ្តើម

ស្វាគមន៍មកកាន់កម្មវិធីអូម៉ូចា។ ពាក្យអូម៉ូចាមានន័យថា"សាមគ្គី "ជាភាសាស្វាហ៊ីលីរបស់អាហ្វ្រិកខាងកើត។ អូម៉ូចា ជួយអ្នកដឹកនាំក្រុមជំនុំ និងសមាជិកធ្វើការជាមួយសហគមន៍ ក្នុងការនាំការផ្លាស់ប្តូរវិជ្ជមាន សំរាប់សហគមន៍ទាំងមូល។ វាគឺជាដំណើរការដែលនាំក្តីសង្ឃឹម ការអោយតំលៃខ្លួនឯង និងការផ្លាស់ប្តូរទៅអោយក្រុមជំនុំ និងសហគមន៍ដែលបានមកពីបទពិសោធន៍ជាង២០ឆ្នាំក្នុងការធ្វើការជុំវិញអាហ្វ្រិកនិងអាស៊ី។

**អូម៉ូចា**គឺជាការនាំថាមពលនិងការរំភើបទៅអោយក្រុមជំនុំនិងសហគមន៍ដែលពាក់ពន្ធ័ទៅនឹងការផ្លាស់ប្តូរនូវភាពវិជ្ជមានដែលគេធ្វើដោយខ្លួនពួកគេផ្ទាល់។ វាស្វែងរកដើម្បីពង្រីកធនធានដែលពួកគេមានស្រាប់និងលើកទឹកចិត្តអោយរុករកជំនាញថ្មីដែលមាននៅក្នុងសហគមន៍របស់ពួកគេ។ ជារឿយៗ គំរោងអភិវឌ្ឍន៍តែងតែពឹងផ្អែកលើជំនួយពីខាងក្រៅ ហើយទុកបុគ្គល និង សហគមន៍ថាគ្មានធនធាន។ អូម៉ូចាធ្វើផ្ទុយពីនេះគឺការជំរុញ និង ហ្វឹកហ្វឺនប្រជាជនក្នុងមូលដ្ឋាននូវនិមិត្តដើម្បីកំនត់អនាគតរបស់ពួកគេដោយធនធានរបស់ពួកគេផ្ទាល់។

សៀវភៅណែនាំអ្នកសម្របសម្រួលអូម៉ូចានេះផ្តល់ចំនេះដឹងដើម្បីជួយជំរុញក្រុមជំនុំនិងសហគមន៍ចាប់ផ្តើមធ្វើការផ្លាស់ប្តូរក្នុងសហគមន៍ ។វាគឺមានប្រយោជន៍ប្រសិនបើអ្នកបានចូលរួមការបណ្តុះបណ្តាលមុនប្រើប្រាស់សៀវភៅនេះ។ សៀវភៅណែនាំអ្នកសម្របសម្រួលអូម៉ូចាគ្របដណ្តប់ប្រធានបទដូចខាងក្រោមនេះ :

- ទិដ្ឋភាពទូទៅនៃអូម៉ូចា-គោលបំនង ផលប្រយោជន៍ តួនាទីរបស់អ្នកសម្របសម្រួល។
- ការបង្កើតនិមិត្តដល់ក្រុមជំនុំការសិក្សាព្រះគម្ពីរនិងសកម្មភាពជួយក្រុមជំនុំទទួលនិមិត្តសំរាប់ចូលរួមក្នុងសហគមន៍។
- ការបង្កើតនិមិត្តដល់សហគមន៍-សកម្មភាពនិងគំនិតជួយសហគមន៍ប៉ាន់ស្មានតំរូវការនិងធនធានរបស់ពួកគេអមជាមួយការសិក្សាព្រះគម្ពីរ។
- ការបង្កើតសុបិន្តនិងផែនការសកម្មភាព: សកម្មភាពនិងគំនិតជួយបង្កើតនិមិត្តសំរាប់អនាគត និងផែនការសំរាប់វាដែលអមជាមួយការសិក្សាព្រះគម្ពីរ។
- ការធ្វើសកម្មភាព-សកម្មភាពនិងដំបូន្មានដើម្បីជួយសហគមន៍ធានាថាផែនការត្រូវបានអនុវត្តន៍និងធ្វើអោយការផ្លាស់ប្តូរវិជ្ជមានកើតមានឡើង។
- ការវាយតំលៃ-ការរំលឹកឡើងវិញពីរបៀបដែលក្រុមជំនុំនិងសហគមន៍ធ្វើការជាមួយគ្នាក្នុងការរៀបចំផែនការនិងដំណើការគំរោងដើម្បីកែលំអរជីវិតរបស់បុគ្គលនិងសហគមន៍វាមិនចាំបាច់ធ្វើតាមលំដាប់ដំណាក់កាលទាំងនេះនោះទេ ប៉ុន្តែ អ្វីដែលសំខាន់គឺជ្រើសរើសមេរៀន ដែលសមស្របទៅតាមស្ថានភាពរបស់អ្នក។ សៀវភៅដែលអមជាមួយសៀវភៅនេះ គឺជាសៀវ-ភៅណែនាំរបស់អ្នកសម្របសម្រួលដែលផ្តល់អោយអង្គការមួយ ឬ និកាយ មួយត្រូវការយល់ដឹង ដើម្បីចាប់ផ្តើម និងគ្រប់គ្រងកម្មវិធីអូម៉ូចានៅក្នុងសហគមន៍មូលដ្ឋាន។

យើងខ្ញុំសង្ឃឹមថា អ្នករីករាយក្នុងដំណើរនេះ។



ហ្វ្រែងស៊ីស ទូឡូ បៀល និង ជែកខី Francis, Tulo, Bill and Jackie

# និជ្ជភាពខ្លូនៅនិងគោលបំណង

# នៃអ្វូប៉ូចា “សាមគ្គី”



## ១.តើអ្វីទៅជាគោលបំនងនៃអូម៉ូចា?

អូម៉ូចាគឺនិយាយអំពីការផ្តល់ដល់ក្រុមជំនុំក្នុងស្រុកនូវនិមិត្តសំរាប់សហគមន៏របស់ពួកគេ ។តាមរយៈការសិក្សាព្រះគម្ពីរនិងអន្តរសកម្មភាព។

អូម៉ូចាក៏និយាយអំពីការផ្តល់អំណាចអោយក្រុមជំនុំចេញទៅជួយសហគមន៏និងជួយប្រជាជនក្នុងការកំនត់និងដោះស្រាយនូវតំរូវការរបស់ពួកគេជាមួយនឹងធនធានផ្ទាល់ក្នុងសហគមន៏របស់ពួកគេ ។



អេសាយ៥៨:៩-១២

*" គ្រានោះ បើឯងអំពាវនាវ ព្រះយេហូវ៉ាទ្រង់នឹងឆ្លើយតប បើឯងស្រែករក នោះទ្រង់នឹងមានបន្ទូលថា អញនៅឯណេះហើយ គឺបើឯងចោលនឹមរបស់ឯងចេញ លែងដន្ទូកំហែងព្រមទាំងលែងពោលដោយកាចអាក្រក់ផង ហើយបើឯងផ្តល់សេចក្តីសប្បុរសដល់មនុស្សស្រេកឃ្លាន ទាំងចំអែតចិត្តនៃអ្នកដែលមានទុក្ខវេទនា នោះពន្លឺរបស់ឯងនឹងភ្លឺឡើងក្នុងទីងងឹត ហើយសេចក្តីងងឹតរបស់ឯងនឹងបានភ្លឺដូចជាវេលាថ្ងៃត្រង់ ។ព្រះយេហូវ៉ាទ្រង់នឹងនាំផ្លូវឯងជានិច្ច ហើយនឹងចំអែតព្រលឹងឯងនៅក្នុងទីហួតហែង ទ្រង់នឹងធ្វើអោយឆ្អឹងឯងបានមាំមួន ឯងនឹងបានដូចជាសួនច្បារដែលគេស្រោចទឹក ហើយដូចជាក្បាលទឹកដែលមិនខានហូរឡើយ ហើយពួកអ្នកដែលនឹងកើតពីឯងមក គេនឹងសង់ទីចាស់ដែលខូចបង់ឡើងជាថ្មី ឯងនឹងសង់ឡើងលើជើងជញ្ជាំង ដែលមាននៅតាំងពីច្រើនដំណតមកហើយ ក៏នឹងមានឈ្មោះថា ជាអ្នកជួសជុលទីបាក់បែក គឺជាអ្នកដែលរៀបចំផ្លូវទៅឯទីលំនៅឡើងវិញ ។ "*

## ២.តើអ្វីជាផលប្រយោជន៏នៃអូម៉ូចា?

អូម៉ូចាបង្កើនកំលាំងនិងក្តីសង្ឃឹមដល់ក្រុមជំនុំដែលចង់ធ្វើអោយមានការផ្លាស់ប្តូរក្នុងសហគមន៏របស់ខ្លួន ។វាមានផលប្រយោជន៏មួយចំនួនចំពោះក្រុមជំនុំនិងសហគមន៏ក្នុងការអនុវត្តន៏អូមីចា ។

**ផលប្រយោជន៏ចំពោះក្រុមជំនុំ**

- បង្កើននូវឥទ្ធិពលវិជ្ជមានក្នុងសហគមន៏
- ជួយក្រុមជំនុំអោយចេះឆ្លុះបញ្ចាំងទៅលើព្រះគម្ពីរនិងតួនាទីរបស់ខ្លួនក្នុងការបំពេញតំរូវការរបស់អ្នកដទៃ

- ជួយកំនត់ធនធានទាំងប៉ុន្មានដែលមាននៅក្នុងក្រុមជំនុំ
- កសាងទំនាក់ទំនង
- ជួយអោយមានទំនុកចិត្តក្នុងការធ្វើការងារជាក្រុម
- ជួយក្រុមជំនុំអោយក្លាយទៅជាសហគមន៍ដែលរីកចំរើន ចែករំលែកបទពិសោធន៏ផ្សេងៗនិងការសំរេចបាននានា



**ផលប្រយោជន៏សហគមន៏**

- ពឹងផ្អែកលើខ្លួនឯង
- ចេះគិតពីគោលបំណង
- អោយតំលៃខ្លួនឯង
- មាននិរន្តរភាពក្នុងការផ្លាស់ប្តូរ
- មានក្តីសង្ឃឹមនិងមានសុខុមាលភាព
- មានលទ្ធភាពក្នុងការកែតំរូវដើម្បីផ្លាស់ប្តូរទៅតាមវប្បធម៌និងបរិស្ថាន
- ធ្វើអោយប្រសើរឡើងនូវទំនាក់ទំនងក្នុងសហគមន៍



**៣.តើអ្វីខ្លះជាដំណាក់កាលគន្លឹះរបស់អូម៉ូចា?**

**ដំណាក់កាលទី១.ការបង្កើតនិមិត្តនិងការហ្វឹកហ្វឺនក្រុមជំនុំ**



អូម៉ូចាគឺជាការធ្វើការងាររវាងអ្នកដឹកនាំក្រុមជំនុំនិងសមាជិកនានាដើម្បីជួយពួកគេអោយយល់ដឹងអំពីទំនួលខុសត្រូវចំពោះព្រះគម្ពីរក្នុងការបំរើសហគមន៏ក្នុងស្រុក។

ដំណើការនេះនឹងជួយបង្កើនការទុកចិត្តនៃសមាជិកក្រុមជំនុំ និងជួយពួកគេអោយកំនត់បាននូវកំលាំងនិងធនធានរបស់ខ្លួន។ ដូច្នេះ គេអាចជឿជាក់ថា ការផ្លាស់ប្តូរអាចប្រព្រឹត្តទៅបាន។

## ដំណាក់កាលទី២.ការបង្កើតនិមិត្តដល់សហគមន៍

ក្រុមជំនុំធ្វើការដឹកនាំសហគមន៍ជាមួយគ្នាដើម្បីពិភាក្សាអំពីតំរូវការនិងធនធានរបស់សហគមន៍ដោយធ្វើការវិភាគពតិមាន និងធ្វើការសំរេចចិត្តអំពីអ្វីដែលចាំបាច់ត្រូវផ្លាស់ប្តូរ ។



## ដំណាក់កាលទី៣.ការបង្កើតនិមិត្តនិងការធ្វើផែនការសកម្មភាព



នៅពេលមនុស្សគ្រប់គ្នាបានព្រមព្រៀងអំពីអ្វីដែលត្រូវផ្លាស់ប្តូរហើយក្រុមជំនុំនិងសហគមន៍និងរួបរួមគ្នាបង្កើតជានិមិត្តសំរាប់ពេលអនាគតនិងកសាងផែនការស្តីអំពីរបៀបដែលនាំអោយមានការផ្លាស់ប្តូរនេះដោយប្រើប្រាស់ធនធានរបស់ខ្លួនផ្ទាល់ ។ការងារនេះរួមបញ្ចូលទាំងការគិតអំពីការបង្កើតគំរោងមួយនៅក្នុងសហគមន៍ ។ គំរោងមួយត្រូវបានកំនត់ដោយគំនិតផ្តួចផ្តើមមួយដែលបានកសាងផែនការព្រមទាំងដំណើរការចេញពីសហគមន៍ផ្ទាល់ដោយប្រើប្រាស់ធនធានរបស់ខ្លួន ។

## ដំណាក់កាលទី៤.ការអនុវត្តន៏សកម្មភាព

នៅពេលដែលសហគមន៏ចាប់ផ្តើមធ្វើសកម្មភាពគឺតំរូវអោយមានការផ្តល់ដំបូន្មានពីបណ្តាអ្នកជំនាញផ្សេងៗដើម្បីធានាថា ផែនការទាំងនេះត្រូវបានអនុវត្តន៏និងធ្វើអោយមានការផ្លាស់ប្តូរជាវិជ្ជមាន ។

## ដំណាក់កាលទី៥.ការវាយតំលៃ

ដំណាក់កាលចុងក្រោយជាការរំលឹកឡើងវិញអំពីរបៀបដែលក្រុមជំនុំនិងសហគមន៍ធ្វើការជាមួយគ្នាដើម្បីកសាងផែនការព្រមទាំងដំណើរការគំរោងក្នុងការផ្លាស់ប្តូរជីវិតបុគ្គលនិងសហគមន៍ ។ការងារនេះគួររួមបញ្ចូលគំនិតនិងការរៀនសូត្រអំពីដំណើរការក្នុងការជំរុញនិងលើកទឹកចិត្តក្រុមជំនុំនិងសហគមន៍អោយធ្វើការជាមួយគ្នាដើម្បីទទួលលទ្ធល្អប្រសើរនាពេលអនាគត ។

**ក្នុងដំណាក់នីមួយៗមានផ្នែកនិងការបែងចែកជាជំហានៗផងដែរ ។**

## វដ្តជំបូងនៃអូម៉ូចា

ដំណាក់កាលទាំងប្រាំដែលជាទំរង់នៃវដ្តរបស់អូម៉ូចាគឺការចាប់ផ្តើមបង្កើតនិមិត្តរបស់ក្រុមជំនុំនិងបញ្ចប់ដោយការវាយតំលៃ ។






## ការរៀបរាប់អំពីវដ្តម្តងទៀតនៃអូម៉ូចា

នៅពេលសហគមន៏ទទួលបានការទុកចិត្តនិងពេលដែលកើតមានឡើងនូវរចនាសម្ពន្ធ័គ្រប់គ្រងគំរោងការផ្សេងៗ ពួកគេអាចរំលឹកជាច្រើនលើកច្រើនដងរហូតដល់រចនាសម្ពន្ធ័គ្រប់គ្រងនោះក្លាយជាជីវិតរបស់សហគមន៏។






## ៤.របៀបបង្កើតកម្មវិធីអូម៉ូចា

នៅពេលបង្កើតកម្មវិធីអូម៉ូចាអ្នកត្រូវពិចារណាអំពីជំហានដូចខាងក្រោមនេះ:

១.នៅពេលដែលក្រុមជំនុំនិងសហគមន៍ត្រូវបានជ្រើសរើស ការសំខាន់ក្នុងការបង្កើតនោះគឺជាការប្រជុំមួយរវាងអ្នកដឹកនាំក្រុមជំនុំនិងសហគមន៍ ដោយហេតុថាពួកគេអាចប្រមែប្រមូលសមាជិកសហគមន៍ទាំងអស់អោយចូលរួមជាបន្តបន្ទាប់ក្នុងសិក្ខាសាលាតូចៗ ។ ការប្រជុំនេះក៏មានប្រយោជន៍សំរាប់ការគិតអំពីពេលវេលាដែលត្រូវរៀបចំសិក្ខាសាលា និងកត់ចំណាំទុកនូវពេលវេលាដែលបុរសនិងស្ត្រីអាចចូលរួមបាន ។



២.គឺជាការល្អក្នុងការចាប់ផ្តើមគំនិតផ្តួចផ្តើមនេះនៅក្នុងកម្មវិធីថ្វាយបង្គំដោយប្រើប្រាស់ការឆ្លុះបញ្ចាំងព្រះបន្ទូលរបស់ព្រះនៅពេលអធិប្បាយ ។នេះគឺជាវិធីសាស្ត្រមួយដែលគំនិតផ្តួចផ្តើមចេញពីក្រុមជំនុំ ។

៣.នៅក្នុងករណីខ្លះ គឺជាការល្អដែលមានការប្រជុំក្នុងមួយខែម្តង ធ្វើដូច្នេះក្រុមជំនុំនិងសហគមន៍អាចនឹងខំប្រឹងប្រែងក្នុងការធ្វើការស្រាវជ្រាវនិងកសាងផែនការរដើម្បីផ្តល់ចំលើយតបទៅអ្នកសម្របសម្រួល ។ទោះបីជាយ៉ាងនេះក្តី ត្រូវពឹងផ្អែកទៅលើពេលវេលារបស់អ្នកចូលរួមថែមទៀត ។



៤.បន្ទាប់ពីសិក្ខាសាលាលើកទីមួយដែលជាចំនុចចាប់ផ្តើមទៅ ការសំខាន់គឺគួរតែងតាំងម្នាក់ក៏វីពីរនាក់ដែលអាចជួយតាមដានក្រុមជំនុំនិងសហគមន៍លើសកម្មភាពដែលគេបានធ្វើផែនការនិងដើម្បីធ្វើការអោយបានជិតស្និទ្ធជាមួយអ្នកសម្របសម្រួល ។អ្នកទាំងនេះគួរតែជាបុរសរឺស្ត្រីដែលមានភាពស្មោះត្រង់និងដែលសហគមន៍គោរព ។ហើយចាំបាច់ត្រូវបង្កើតក្រុមតូចមួយដែលមានឈ្មោះថា " ក្រុមសម្របសម្រួលមូលដ្ឋាន " "Local Co-ordination Group " ដែលហៅកាត់ថា（LCG）ដើម្បីសម្របសម្រួលគំរោងផ្សេងៗ ។



៥.តួនាទីមួយចំនួនទៀតរបស់ក្រុមអ្នកសម្របសម្រួលមូលដ្ឋានគឺត្រូវគ្រប់គ្រងកម្មវិធី ទទួលខុសត្រូវក្នុងការរៀបចំសិក្ខាសាលា រក្សាទុករបាយការណ៍នឹងចែកចាយទៅដល់សហគមន៍ ។ ពួកគាត់គួរតែត្រួតពិនិត្យការវិវត្តន៍របស់កម្មវិធីនិងធ្វើការជាមួយអ្នកសម្របសម្រួលលើការផ្លាស់ប្តូរអ្វីមួយប្រសិនបើជាការចាំបាច់ ។

៦.នៅពេលកម្មវិធីចាប់ផ្តើម ការសំខាន់គួរតែចែករំលែកនូវអ្វីដែលកំពុងប្រព្រឹត្តទៅ ដល់អាជ្ញាធររឹមន្ត្រីមូលដ្ឋាន។

៧.(LCG)គួតែជារួមមាន ប្រធាន(អ្នកសម្របសម្រួល) លេខាធិការ ហិរញ្ញឹក និង សមាជិកសំខាន់ៗដែលមានជំនាញក្នុងការរៀបចំនិងការប្រមូលគំនិត ។ជួនកាលវាមានប្រយោជន៏ប្រសិនបើអ្នកដឹកនាំក្រុមជំនុំមិនធ្វើជាប្រធាន(អ្នកសម្របសម្រួល)ដើម្បីអោយប្រជាជនបានិយាយដោយសេរី ។ចំពោះតួនាទីលំអិតរបស់អ្នកដែលត្រូវចូលរួមក្នុងដំណើរការនេះ សូមមើលទំព័រទី ៦៤-៦៦។

៨.(LCG)គួរតែជួបគ្នាជាទៀងទាត់ជាក្រុម ដើម្បីរៀបចំផែនការជាមុនក្នុងការរៀបចំសិក្ខាសាលា និងសកម្មភាពចាំបាច់នានាដែលត្រូវតាមដាន។

៩.ការផ្លាស់ប្តូរអាកប្បកិរិយានិងផ្នត់គំនិតរបស់មនុស្សត្រូវការចំនាយពេលវេលាយូរអង្វែង ។ពីព្រោះបើសិនជាដំណើរការលឿនពេក ការផ្លាស់ប្តូរនឹងមិនស៊ីជំរៅឡើយ ។មាន់ញាស់ក្នុងរយៈពេល២២ថ្ងៃ ហើយដំរីកើតកូនក្នុងរយៈពេល ២២ខែ ។ជួនកាលដំណើរការកម្មវិធី ត្រូវការចំនាយពេលយូរ ។



## ៥.តួនាទីរបស់ខ្ញុំជាអ្នកសម្របសម្រួល

តួនាទីជាអ្នកសម្របសម្រួលមានភារៈកិច្ចដូចខាងក្រោមនេះ :

- ជួបជាមួយអ្នកដឹកនាំនិងសមាជិកក្រុមជំនុំដើម្បីស្វែងយល់អំពីរបៀបដែលពួកគេអាចនឹងអនុវត្តអូម៉ូចាបាន
- សម្របសម្រួលសកម្មភាពផ្សេងៗដែលអាចជួយក្រុមជំនុំនិងសហគមន៏អាចឈានទៅរកការផ្លាស់ប្តូរបាន
- សម្របសម្រួលការសិក្សាព្រះគម្ពីរនិងជួយអោយប្រជាជនរៀនពីខ្លួនឯងព្រមទាំងអនុវត្តន៏ទៅតាមគោលការណ៏ស្ថានភាពរបស់ពួកគេ។
- ជំរុញអោយក្រុមធ្វើការជាមួយគ្នានិងជួយពួកគេក្នុងការដោះស្រាយនូវការលំបាកដែលអាចកើតមាន។
- រំលឹកអំពីអ្វីដែលកំពុងតែធ្វើបានល្អនិងអ្វីដែលនឹងអាចធ្វើអោយកាន់តែប្រសើរឡើង។



## ៦.អ្វីជាការសម្របសម្រួបហើយហេតុអ្វីបានជាវាមានសារៈសំខាន់?

### ➢ អ្វីជាការសម្របសម្រួល?

ការសម្របសម្រួលរួមមានៈ

- លើកទឹកចិត្តមនុស្សគ្រប់រូបនៅក្នុងក្រុមអោយធ្វើការចូលរួមចែករំលែកគំនិតព្រមទាំងបទពិសោធន៏របស់ខ្លួនតាមមធ្យោបាយដែលអាចធ្វើអោយពួកគេមានភាពងាយស្រួល ។
- ជួយក្រុមអោយមានការយល់ដឹងអំពីគោលគំនិតរួមដែលនឹងធ្វើអោយពួកគេមានអារម្មណ៏ថាខ្លួនកំពុងតែទទួលនូវការគាំទ្រ ។
- ទទួលមនុស្សគ្រប់រូបដោយមិនប្រកាន់ពូជសាសន៏ អាយុ វប្បធមិ ជំនាញ ការអប់រំ ពិការភាព ស្ថានភាព សេដ្ឋកិច្ច ឬ សុខភាព ។
- ដឹកនាំជាគំរូតាមរយៈសកម្មភាពនិងអាកប្បកិរិយា ។

### ➢ ហេតុអ្វីបានជាមានសារៈសំខាន់?

ការសម្របសម្រួលជាមធ្យោបាយល្អបំផុតក្នុងការធ្វើការជាមួយសហគមន៏ដើម្បីជួយពួកគេអោយរកឃើញដោយខ្លួនឯងនូវសក្ដានុពលភាពដែលពួកគេមានក្នុងការនាំការផ្លាស់ប្ដូរជាវិជ្ជមានទៅដល់សហគមន៏របស់ខ្លួន ។



*តាមរយៈការចែកចាយគំនិតរបស់ពួកយើង យើងអាចជំរុញទឹកចិត្តគ្នាទៅវិញទៅមក*
*ចែកចាយនូវនិមិត្តនិង ធ្វើអោយកើតមានឡើងនាថ្ងៃអនាគត ។*
*យើងអាចរកឃើញនូវគុណតំលៃរួមនិងបង្កើនការប្ដេជ្ញាចិត្ត ។*
*ដោយគិតតាមរបៀបនៃការវិភាគយើងអាចកំនត់បានពីរបៀបដែលយើងធ្វើការជាមួយគ្នា ។*

Ruth Hild, The Art of Facilitation

## ➢ ភាពខុសគ្នារវាងការអធិប្បាយ ការបង្រៀន និង ការសម្របសម្រួល

មនុស្សពេញវ័យរៀនល្អបំផុតនៅពេលពួកគេទទួលបានការសម្របសម្រួលនិងការអនុញ្ញាតិអោយបញ្ចេញមតិនិងបទពិសោធន៍ផ្ទាល់ខ្លួន ។ការសម្របសម្រួលគឺពឹងផ្អែកលើការធ្វើការជាមួយថាមពលនិងការលើកទឹកចិត្តរបស់ក្រុម ។ការងាររបស់អ្នកសម្របសម្រួលគឺធ្វើយ៉ាងណាអោយក្រុមនៅតែមានការរំភើបនិងមានទឹកចិត្តចំពោះបញ្ហាដែលគេចង់រុករក ។

- **ការអធិប្បាយនិងការបង្រៀន**
  - ការចែករំលែកពតិមាននៅក្នុងទិសដៅតែមួយ ។
  - ការបង្ហាញគំនិតពីខាងមុខ ។
  - ទំនាក់ទំនងផ្លូវការជាមួយអ្នកស្តាប់ ។



- **ការសម្របសម្រួល**
  - ការចែករំលែកនៅក្នុងទិសដៅជាច្រើន ។
  - អ្នកសម្របសម្រួលអង្គុយជាមួយក្រុមនិងលើកទឹកចិត្តអោយមានការពិភាក្សា ។
  - អ្នកសម្របសម្រួលជាអ្នកដឹកនាំដែលគ្មានតួនាទីដឹកនាំជាផ្លូវការ ។

***ទៅរកប្រជាជន***
***រស់នៅជាមួយពួកគេ***
***រៀនពីពួកគេ***
***ស្រឡាញ់ពួកគេ***
***ចាប់ផ្តើមជាមួយអ្វីដែលពួកគេដឹង***
***បង្កើនអ្វីដែលពួកគេមាន***
***ប៉ុន្តែជាអ្នកដឹកនាំល្អម្នាក់***
***នៅពេលការងារត្រូវបានបញ្ចប់***
***កិច្ចការបានសំរេច***
***ប្រជាជននឹងនិយាយថា***
***យើងបានបញ្ចប់ការងារនេះជាមួយគ្នា***

***ដោយ ឡាវ សឺ សុភាសិតចិន នៅឆ្នាំ៧០០មុនគ្រីស្តសករាជ ( Lao Tsu, China 700B.C ) ។***

- ## ល្បិចក្នុងការសម្របសម្រួលក្រុម
  - ### របៀបធ្វើអោយក្រុមនិយាយគ្នា

- អោយអ្នកចូលរួម២ទៅបីនាក់ចែកចាយគំនិតរបស់ពួកគេទៅវិញទៅមកហើយអោយពួកគេចែកចាយគំនិតនោះទៅក្នុងក្រុមធំ ។ការនេះដើម្បីជួយអោយសមាជិកដែលមានការអៀនខ្មាស់ច្រើនបានចូលរួមផង ។
- ចែកក្រុមទៅតាម ភេទ អាយុ ហើយអោយពួកគេចែកចាយគំនិតផ្សេងៗរបស់ខ្លួនទៅលើបញ្ហាដូចគ្នា ។
- អោយក្រុមតូចនីមួយៗបង្ហាញចំលើយដោយប្រើល្ខោន ឬចំរៀង ឬក៏ការត្រាប់តាម ។
- ប្រើប្រភេទការងារនៃក្រុមផ្សេងៗសំរាប់ការពិភាក្សាសហគមន៍ដូចជាក្រុមតូច ការប្រមូលគំនិត និងល្ខោន ។

  - ### របៀបដែលធ្វើអោយក្រុមនៅតែមានថាមពល



- ប្រើសកម្មភាពដែលសមស្របទៅនឹងវប្បធម៌ដែលអាចជា ការច្រៀង ការរាំនិងល្បែងកុមារដើម្បីជួយអោយពួកគេមានការបន្ធូរអារម្មណ៍និងនៅតែមានចិត្តចង់ចូលរួម ។
- ដាក់ក្រុមអោយនៅចំរុះគ្នា ដូច្នេះហើយពួកគេមិនអាចនៅជាមួយមនុស្សដដែលៗគ្រប់ពេលវេលាទេ ។
- ផ្លាស់ប្តូរទីកន្លែងដែលក្រុមជួបគ្នាដូចជាចេញពីខាងក្នុងទៅខាងក្រៅបន្ទប់ឬផ្លាស់លក្ខណៈនៃបន្ទប់ជាដើម ។
- គិតរកមធ្យោបាយផ្សេងៗនៅពេលដែលអ្នកចូលរួមផ្តល់ចំលើយត្រលប់មកវិញឬចែកចាយពត៌មាន ។ ឧទាហរណ៏ ការប្រើគំនូរ ឬឧបករណ៏ផ្សេងៗ ។

- ## របៀបគ្រប់គ្រងស្ថានភាពលំបាកនានា:

  - ### ការគ្រប់គ្រងជំលោះ

- រំលឹកដល់អ្នកចូលរួមអំពីគោលដៅរួមនិងគោលបំនងរួមរបស់ការប្រជុំនិងស្វែងរកវិធីសាស្ត្រដោះស្រាយជំលោះនៅពេលក្រោយ ។
- ផ្តល់ពេលវេលាអោយភាគីនីមួយៗចែកចាយនូវបញ្ហារបស់ខ្លួននិងយល់អំពីមូលហេតុនៃជំលោះ ។
- ផ្តល់ឱកាសអោយភាគីម្ខាងបាននិយាយ ហើយភាគីម្ខាងទៀតរង់ចាំស្តាប់ដោយមិនអោយមានមតិអ្វីទាំងអស់ ។ ទុកអោយភាគីនីមួយៗសង្ខេបនូវជំហររបស់អ្នកដទៃដោយគ្មានការរិះគន់និងធ្វើសំនូមពររកវិធីសាស្ត្រសំរាប់ដោះស្រាយនៅពេលខាងមុខទៀត ។

### ○ ការគ្រប់គ្រងមនុស្សមានឥទ្ធិពលលើក្រុម

- កំនត់ច្បាប់រួមនិងរំលឹកក្រុមអោយចងចាំ ។
- អោយកិច្ចការពួកគាត់ធ្វើដូចជាសរសេរលើក្រដាស់ធំ ឬទទួលបន្ទុកហៅអ្នកចូលរួមត្រឡប់មកវិញអោយទាន់ពេលបន្ទាប់ពីសំរាក ។
- ចែកអោយពួកគេនូវគ្រាប់សណ្តែកមួយចំនួនឬក៏ជាតួលេខហើយពន្យល់ពួកគាត់ថាគាត់អាចមានមតិបានតែនៅពេលដែលពួកគេបានទទួលការហៅលេខដូចចំនួនតួលេខឬចំនួនគ្រាប់សណ្តែកតែប៉ុណ្ណោះ ។
- ជំរើសមួយទៀតគឺអាចប្រើវត្ថុមួយបោះជុំវិញហើយអ្នកណាដែលទទួលរបស់នោះទើបមានសិទ្ធិនិយាយ ។

### ○ ការគ្រប់គ្រងសំនួរផ្សេងៗដែលមានការលំបាក

- សារភាពថាអ្នកមិនដឹងចំលើយប៉ុន្តែអ្នកនឹងព្យាយាមស្វែងរកចំលើយពីអ្នកដ៏ទៃទៀតដែលដឹងមកប្រាប់ ។
- សួរអ្នកដែលចូលរួមថាតើមានអ្នកណាដឹងចំលើយឬទេ ។
- ធ្វើបញ្ជីសំនួរលំបាកៗនិងពន្យល់ថា អ្នកនៅមានពេលសំរាប់ឆ្លើយសំនួរជាលំអិត ។ប្រការនេះនឹងផ្តល់អោយអ្នកមានឱកាសដើម្បីស្រាវជ្រាវរកចំលើយ ។



## ■ បញ្ជីសំរាប់វាយតំលៃនិងការបង្កើនជំនាញសម្របសម្រួលរបស់អ្នក

អ្នកសម្របសម្រួលដ៏ល្អម្នាក់ គឺតែងតែធ្វើការឆ្លុះបញ្ចាំងទៅលើវិធីសាស្រ្តដែលពួកគេកំពុងធ្វើ ដោយរៀនចេញពីបទពិសោធន៍ដែលមានកន្លងមក និងធ្វើអោយវាកាន់តែប្រសើរឡើង ។បញ្ជីវាយតំលៃផ្ទាល់ខ្លួនខាងក្រោមនេះអាចជួយអោយការឆ្លុះបញ្ចាំងនេះមានដំណើរការទៅបានៈ

- តើខ្ញុំបានធ្វើអោយអ្នកចូលរួមមានអារម្មណ៏ធូរស្រាលនិងរីករាយដែរឬទេ? ប្រសិនបើមានតើមកពីមូលហេតុអ្វី?
- តើពតិមានទាំងនេះមានការទំនាក់ទំនងគ្នាយ៉ាងដូចម្តេច ដើម្បីអោយក្រុមយកទៅប្រើ? តើខ្ញុំអាចសម្របខ្លួនយ៉ាងដូចម្តេចស្របទៅតាមពតិមាននេះដើម្បីអោយមានទំនាក់ទំនងនៅក្នុងក្រុម?

- តើខ្ញុំបានលើកទឹកចិត្តដល់សមាជិកដែលស្ងៀមស្ងាត់អោយបានចូលរួមពិភាក្សាក្នុងក្រុមយ៉ាងដូចម្ដេច?
- តើខ្ញុំបានដោះស្រាយជាមួយមតិផ្សេងៗយ៉ាងដូចម្ដេច?
- តើខ្ញុំបានចូលរួមដោះស្រាយជាមួយអ្នកចូលរួមដែលមានឥទ្ធិពលក្នុងក្រុមយ៉ាងដូចម្ដេច?
- តើខ្ញុំបានឆ្លើយតបទៅនឹងសំនួរពីសំណាក់អ្នកចូលរួមយ៉ាងដូចម្ដេច? តើខ្ញុំអាចឆ្លើយតបទៅនឹងសំនួររបស់ពួកគេបានដែរឬទេ? ប្រសិនបើមិនអាច តើខ្ញុំអាចស្វែងរកពត៌មានដែលអាចជួយខ្ញុំអោយដោះស្រាយសំនួរទាំងនោះទៅថ្ងៃមុខដោយរបៀបណាខ្លះ?
- តើខ្ញុំបានណែនាំការពិភាក្សាដោយរបៀបណា? តើខ្ញុំធ្វើយ៉ាងដូចម្ដេច ដើម្បីអោយប្រសើជាងនេះ?
- តើខ្ញុំបានលើកទឹកចិត្តការពិភាក្សាក្រុមដោយរបៀបណា?
- តើខ្ញុំបានដោះស្រាយភ្លាមៗដោយរបៀបណា?
- តើខ្ញុំបានដឹកនាំការពិភាក្សាទៅរកសេចក្ដីសន្និដ្ឋានបានពេញចិត្តដែរឬទេ?
  តើខ្ញុំធ្វើយ៉ាងដូចម្ដេច ដើម្បីអោយប្រសើជាងនេះ?
- តើខ្ញុំបានធ្វើអោយប្រាកដថាគំនិតរបស់ក្រុមត្រូវបានកត់ត្រាសំរាប់ប្រើក្នុងការពិភាក្សាបន្ត ការកសាងផែនការក្រុម ឬក៏ការចែករំលែកទៅអ្នកដទៃដោយរបៀបណា?
- តើសមាជិកក្រុមបានប្ដេជ្ញាចិត្តយករបៀបដែលគេបានរៀនទៅអនុវត្តន៏ជាក់ស្ដែងដោយរបៀបណា? ប្រសិនបើទេ តើខ្ញុំអាចលើកទឹកចិត្តពួកគេបានដោយរបៀបណា?
- តើអ្វីជាពត៌មានបន្ថែមឬជាការពិភាក្សាដែលចាំបាច់ត្រូវតាមដានដើម្បីដោះស្រាយគំនិតនិងប្រធានបទដែលត្រូវលើកយកមកពិភាក្សា?

# ដំណាក់កាលទី១:

## ការបង្កើតនិមិត្តនិងការឃ្វើកឃ្វើនក្រុមជំនុំ



**ទិដ្ឋភាពទូទៅនៃតំណាក់កាលទី១: ការបង្កើតនិមិត្ត និងការហ្វឹកហ្វឺនក្រុមជំនុំ**

គោលបំណងនៃតំណាក់កាលនេះ:

ដើម្បីជួយអោយក្រុមជំនុំមាននិមិត្តក្នុងការធ្វើការងារជាមួយសហគមន៏របស់ខ្លួន និងប្រើប្រាស់នូវធនធានរបស់ខ្លួនដើម្បីអនុវត្តគម្រោងខ្នាតតូច ។

តំណាក់កាលនេះចែកចេញជាផ្នែក៧ដូចខាងក្រោមនេះ:




វារួមបញ្ចូលសកម្មភាពនានាដូចខាងក្រោមនេះ:

**១.ល្បែងបង្កើនថាមពល:**

នៅក្នុងផ្នែកនេះមានបញ្ចូលល្បែងមួយចំនួនទាំងនៅមុននិងក្រោយការសិក្សាព្រះគម្ពីរ ។ ល្បែងទាំងនេះមានសារសំខាន់មិនគ្រាន់តែសម្រាប់ដាស់ស្មារតីអ្នកចូលរួមប៉ុណ្ណោះទេ តែថែមទាំងជួយអោយការសិក្សាទាំងមូលមានភាពសប្បាយរីករាយនិងសម្រាកផ្នែកអារម្មណ៍ទៀតផង ។ល្បែងទាំងនេះថែមទាំងមានតួនាទីសំខាន់ផងដែរនៅក្នុងការបង្កើតការយល់ដឹងបន្ថែមតាមរយៈការចែកចាយបទពិសោធន៏របស់អ្នកចូលរួម ។ ល្បែងនេះអាចមានសារសំខាន់នៅពេលដែលយើងប្រើវាដើម្បីអោយអ្នកចូលរួមទាញយកចំនុចនិងមេរៀនសំខាន់ៗយកទៅអនុវត្តន៏ ។



## ២.ការសិក្សាព្រះគម្ពីរ : 

តំណាក់កាលទីមួយគឺពឹងផ្អែកទៅលើការសិក្សាព្រះគម្ពីរដើម្បីជំរុញទឹកចិត្តសមាជិកអោយមានការរំភើបអំពីការធ្វើការងារជាមួយសហគមន៏ ។ការសិក្សាព្រះគម្ពីរគឺមានសារសំខាន់ខ្លាំងណាស់ ។

- ដើម្បីអោយក្រុមជំនុំឆ្លុះបញ្ចាំងលើអ្វីដែលព្រះជាម្ចាស់ទ្រង់ត្រាស់ហៅពួកគេធ្វើនិងអនុវត្តក្នុងសហគមន៏
- ដើម្បីជំរុញនិងលើកទឹកចិត្តក្នុងការពង្រឹងនូវជំនឿរបស់ពួកគេ ។
- ដើម្បីអោយក្រុមតូចៗទាំងឡាយរៀនជាមួយគ្នានិងចែកចាយការយល់ដឹងរបស់ខ្លួនទៅវិញទៅមក ។
- ដើម្បីផ្តល់សិទ្ធិអំណាចនិងផ្តល់អោយពួកគេមានការជឿជាក់ ។

នៅពេលក្រុមជំនុំបានសិក្សាព្រះគម្ពីរហើយ គេគួរព្យាយាមបង្កើតនូវនិមិត្តសំរាប់ការងារនៅក្នុងសហគមន៏និងចាប់ផ្តើមគិតអំពីអ្វីជាក់ស្តែងដែលអាចនឹងធ្វើជាមួយសហគមន៏ ។នៅពេលក្រុមជំនុំមាននិមិត្តសំរាប់ធ្វើការជាមួយសហគមន៏ហើយ ក្រុមជំនុំត្រូវការពិចារណាអំពីរបៀបដោះស្រាយនូវតំរូវការក្នុងក្រុមជំនុំនិងក្នុងសហគមន៏ចេញពីធនធាននានាដែលខ្លួនមាន ។ប្រការនេះគឺដើម្បីធ្វើអោយគំនិតផ្តួចផ្តើមទាំងនោះមាននិរន្តរភាពយូរអង្វែង ។



## ៣.សកម្មភាពអបអរ:

នៅក្នុងផ្នែកនេះមានបញ្ចូលសកម្មភាពអបអរនានាពីព្រោះសកម្មភាពទាំងនេះអាចជួយអោយអ្នកចូលរួមមាន ទស្សនះវិជ្ជមាននិងពោរពេញដោយថាមពលចំពោះស្ថានភាពរបស់ពួកគេ ។យើងព្យាយាមភ្ជាប់សកម្មភាពទាំងនេះ ទៅនឹងលក្ខណៈស្រដៀងៗគ្នាប៉ុន្តែក្រុមនីមួយៗអាចជ្រើសរើសយកសកម្មភាពមួយណាដែលជាតំរូវការរបស់ខ្លួន ។

- *ហេតុអ្វីបានជាការអបអរមានសារសំខាន់ ?*

ជាផ្នែកមួយនៃការថ្វាយបង្គំព្រះជាម្ចាស់

ជួយយើងអោយចេះអបអរគ្នាទៅវិញទៅមក

ផ្តល់អោយយើងនូវថាមពល
ដើម្បីចាប់យកឱកាសថ្មីៗ



ជួយយើងអោយដឹងនូវអ្វីដែល
យើងធ្វើបានយ៉ាងល្អបំផុត

កសាងភាពជឿជាក់ទៅលើ
អ្វីដែលយើងអាចធ្វើបាន

ជួយយើងអោយគិតពីអ្វីដែល
យើងអាចពឹងផ្អែកបាន

ជួយយើងអោយគិតអំពីសក្តានុពលភាពរបស់យើងក្នុងលក្ខណៈ
ជាក្រុមដើម្បីបំពេញកិច្ចការត្រឹមត្រូវរួមគ្នា

## ផ្នែកទី១ : ការបង្កើតនិមិត្តដល់ក្រុមជំនុំ

❖ គោលបំណង

គឺដើម្បីអោយក្រុមជំនុំមាននិមិត្ត ក្នុងការធ្វើការងារជាមួយសហគមន៍ក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការនានាទាំងផ្នែកព្រលឹងវិញ្ញាណ និងផ្នែករូបកាយរបស់ពួកគេ ។ការនេះអាចសំរេចបានដោយឈរលើជំហានគន្លឹះ ០៥ ជំហាន ដែលជំហាននីមួយៗត្រូវបានពន្យល់នៅក្នុងទំព័របន្តបន្ទាប់ ។

ជំហានគន្លឹះទាំងប្រាំ :

១-ជួបប្រជុំជាមួយអ្នកដឹកនាំក្រុមជំនុំ និងរៀបចំផែនការបង្កើតនិមិត្តសម្រាប់ក្រុមជំនុំ ។

២-ប្រើល្បែងបង្កើនថាមពលដើម្បីអោយអ្នកចូលរួមគិតអំពីបញ្ហាផ្សេងៗនៃការធ្វើការរួមគ្នា ។

៣-លើកយកព្រះគម្ពីរមកសិក្សាអោយបានម្តងឬច្រើនដងដើម្បីធ្វើការឆ្លុះបញ្ចាំងថាតើនិមិត្តនេះមានប្រយោជន៍យ៉ាងណាខ្លះចំពោះក្រុមជំនុំ និងសហគមន៍របស់ពួកគេផ្ទាល់ ។

៤-អនុវត្តសកម្មភាពអបអរដើម្បីពិនិត្យឡើងវិញនូវប្រវត្តិសាស្ត្ររបស់ក្រុមជំនុំ និងសហគមន៍ ។

៥.បង្កើតក្រុមអ្នកសម្របសម្រួលក្រុមជំនុំ (ក.ស.ក)(CCG) Church Co-ordination Group ។



✳ ជំហានទី១ : ជួបប្រជុំជាមួយអ្នកដឹកនាំក្រុមជំនុំ

❖ **ការកសាងទំនាក់ទំនង**

មុនពេលពិភាក្សាអំពីអូម៉ូចាជាមួយអ្នកដឹកនាំក្រុមជំនុំ ការសំខាន់គឺការចំនាយពេលវេលាដើម្បីស្គាល់ពួកគេអោយបានច្បាស់លាស់ជាមួយសមាជិកក្រុមជំនុំ ។វាសំខាន់ណាស់ដែលត្រូវធ្វើអោយប្រាដកថាអូម៉ូចាគឺជាអ្វីដែលអ្នកដឹកនាំក្រុមជំនុំពិតជាចង់យកទៅអនុវត្តមែន ។នៅក្នុងករណីក្រុមជំនុំខ្លះ អ្នកដឹកនាំក្រុមជំនុំមូលដ្ឋានចង់ចូលរួមជាមួយអូម៉ូចានៅពេលអ្នកដឹកនាំនិកាយឬគ្រូគង្វាលធំមានការយល់ព្រមពីដំណើរការរួចហើយ ។



អ្នកសម្របសម្រួលត្រូវដឹងថាអ្នកដឹកនាំក្រុមជំនុំខ្លះអាចមានរបៀបវារៈលាក់កំបាំង ។ឧទាហរណ៍ដូចជាមានបំនងប្រើអូម៉ូចាដើម្បីទទួលមូលនិធិជំនួសសកម្មភាពផ្សេងទៀតឬប្រើដើម្បីទទួលកេរ្តិ៍ឈ្មោះនៅក្នុងសហគមន៍ឬដើម្បីបង្កើនឥទ្ធិពលរបស់ពួកគេ ។ហេតុដូច្នេះហើយបានជាវាមានសារៈសំខាន់ណាស់ក្នុងការចំនាយពេលស្គាល់អ្នកដឹកនាំក្រុមជំនុំដើម្បីអោយយល់អំពីអ្វីដែលពួកគេបានគិតអំពីអូម៉ូចា ។



- **ចំនុចដែលត្រូវពិភាក្សាជាមួយអ្នកដឹកនាំក្រុមជំនុំ:**

  - គោលបំនងនិងផលប្រយោជន៍របស់អូម៉ូចា
  - របៀបធ្វើការរបស់អូម៉ូចា
  - តួនាទីរបស់អ្នកដឹកនាំក្រុមជំនុំក្នុងការងារអូម៉ូចា
  - បញ្ហាណាខ្លះនៅក្នុងក្រុមជំនុំនិងសហគមន៍ដែលអាចប៉ះពាល់ដល់អូម៉ូចា
  - លទ្ធភាពដែលមានក្នុងការងារកសាងគំនិតផ្តួចផ្តើមរួមរបស់ក្រុមជំនុំក្នុងសហគមន៍
  - របៀបរៀបចំសកម្មភាពនិងការសិក្សាព្រះគម្ពីរជាមួយក្រុមជំនុំនិងអ្នកដែលអាចជួយការងារនេះបាន។

### ❖ ការដោះស្រាយជាមួយការព្រួយបារម្ភណ៍

អាចមានបញ្ហារាំងស្ទះខ្លះៗចំពោះការចាប់ផ្ដើមដំណើរការប្រជុំនេះទាក់ទងនឹងមូលហេតុមួយចំនួន។ ការលើកឡើងនូវការព្រួយបារម្ភនានា និងការផ្ដោតគំនិតទៅលើផលប្រយោជន៍នៃដំណើរការនេះគឺជាកិច្ចការមួយដ៏មានសារៈសំខាន់។

-អ្នកដឹកនាំក្រុមជំនុំអាចព្រួយបារម្ភថា អូម៉ូចាអាចយកដង្វាយរបស់ក្រុមជំនុំទៅប្រើប្រាស់សម្រាប់ជាប្រយោជន៍ដល់សហគមន៍ ។ត្រូវបញ្ជាក់អោយច្បាស់ថាលទ្ធផលនៃអូម៉ូចាគឺតែងតែធ្វើអោយដង្វាយក្រុមជំនុំមានការកើនឡើងជានិច្ច។

-អ្នកដឹកនាំក្រុមជំនុំអាចមានការព្រួយបារម្ភថា កិច្ចការនេះអាចបង្អាក់សមាជិកក្រុមជំនុំក្នុងការប្រកាសដំណឹងល្អ។ ត្រូវបញ្ជាក់អោយច្បាស់ថា អូម៉ូចាជួយពង្រឹងទំនាក់ទំនងរបស់ក្រុមជំនុំ និងសហគមន៍ដែលអាចធ្វើអោយក្រុមជំនុំមានការរីកចំរើន។

- អ្នកដឹកនាំក្រុមជំនុំអាចមានការព្រួយបារម្ភថា ពួកគេគ្មានធនធាន និងពេលវេលាក្នុងការអនុវត្តន៍គម្រោងនានានៅក្នុងសហគមន៍។ ត្រូវបញ្ជាក់អោយច្បាស់ថា អូម៉ូចាគឺធ្វើអោយក្រុមជំនុំ និងសហគមន៍ធ្វើការរួមគ្នានិងជួយរំលែកការងារគ្នាទៅវិញទៅមក។

-ប្រជាជនអាចព្រួយបារម្ភពីរយៈពេលនៃការអនុវត្តន៍គម្រោង។ ត្រូវតែស្មោះត្រង់និងមានភាពច្បាស់លាស់ចំពោះកិច្ចការនេះ ប៉ុន្តែត្រូវរំលឹកពួកគាត់ថាការផ្លាស់ប្ដូរមិនអាចកើតមានឡើងភ្លាមៗបានទេ។

-អ្នកដឹកនាំក្រុមជំនុំខ្លះអាចមានចិត្តស្ទាក់ស្ទើរក្នុងការធ្វើការជាមួយក្រុមជំនុំផ្សេងៗទៀតនៅក្នុងសហគមន៍។ ត្រូវបញ្ជាក់អោយច្បាស់ថា អូម៉ូចាមានគោលដៅប្រមូលផ្ដុំក្រុមជំនុំទាំងអស់ដើម្បីបំរើសហគមន៍ ។ការធ្វើអោយក្រុមជំនុំនានាមានទំនាក់ទំនងល្អជាមួយគ្នាគឺជាកិច្ចការមួយដ៏អស្ចារ្យ។



✳ ជំហានទី២ : ល្បែងបង្កើនថាមពល-គិតអំពីភាពលំបាកក្នុងការធ្វើការងាររួមគ្នា

❖ *ការបន្ទាបកំណាត់ឈើ*

នេះគឺជាល្បែងមួយដ៏មានសារសំខាន់ដែលធ្វើអោយប្រជាជនគិតអំពីភាពលំបាកនានាក្នុងការធ្វើការងាររួមគ្នា។

- សកម្មភាពដែលត្រូវធ្វើ :

-បែងចែកអ្នកចូលរួមជាពីរក្រុមដែលមានសមាជិករហូតដល់៨រូប បន្ទាប់មកអោយពួកគាត់តំរង់ជាពីរជួរ

-យកកំណាត់ឬស្សីវែងមួយដើមមកអោយពួកគាត់ទាំងពីរក្រុមទ្រ ដោយប្រើតែម្រាមដៃតែមួយប៉ុណ្ណោះ

-ត្រូវប្រាកដថាកំណាត់ឈើនេះស្ថិតនៅក្នុងកំពស់ស្មើគ្នាហើយអ្នកចូលរួមទាំងអស់បានទ្រគ្រប់ៗគ្នា បន្ទាប់មកប្រាប់ក្រុមទាំង២នោះអោយបន្ទាបកំណាត់ឈើនោះចុះក្រោមរហូតដល់ដី ដោយរក្សាវាអោយស្ថិតនៅក្នុងកំពស់ស្មើគ្នា។

-ធ្វើការពិភាក្សាក្នុងក្រុមទៅលើកត្តាដែលធ្វើអោយកិច្ចការនេះទទួលបានជោគជ័យ ហើយអ្វីដែលជាការលំបាកក្នុងការធ្វើកិច្ចការនេះ។

-តើមានចំនុចអ្វីខ្លះដែលយើងអាចរៀនបានពីល្បែងនេះ ទាក់ទងទៅនឹងរបៀបដែលយើងធ្វើការរួមគ្នានៅក្នុងក្រុមជំនុំ។

អ្នកអាចប្រើល្បែងបង្កើនថាមពលផ្សេងៗទៀតដែលអ្នកចេះ ហើយយល់ថាមានសារៈសំខាន់ក្នុងការជំរុញអោយអ្នកចូលរួមគិតអំពីការធ្វើការងារជាមួយគ្នា។



✳ **ជំហានទី៣ : ការសិក្សាព្រះគម្ពីរ**

ព័ន្ធកិច្ចរបស់ព្រះយេស៊ូគ្រីស្ទ —ការបង្កើតនិមិត្តដកលក្រុមជំនុំក្នុងមូលដ្ឋាន

យើងអាចចែកការសិក្សាព្រះគម្ពីរនេះជាបីផ្នែកផ្សេងៗគ្នា ហើយយើងក៏អាចបែងចែកអ្នកចូលរួមជា បីក្រុមផងដែរដោយ មួយក្រុមសិក្សាមួយផ្នែក ឬយើងមិនចាំបាច់បែងចែកក្រុមក៏បាន ដោយរៀនតាមលំដាប់ផ្នែកនីមួយៗក្នុងពេលផ្សេងៗគ្នា។

❖ ការក្តួលអាណិត :

*សូមអានម៉ាថាយ៩:៣៥-៣៨*

១.តើការពណ៌នាពីកិច្ចការរបស់ព្រះយេស៊ូគ្រីស្ទនៅក្នុងអត្ថបទគម្ពីរនេះមានលក្ខណៈស្រដៀងនឹងអ្វីដែលបានពណ៌នានៅក្នុងអត្ថបទគម្ពីរម៉ាថាយ៤:២៣-២៥យ៉ាងណា ? តើកិច្ចការថ្មីអ្វីខ្លះដែលយើងអាចរៀនពីព័ន្ធកិច្ចរបស់ព្រះយេស៊ូគ្រីស្ទបាន?

២.តើមានពាក្យឬរូបភាពអ្វីដែលអ្នកប្រើដើម្បីពណ៌នាពីមនុស្សដែល "នឿយព្រួយ និងអស់សង្ឃឹម ដូចជាចៀមគ្មានអ្នកគង្វាល"?

៣.ពាក្យ "ក្តួលអាណិត" (ខ៣៦) ជាពាក្យមួយមានអត្ថន័យស៊ីជំរៅយ៉ាងខ្លាំង ។ពិតជាធ្វើអោយព្រះយេស៊ូគ្រីស្ទមានការឈឺចាប់នៅពេលទ្រង់ទតឃើញហ្វូងប្រជាជន និងដឹងថាពួកគេជាអ្នកណា។
នៅពេលដែលយើងឃើញប្រជាជនកំពុងមានតម្រូវការ តើយើងឆ្លើយតបទៅពួកគេយ៉ាងដូចម្តេច?

៤.តើអ្វីជាការជំរុញទឹកចិត្តយើង នៅពេលយើងព្យាយាមជួយប្រជាជនដែលកំពុងមានតម្រូវការ? តើកិច្ចការនេះមានលក្ខណៈដូច ឬខុសគ្នាយ៉ាងណាទៅនឹងកិច្ចការរបស់ព្រះយេស៊ូគ្រីស្ទ?

៥.ហេតុអ្វីអ្នកគិតថា ការឆ្លើយតបប្រកបដោយភាពក្តួលអាណិតរបស់ព្រះយេស៊ូគ្រីស្ទចំពោះមនុស្សដែលកំពុងមានតម្រូវការនាំអោយព្រះអង្គមានព្រះបន្ទូលថា "វាលចំរូតធំណាស់ តែអ្នកច្រូតមានតិចតួចប៉ុណ្ណោះ"?(ខ៣៧)

*ចំនុចគន្លឹះ : ព្រះរាជ្យរបស់ព្រះជាម្ចាស់ស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះអស់អ្នកណាដែលនឿយព្រួយ និងអស់សង្ឃឹម ក៏ប៉ុន្តែអ្នកដែលធ្វើការដើម្បីចែករំលែកការក្តួលអាណិតរបស់ព្រះយេស៊ូគ្រីស្ទចំពោះពួកគេមានចំនួនតិចតួចប៉ុណ្ណោះ ។*



❖ ការប្រោសអោយជា :

*សូមអានម៉ាថាយ៤:១២-១៣, ២៣-២៥*

១.តើព្រះយេស៊ូគ្រីស្ទទ្រង់ធ្វើអ្វីខ្លះ?

*ចំនុចគន្លឹះ :តាំងពីចាប់ផ្ដើមព្រះយេស៊ូគ្រីស្ទយាងទៅកាន់កន្លែងដែលប្រជាជនរស់នៅដើម្បីបំពេញកិច្ចការរបស់ទ្រង់ ។ ការដែលប្រជាជនចាប់ផ្ដើមមករកព្រះយេស៊ូគ្រីស្ទគឺជាលទ្ធផលនៃការដែលទ្រង់យាងចេញទៅរកពួកគេមុន ។*

២.តើអ្វីដែលនាំអោយមានមនុស្សជាច្រើនមករក និងស្ដាប់ព្រះយេស៊ូគ្រីស្ទ?

៣.តើព័ន្ធកិច្ចប្រោសអោយជារបស់ព្រះយេស៊ូគ្រីស្ទប្រាប់យើងពីអ្វីទាក់ទងទៅនឹងព្រះរាជ្យនៃព្រះ?

៤.តើក្រុមជំនុំរបស់អ្នកកំពុងបង្ហាញ ឬមិនបង្ហាញពីព័ន្ធកិច្ចនៃការប្រោសអោយជាតាមរបៀបណា? តើក្រុមជំនុំរបស់អ្នកត្រូវការផ្លាស់ប្ដូរបែបណា?

*ចំនុចគន្លឹះ :អត្ថបទនេះបង្ហាញយើងថា ផ្នែកសំខាន់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់គឺបំបាត់ការឈឺចាប់ ទទួលស្គាល់ការឈឺចាប់ផ្នែកផ្លូវចិត្ត ឬផ្លូវកាយរបស់មនុស្ស និងជួយពួកគេអោយឆ្លងផុតពីបញ្ហាទាំងនោះ ។*

❖ ការប្រែចិត្ត :

*សូមអានម៉ាថាយ៣:១-២ និង ៤:១៧*

○ ហេតុអ្វីបានជាអ្នកគិតថា ព្រះយេស៊ូគ្រីស្ទប្រកាសឡើងវិញនូវព្រះរាជសារដែលលោកយ៉ូហានបាប់ទីស្ទបានប្រកាសរួចហើយ?

*ចំនុចគន្លឹះ : ព្រះយេស៊ូគ្រីស្ទយល់ស្របចំពោះព្រះរាជសារដែលលោកយ៉ូហានបាប់ទីស្ទបានប្រកាស ។*

១.តើខ្លឹមសារនៃអ្វី ដែលលោកយ៉ូហានបាប់ទីស្ទបានប្រកាស? (សូមអានលូកា៣:៧-១៤)

២.តើអំពើបាបអ្វីខ្លះដែលលោកយ៉ូហានបាប់ទីស្ទបានលើកឡើង ហើយត្រូវអោយមនុស្សប្រែចិត្តចេញពីអំពើទាំងអស់នោះដើម្បីត្រៀមខ្លួនចូលក្នុងនគរព្រះ? សូមសរសេរចុះជាចំនុចនូវអំពើបាបទាំងនោះ

៣.ប្រសិនបើលោកយ៉ូហានបាប់ទីស្ទកំពុងប្រកាសព្រះរាជសារនៅក្នុងសហគមន៍របស់យើងបច្ចុប្បន្ននេះ តើអំពើបាបអ្វីខ្លះដែលគាត់នឹងប្រាប់យើងអោយប្រែចិត្ត? សូមសរសេរចុះជាចំនុចនូវអំពើបាបទាំងនោះ

៤.តាមរយៈអ្វីដែលព្រះយេស៊ូគ្រីស្ទនិងលោកយ៉ូហានបាប់ទីស្ទបានប្រកាស តើអ្វីខ្លះជាចរិតលក្ខណៈនៃនគរព្រះ?

៥.តើសព្វថ្ងៃនេះក្រុមជំនុំរបស់អ្នកកំពុងបង្ហាញឬមិនបង្ហាញនូវចរិតលក្ខណៈនេះដោយរបៀបណា? តើក្រុមជំនុំរបស់អ្នកត្រូវការផ្លាស់ប្តូរយ៉ាងណា?

*ចំនុចគន្លឹះ : ព្រះរាជសារនេះបង្ហាញយើងថា ព្រះជាម្ចាស់ពុំមានព្រះហឫទ័យប្រណីសណ្តោសចំពោះការជិះជាន់អ្នកក្រ និងការកេងប្រវ័ញ្ចរបស់ពួកអ្នកមានទេ។*

❖ សន្និដ្ឋាន :

បន្ទាប់ពីបញ្ចូលចំលើយគ្រប់ការសិក្សាទាំងបីផ្នែកនិងការពិភាក្សារួចមក សូមពិចារណាទៅលើសំនួរបញ្ចប់ខាងក្រោមនេះ :

១.តើយើងរៀនបានអ្វីខ្លះពីនគរព្រះ?

២.តើខ្ញុំត្រូវការផ្លាស់ប្តូរយ៉ាងណាដើម្បីបង្ហាញពីនគរព្រះអោយកាន់តែខ្លាំងថែមទៀតនៅក្នុងជីវិតរបស់ខ្ញុំ?

៣.ក្នុងនាមយើងជាក្រុមជំនុំ តើត្រូវការផ្លាស់ប្តូរបែបណាក្នុងគោលបំណងដើម្បីបង្ហាញពីនគរព្រះបន្ថែមទៀត?



## ការសិក្សាព្រះគម្ពីរ : រឿងរបស់លោកបាទីមេ

### ❖ សេចក្ដីផ្ដើម:

នេះជារឿងមួយដ៏មានសារសំខាន់ក្នុងការជួយអោយក្រុមជំនុំឆ្លុះបញ្ចាំងពីតួនាទីដ៏សំខាន់របស់ក្រុមជំនុំក្នុងការធ្វើការងារជាមួយជនក្រីក្រ ហើយនេះក៏ជារបៀបមួយនៃការថ្វាយបង្គំរបស់យើងដែរ ។

*សូមអានម៉ាកុស១០:៤៦-៥២*

ប្រសិនបើអោយអ្នកចូលរួមបានសំដែងរឿងនេះឡើងគឺរឹតតែប្រសើរ ។

សំនួរ :

១.តើអ្នកសង្កេតឃើញមានការផ្លាស់ប្ដូរអ្វីខ្លះនៅក្នុងអាកប្បកិរិយារបស់ហ្វូងមហាជនចំពោះលោកបាទីមេ ?

២.តើអ្វីជាមូលហេតុនៃការផ្លាស់ប្ដូរទាំងនេះ?

៣.ប្រសិនបើហ្វូងមហាជនទាំងនោះតំណាងអោយក្រុមជំនុំបច្ចុប្បន្ន តើអ្វីជាអាកប្បកិរិយាអវិជ្ជមានដែលក្រុមជំនុំមានចំពោះជនងាយរងគ្រោះ និងជនត្រូវគេបោះបង់ចោល?

៤.តើយើងអាចធ្វើអ្វីដើម្បីដោះស្រាយអាកប្បកិរិយាអវិជ្ជមានអស់ទាំងនេះ?



ចំនុចគន្លឹះនានាដែលជាលទ្ធផលចេញពីការពិភាក្សា :

១.ហ្វូងមហាជនជាតំណាងអោយក្រុមជំនុំហើយព្រះយេស៊ូគ្រីស្ទជំរុញអោយក្រុមជំនុំផ្ដោតការយកចិត្តទុកដាក់ទៅលើជនងាយរងគ្រោះ និងជនត្រូវគេបោះបង់ចោល ។

២.ព្រះយេស៊ូគ្រីស្ទប្រើហ្វូងមហាជនដើម្បីនាំលោកបាទីមេមកជិតទ្រង់ និងស្ថិតនៅកណ្ដាលហ្វូងមហាជន ។ ដូចគ្នានេះដែរ ក្រុមជំនុំត្រូវបានត្រាស់ហៅមកដើម្បីអោយពួកគេយកជនងាយរងគ្រោះ និងជនត្រូវគេបោះបង់ធ្វើជាចំនុចស្នូលនៃព័ន្ធកិច្ចរបស់ខ្លួន ។

៣.របៀបដែលព្រះយេស៊ូគ្រីស្ទឆ្លើយតបចំពោះលោកបាទីមេគឺជាការស្វែងរកតម្រូវការរបស់គាត់ និងការឆ្លើយតបតាមតំរូវការនោះ ព្រមទាំងការពាក់ព័ន្ធរបស់អ្នកដទៃទៀតនៅក្នុងការឆ្លើយតបចំពោះតម្រូវការទាំងអស់នោះ ។

✲ ជំហានទី៤ : សកម្មភាពអបអរ-ការអបអរចំពោះប្រវត្តិរបស់យើង

គោលបំណង:

ដើម្បីពិនិត្យមើលឡើងវិញនូវព្រឹត្តិការណ៍សំខាន់ៗដែលបានកែច្នៃទាំងក្រុមជំនុំរបស់យើង និងសហគមន៍មូលដ្ឋាន ព្រមទាំងពិនិត្យមើលអ្វីដែលយើងអាចយកមកប្រើប្រាស់បានសម្រាប់អនាគត ។



ការណែនាំតាមជំហាន:

១.យកក្រដាសវែងមួយផ្ទាំងទៅក្រាលនៅលើតុ ហើយអ្នកចូលរួមអាចដើរជុំវិញតុនោះបាន ។
២.គូសបន្ទាត់មួយនៅលើក្រដាសនោះពីម្ខាងទៅម្ខាង បន្ទាប់មកកំណត់ពេលវេលានៅលើបន្ទាត់នោះ ។
៣.អ្នកចូលរួមត្រូវសរសេរព្រឹត្តិការណ៍សំខាន់ៗតាមលំដាប់ពេលវេលានៅលើបន្ទាត់នោះ ។
៤.សរសេរព្រឹត្តិការណ៍ល្អពីលើបន្ទាត់និងព្រឹត្តិការណ៍មិនល្អពីក្រោមបន្ទាត់ ដោយប្រើសំនួរខាងក្រោម ព្រមទាំងកំណត់នូវមេរៀនដែលអាចរៀនបានសម្រាប់អនាគត ។

សំនួរ :
១-តើអ្វីដែលបាននិងកំពុងធ្វើល្អបំផុតក្នុងពេលនេះ? ហេតុអ្វី?
២-តើអ្វីដែលលំបាកបំផុត?
៣-តើយើងអាចធ្វើអ្វីសម្រាប់អនាគត?

ការណែនាំនានា:

១.អ្នកអាចគូររូបភាពនៅលើបន្ទាត់នោះដើម្បីអោយមើលទៅកាន់តែច្បាស់លាស់ និងទាក់ទាញ ។
២.ប្រសិនបើក្នុងក្រុមមានសមាជិកច្រើន (លើសពី១០នាក់) ត្រូវប្រាកដថាម្នាក់ៗអាចមើលឃើញពីការកំណត់ពេលវេលានិងអាចចូលរួមចំណែកបាន ។ យើងអាចបែងចែកជា២ឬ៣ក្រុមនៅក្នុងការពិភាក្សានេះ រួចហើយយកមកប្រៀបធៀបគ្នានៅពេលបញ្ចប់វគ្គ ។
៣.ជាការមួយសំខាន់ដែលអ្នកសម្របសម្រួលត្រូវរក្សាការពិភាក្សាអោយមានដំណើរការប្រព្រឹត្តទៅជានិច្ច ហើយនឹងមិនអោយជាប់គាំងនៅតែលើព្រឹត្តិការណ៍ណាមួយឡើយ ។ អ្វីដែលសំខាន់មួយទៀតនោះគឺត្រូវស្វែងរកអោយឃើញនូវមូលហេតុដែលព្រឹត្តិការណ៍នោះជាព្រឹត្តិការណ៍ល្អឬមិនល្អ ព្រមទាំងមេរៀន និងការយល់ដឹងផ្សេងៗដែលពួកគេទទួលបានដើម្បីយកទៅអនុវត្តនាពេលអនាគត ។

✳ **ជំហានទី៥: រៀបចំក្រុមសម្របសម្រួលក្រុមជំនុំ (ក.ស.ក) (**Church Co-ordination Group**)**

ក្រុមសម្របសម្រួលក្រុមជំនុំ (ក.ស.ក) គឺជាក្រុមដែលមានចិត្តក្នុងការជួយដល់អ្នកសម្របសំម្រួលក្នុងពេលដែលជួបជុំគ្នាបង្កើតនិមិត្តនិងកសាងគម្រោងផែនការក្រុមជំនុំនិងអង្កេតមើលជាបន្ត ។អ្នកសម្របសម្រួលត្រូវប្រាដកថា គ្រប់ៗគ្នាដែលស្ថិតក្នុងក្រុមខាងលើ ពួកគេបានដឹងច្បាស់ពីទីកន្លែង ពេលវេលានៃការជួបជុំនិងសកម្មភាពនានាដែលត្រូវធ្វើបន្តបន្ទាប់ ។

បទពិសោធន៍នៃការកសាងនិងដំណើរការគម្រោងគឺជាឱកាសដ៏ល្អមួយសំរាប់ក្រុមសម្របសម្រួលដើម្បីធ្វើអោយជំនាញនានានិងភាពប៉ិនប្រសប់អោយកាន់តែចំរើនឡើងដែលពួកគេអាចយកទៅប្រើប្រាស់ក្នុងសហគមន៍កាន់តែទូលាយឡើងៗនៅក្នុងដំណាក់កាលជាបន្តបន្ទាប់ទៀតរបស់អូម៉ូចា ។



ជំហានគន្លឹះនានាសំរាប់ការជ្រើសរើសនិងហ្វឹកហ្វឺនក្រុមសម្របសម្រួលក្រុមជំនុំ :

១.ក្រុមជំនុំត្រូវរៀបចំលក្ខណ្ឌមួយចំនួនក្នុងការជ្រើស (ក.ស.ក) ដោយមានការយល់ស្របពីសមាជិកក្រុមជំនុំ ។ លក្ខណ្ឌនេះត្រូវរួមបញ្ចូលចំនុចមួយចំនួនដូចខាងក្រោម:

- -តើពួកគេទទួលការគោរពពីសមាជិកដទៃទៀតក្នុងក្រុមជំនុំដែរឬទេ?
- -តើសមត្ថភាព និងឆន្ទៈរបស់ពួកគេត្រូវបានគេទទួលស្គាល់ដែរឬទេ?
- -តើពួកគេមានបំនិនប្រសប់ដែរឬទេ?

២.តើយើងអាចធ្វើការអញ្ជើញឬក៏អោយពួកគេស្ម័គ្រចិត្តចូលក្នុងក្រុមនេះបានដែរឬយ៉ាណា? សូមមើលការសិក្សាព្រះគម្ពីរក្នុងទំព័រទី៣0 អោយគេពិចារណាយកវិធីសាស្រ្តមួយដ៏ល្អបំផុតដើម្បីជ្រើសរើសមនុស្ស ។

៣.នៅពេលដែលក្រុមត្រូវបានជ្រើសរើសរួចរាល់ហើយ ត្រូវពន្យល់សមាជិកម្នាក់អោយបានច្បាស់ពីតួនាទីរបស់ខ្លួននៅក្នុងក្រុមព្រមទាំងរៀបចំទាំងអស់គ្នានូវ ពេលវេលា ទីកន្លែងមួយសំរាប់ការប្រជុំគ្នាជាទៀងទាត់ ។

៤.រៀបចំវគ្គមួយដើម្បីបង្ហាញ និងណែនាំពួកគេអោយកាន់តែលំអិតថែមទៀតអំពីរបៀបដែលអូម៉ូចាអនុវត្តការងារ និងតួនាទីរបស់ (ក.ស.ក) ។សូមមើលឯកសារយោងស្តីអណពីទិដ្ឋភាពទូទៅនៃអូម៉ូចាក្នុងទំព័រ៣-៧និងជំនាញសម្របសម្រួលក្នុងទំព័រ១០-១៤ ។

៥.ពន្យល់ពីតួនាទីរបស់ពួកគេក្នុងការជួយក្រុមជំនុំអោយអនុវត្តគម្រោងតូចៗ។ ការរៀបចំគម្រោងតូចៗ នេះនឹងមានដំណើរការល្អនៅពេលក្រុមជំនុំធ្វើការសហការរៀបចំជាមួយសហគមន៍។

៦.អ្វីដែលសំខាន់នោះគឺពួកគេធ្វើការជាប់ជាមួយអ្នកសម្របសម្រួលនៅក្នុងការរៀបចំផែនការសកម្មភាព និងធ្វើការរំលឹកឡើងវិញពីរបៀបអនុវត្តសកម្មភាពទាំងនោះ។

❖ តួនាទីរបស់ (ក.ស.ក)

- សូមពួកគេអោយរៀបចំនូវការប្រជុំនានាជាមួយក្រុមជំនុំ។
- បញ្ចូលពួកគេទៅក្នុងក្រុមសម្របសម្រួលតូចៗ។
- សូមពួកគេអោយសរសេរទុកនូវការរៀនសូត្រនិងចំនុចគន្លឹះនានាដែលបាន ពីការពិភាក្សាផ្សេងៗ។

ការសិក្សាព្រះគម្ពីរ :ការជ្រើសរើសអ្នកត្រួតត្រាការងារទាំង០៧នាក់

*កិច្ចការ៦:១-៧*

អ្នកអាចឃើញនូវចំនុចខ្លះដែលអាចជួយធ្វើសកម្មភាពតាមរយៈរឿង ដែលអាចជួយពួកគេអោយមើលឃើញអំពីអ្វីដែលនឹងកើតឡើង។



១.តើមានអ្វីកើតឡើងក្នុងរឿងនេះ?

២.តើមានបញ្ហាអ្វីដែលបានកើតឡើង?តើអ្នកគិតថាបញ្ហានេះអាចកើតមានឡើងនៅក្នុងសហគមន៍របស់អ្នកដែរឬទេ?

៣.តើសាវ័កទាំង១២សំរេចចិត្តធ្វើអ្វីខ្លះ?តើអ្នកគិតថាវាជាការសំរេចចិត្តល្អដែរឬទេ? ហេតុអ្វី? ហើយហេតុអ្វីមិនល្អ ?

៤.តើក្រុមថ្មីដែលមាន៧នាក់ដែលទទួលខុសត្រូវក្នុងការថែរក្សាមេម៉ាយគួរជ្រើសរើសដោយអ្នកណា?តើសាវ័កទាំង១២បានផ្តល់ដំបូន្មានអ្វីខ្លះអំពីប្រភេទមនុស្សដែលគួរជ្រើសរើស?

៥.តើរឿងនេះមានទាក់ទងទៅនឹងអូម៉ូចានិងសហគមន៍របស់អ្នកព្រមទាំងក្រុមជំនុំរបស់អ្នកដូចម្តេចដែរ?

៦.តើមានតំរូវការថ្មីសំរាប់ការទទួលខុសត្រូវថ្មីដែលកើតពីអូម៉ូចាដែលគួរចែកចាយក្នុងចំនោមមនុស្សច្រើ

នជាងនេះដែរឬទេ?

ប្រសិនបើមានៈ

-តើគួរធ្វើសំរេចចិត្តបែបណា?

-តើអ្នកណាគួរតែជ្រើសរើស?

-តើគុណភាពអ្វីខ្លះដែលមនុស្សថ្មីទាំងនេះគួរតែមាន?

## ផ្នែកទី២ : ការប្រើប្រាស់ធនធាននានារបស់យើង

- គោលបំណងៈ

ដើម្បីអោយសមាជិកក្រុមជំនុំទទួលស្គាល់ថា បញ្ហានិងផលលំបាកនានាអាចដោះស្រាយបានតាមរយៈធនធានផ្ទាល់របស់ខ្លួន ។

- ជំហានគន្លឹះនានាៈ

១.ប្រើល្បែងបង្កើនថាមពលដើម្បីនាំអ្នកចូលរួមអោយគិតអំពីការធ្វើការរួមគ្នាដោយប្រើប្រាស់អ្វីដែលខ្លួនមាន ។

២.ធ្វើការសិក្សាពីព្រះគម្ពីរ និងឆ្លុះបញ្ចាំងពីអ្វីដែលពួកគេកំពុងនិយាយទាក់ទងទៅនឹងការប្រើប្រាស់ធនធាននានា ។ សូមជ្រើសរើសប្រធានបទណាដែលសមស្របសម្រាប់ក្រុមរបស់អ្នក ។

៣.ធ្វើសកម្មភាពអបអរដើម្បីឆ្លុះបញ្ចាំងពីធនធានដែលក្រុមជំនុំមាន យកល្អកត់ត្រាពតិមានដែលប្រមូលបានដោយប្រើជាតារាង ។

៤.គិតអំពីតំរូវការនានានិងធនធានផ្សេងៗក្នុងក្រុមជំនុំដោយកត់ត្រាដាក់ក្នុងតារាងមួយ ។



✳ ជំហានទី១ : ការបង្កើថាមពល-ល្បែងតភ្ជាប់ខ្សែអោយបានវែងបំផុត

នេះគឺជាសកម្មភាពដ៏ល្អមួយក្នុងការប្រមូលក្រុមអោយគិតអំពីអ្វីដែលពួកគេអាចធ្វើបានជាមួយនឹងធនធាននានាដែលពួកគេមាន ។ល្បែងនេះអាចបង្កើតភាពសប្បាយរីករាយនិងធ្វើអោយអ្នកអស់សំណើចដោយសាររបស់របរដែលគេប្រើ ព្រមទាំងផ្តល់អោយអ្នកនូវមេរៀនដែលមានប្រយោជន៍ជាច្រើន ។

១.អោយក្រុមបែងចែកជាពីរជួរដែលជួរនីមួយៗមានចំនួនមនុស្សស្មើរៗគ្នា ។

២.ពន្យល់ពួកគេថា ពួកគេអាចប្រើប្រាស់របស់របរទាំងឡាយដែលនៅជាប់ជាមួយខ្លួនគេតធ្វើជាខ្សែអោយបានវែងបំផុតដែលគេអាចធ្វើបានដែលមានដូចជា ( ខ្សែទ្រនាប់ជើង ខ្សែក្រវាត់ អាវយឺត...ល..) ។



៣.គ្រប់ៗគ្នាដែលនៅក្នុងក្រុមត្រូវជួយរកមើលគ្នាទៅវិញទៅមកនូវរបស់របរទាំងឡាយណាដែលនៅលើខ្លួនឬនៅលើសំលៀកបំពាក់ដែលអាចយកទៅប្រើបាន ។

៤.ក្រុមដែលឈ្នះគឺជាក្រុមដែលបានតខ្សែបានវែងជាងគេបំផុត ។

- សំនួរផ្សេងៗ:

១-តើអ្វីទៅជាប្រវែងដ៏វែងដែលពួកគេបានតជាខ្សែតាមលទ្ធភាពដែលគេអាចធ្វើទៅបាន ?

២-តើអ្វីខ្លះជាឧបសគ្គដែលរារាំងមិនអោយគេចែកចាយនូវអ្វីដែលគេមាន ?

៤-តើល្បែងនេះបានបង្រៀនយើងយ៉ាងណាស្តីពីការប្រើប្រាស់ធនធានទាំងឡាយដែលយើងមាន ?

- ចំនុចនានាដែលរៀនបានដើម្បីលើកយកមកពិភាក្សាក្នុងក្រុមមាន:

  -ល្បែងនេះគឺជាល្បែងដែលធ្វើអោយយើងភ្ញាក់ផ្អើល ដោយព្រោះតែយើងអាចបញ្ចប់បានដោយគ្រាន់តែប្រើប្រាស់នូវសំភារះផ្សេងៗដែលយើងមានតែប៉ុណ្ណោះ ។

  -ជួនកាលស្ថានភាពលំបាកៗជាច្រើនធ្វើអោយភាពជាអ្នកដឹកនាំពីធម្មជាតិរបស់យើងលេចចេញមក ។

  -នៅពេលដែលមនុស្សមាននិមិត្តច្បាស់លាស់ពីអ្វីដែលជាតំរូវការនានា ពួកគេនឹងក្លាយទៅជាអ្នកដែលមានកំលាំងនិងមានចំណង់ចង់ធ្វើការងារនោះថែមទៀត ។

  -ស្ថានភាពលំបាកនានាអាចបង្កើតអោយមានគំនិតឆ្នៃប្រឌិត ។ជាឧទាហរណ៍ ពួកគេអាចសំរេចចិត្តដេកទៅលើដីដើម្បីតធ្វើជាខ្សែអោយបានវែងឬក៏ប្រើប្រាស់សំលៀកបំពាក់និងឧបករណ៍ផ្សេងៗ ។

  -ពេលដែលជួបការលំបាកក្នុងការលេងល្បែងនេះ មានមនុស្សខ្លះអាចមានអារម្មណ៏ថាពិបាកលេងហើយពេលខ្លះគេសុខចិត្តលះបង់ចោលនូវធនធានដែលគេមានដើម្បីអោយកាលំបាកនិងអារម្មណ៏តានតឹងនោះបានល្អឡើងវិញ ។



✴ **ជំហានទី២ : ការសិក្សាព្រះគម្ពីរ**

រឿង ការរស់ឡើងវិញរបស់ឡាសារ :

សូមអានទូវសាច់រឿងទាំងមូល (យ៉ូហាន១១:១-៤៤) ឬក៏ខ្លឹមសារគន្លឹះសម្រាប់ការសិក្សានេះក្នុង (យ៉ូហាន១១:១-៣, ១៧, ៣២-៤៤) ។ ជាការមួយរិតតែប្រសើរប្រសិនបើអោយអ្នកចូលរួមសំដែងរឿងនេះដែលអាចធ្វើអោយពួកគាត់ឃើញកាន់តែច្បាស់នូវអ្វីដែលកំពុងកើតឡើង ។



១-តើមានអ្វីកើតឡើងនៅក្នុងរឿងនេះ ? សូមកត់ត្រាពីមនុស្សដែលពាក់ព័ន្ធនៅក្នុងរឿងនេះព្រមទាំងបញ្ជាក់ពីកិច្ចការដែលពួកគេធ្វើផង ។

២-តើព្រះយេស៊ូគ្រីស្ទជាប់ពាក់ព័ន្ធនឹងអ្នកដទៃយ៉ាងណានៅក្នុងអព្ភូតហេតុដែលបានកើតឡើងនេះ?

៣-ព្រះយេស៊ូគ្រីស្ទអាចសំដែងអព្ភូតហេតុដោយអង្គឯង ហេតុអ្វីបានជាអ្នកគិតថាព្រះអង្គជ្រើសយកជំរើសពាក់ព័ន្ធនឹងអ្នកដទៃ?

៤-តើរឿងនេះប្រាប់យើងពីអ្វីទាក់ទងទៅនឹងព្រះយេស៊ូគ្រីស្ទនិងនគរព្រះ ? តើរឿងនេះប្រាប់យើងនូវអ្វីខ្លះអំពីខ្លួនយើង?

***ចំនុចគន្លឹះ*** *: ព្រះយេស៊ូគ្រីស្ទជាប់ពាក់ព័ន្ធនឹងមនុស្សដទៃនៅក្នុងការរស់ឡើងវិញរបស់ឡាសារ មានដូចជា ពួកគេបានបង្ហាញព្រះយេស៊ូគ្រីស្ទអំពីផ្នូររបស់ឡាសារ ពួកគេប្រមៀលដុំថ្មនៅមាត់ផ្នូរចេញ ពួកគេស្រាយក្រណាត់រុំសាកសពចេញ ។ ព្រះយេស៊ូគ្រីស្ទសព្វព្រះហឫទ័យបង្ហាញថា មិនមែនគ្រាន់តែត្រូវការអំនាច របស់ព្រះជាម្ចាស់ដែលឈ្នះលើសេចក្តីស្លាប់នោះទេ ប៉ុន្តែថែមទាំងត្រូវការមនុស្សផ្សេងៗដែលពួកគេមានធនធានអាច ផ្តល់ និងប្រើប្រាស់សម្រាប់បំពេញកិច្ចការរបស់ព្រះជាម្ចាស់ ។*

## រឿង អេលីសេ និងភាជនៈ

*សូមអាន២ពង្សាវតាក្សត្រ៤:១-៧*



- ចូរពិភាក្សាសំនួរដូចខាងក្រោម :

១.តើអ្វីជាព្រឹត្តិការណ៍សំខាន់នៅក្នុងរឿងនេះ?

២.តើអ្នកណាជាអ្នកទទួលខុសត្រូវ?

៣.តើធនធានអ្វីខ្លះដែលស្ត្រីមេម៉ាយ និងកូនរបស់គាត់មាន?

៤.តើយើងអាចរៀនបានអ្វីពីរឿងនេះ ដើម្បីយកទៅអនុវត្តសម្រាប់ជំរុញអោយសហគមន៍អាចប្រើប្រាស់នូវអ្វីដែលខ្លួនមានក្នុងការយកជ័យជំនះលើ ភាពក្រីក្រ?

៥.សូមក្រឡេកមើលតារាងខាងក្រោម បន្ទាប់មកអោយអ្នកចូលរួមទាំងអស់បង្កើតតារាងនេះតាមគំនិតរបស់ពួកគេដែលស្រដៀងទៅនឹងតារាងនេះ ។ នេះគឺជាវិធីមួយដ៏ល្អក្នុងការណែនាំពីជំនាញរៀបចំផែនការបែបសាមញ្ញៗដែលពួកគាត់អាចប្រើសម្រាប់រៀបចំផែនការរបស់ក្រុមជំនុំ ឬគម្រោងអភិវឌ្ឍន៍សហគមន៍ដោយប្រើប្រាស់ធនធានដែលពួកគាត់មាន ។

| **តម្រូវការរបស់ស្ត្រីមេម៉ាយ** | **ធនធានដែលស្ត្រីមេម៉ាយមាន** |
|---|---|
| -សងបំណុលដែលប្តីគាត់ជំពាក់គេ | -ប្រេងបន្តិចបន្តួច |
| -ការពារកូនៗពីការលក់ធ្វើជាទាសករ ដើម្បីសងបំណុលគេ | -ពាងទទេ |
| | -ប្រាជ្ញានៃអេលីយ៉ា |
| -ប្រាក់ចំណូលសម្រាប់អនាគត | -ការអធិស្ឋាន |
| | -កំលាំងពលកម្មគ្រួសារ |

***ចំនុចគន្លឹះ*** *: ជាមួយជំនួយរបស់ព្រះ ប្រសិនបើយើងមានចិត្តចង់ចែករំលែកនូវធនធានដែលយើងមានទៅកាន់ អ្នកទុរគត៌និងសហគមន៍ដែលយើងរស់នៅនោះនឹងមានការផ្លាស់ប្តូរជាមិនខាន។*

- ការប្រទានអាហារដល់មនុស្សប្រាំពាន់នាក់:

*សូមអាន ម៉ាកុស៦:៣០-៤៤*



○ចូរធ្វើការពិភាក្សាទៅលើសំនួរខាងក្រោមនិងស្វែងរកចំលើយដោយសរសេរនៅលើក្តារខៀនឬផ្ទាំងក្រដាសធំមួយ។

១-តើនរណាខ្លះជាតួអង្គសំខាន់នៅក្នុងរឿងនេះ?

២-តើពួកគេធ្វើសកម្មភាពសំខាន់ៗអ្វីខ្លះ?

៣-តើអ្វីជាតម្រូវការនៃរឿងនេះ? តើមានធនធានអ្វីខ្លះ?

○បន្ទាប់មកបែងចែកជាពីរឬបីនាក់ក្នុងមួយក្រុមហើយអោយឆ្លើយនូវសំនួរទាំងឡាយនេះ :

៤-តើដំណាក់កាលអ្វីខ្លះដែលព្រះយេស៊ូគ្រីស្ទប្រើដើម្បីសំដែងការអស្ចារ្យ។

៥-នៅក្នុងរឿងនេះ តើព្រះយេស៊ូគ្រីស្ទផ្តោតទៅលើអ្វីជាសំខាន់? តើពួកសិស្សផ្តោតទៅលើអ្វីជាសំខាន់?

៦-តើគេប្រើប្រាស់ធនធានតាមរបៀបយ៉ាងណាដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងដែលកើតមានឡើង?

○ ជាចុងក្រោយ សូមអោយគេត្រឡប់មកវិញហើយធ្វើការពិភាក្សាជាក្រុមធំម្តង:

៧-ហេតុអ្វីបានជាអ្នកគិតថា ព្រះយេស៊ូគ្រីស្ទប្រើជំហានទាំងនោះ ? សូមសរសេរចុះនូវចំលើយនានា។

៨-តើព្រះអង្គសំដែងការអស្ចារ្យទាំងនេះដោយមានលក្ខណៈខុសៗគ្នាតាមរបៀបណា? ហេតុអ្វីបានជាព្រះអង្គមិនសំដែងអព្ភូតហេតុអស្ចារ្យនេះអោយមានលក្ខណៈផ្សេងគ្នា?

៩-តើសារនេះប្រាប់អ្វីដល់យើងទាក់ទងទៅនឹងវិធីសាស្រ្តដែលយើងគួរប្រើក្នុងការសម្របសម្រួលអោយក្រុមជំនុំ និង សហគមន៍ឆ្លើយតបនឹងតម្រូវការរបស់ខ្លួន?

១០-តើការអស្ចារ្យមានលក្ខណៈដូចម្តេចចំពោះសហគមន៍របស់យើង? ចូរគិតអំពីធនធាននានាដែលយើងត្រូវថ្វាយចំពោះព្រះជាម្ចាស់ ។

ចូរអោយអ្នកចូលរួមបំពេញតារាងខាងក្រោមដោយផ្អែកលើហ្វូងមនុស្សដែលចេញពីការសិក្សាព្រះគម្ពីរ ៖

| តម្រូវការរបស់ពួកគេ | ធនធានរបស់ពួកគេ |
| --- | --- |
| | |

តារាងនេះគួរមានលក្ខណៈដូចខាងក្រោម :

| **តម្រូវការរបស់ពួកគេ** | **ធនធានរបស់ពួកគេ** |
|---|---|
| -មហាជនឃ្លានអាហារ | -នំប៉័ង៥ដុំ ត្រី២កន្ទុយ<br>-អំណាចរបស់ព្រះជាម្ចាស់ |
| -ត្រូវរៀបចំហ្វូងមហាជនអោយមានសណ្តាប់ធ្នាប់ដើម្បីចែកអាហារ | -ពួកសិស្សដែលរៀបចំហ្វូងមហាជនអោយមានសណ្តាប់ធ្នាប់<br>-ល្អីទទេ |
| -អាហារត្រូវរៀបចំអោយមានសណ្តាប់ធ្នាប់ | -ពួកសិស្សដែលត្រូវចែកអាហារ<br>-ព្រះយេស៊ូគ្រីស្ទ |
| -ការបង្រៀនផ្នែកព្រលឹងវិញ្ញាណ | |

***ចំនុចគន្លឹះ*** *: ព្រះទ្រង់ចង់ប្រើយើងនិងធនធានទាំងឡាយរបស់យើងដើម្បីនាំការផ្លាស់ប្តូរទាំងនៅក្នុងជីវិតរស់នៅរបស់យើងនិងជីវិតនៃសហគមន៍របស់យើង ។*

✲ **ជំហានទី៣ : សកម្មភាពអបអរ-ការអបអរចំពោះអ្វីដែលយើងមាន**

គោលបំណង:

ដើម្បីធ្វើអោយអ្នកចូលរួម/សមាជិកក្រុមជំនុំនិងសហគមន៍ដឹងយ៉ាងច្បាស់ពីលទ្ធភាពដែលពួកគេមានក្នុងការនាំមកនូវការផ្លាស់ប្តូរនិងការរីកចំរើនដល់សហគមន៍។



លំនាំជាជំហានៗ:

១-បែងចែកជាក្រុមតូច១ និងពិភាក្សាទៅលើធនធាន អំណោយទាន និងអ្វី១ផ្សេងទៀតដែលមាននៅក្នុងក្រុមជំនុំនិងសហគមន៍។

២-ចប់ការពិភាក្សា ត្រូវប្រមូលលទ្ធផលនៃការពិភាក្សាដែលមាននិយាយនៅចំនុចទី១។

៣-យកលទ្ធផលទាំងនោះមកតំរៀបគ្នានៅលើកំរាលរាបស្មើជារាងឈើឆ្កាង បន្ទាប់មកធ្វើការពន្យល់នូវចំនុចដែលខុសគ្នា។

៤-អោយនរណាម្នាក់កត់ត្រាលទ្ធផលទាំងអស់នោះនៅលើក្រដាសធំ។

៥-នៅលើក្រដាសធំនេះត្រូវបែងចែកជា ជំនាញ ចំណេះដឹង និងបទពិសោធន៍ បន្ទាប់មកស្រង់លទ្ធផលខាងលើដាក់តាមប្រភេទទាំង៣នេះ។

៦-ធ្វើការពិភាក្សាជាក្រុមធំទៅលើសំនួរដូចខាងក្រោម :

ក) -នៅក្នុងក្រុមជំនុំ ឬសហគមន៍របស់យើង តើមានជំនាញនិងចំណេះដឹងអ្វីខ្លះដែលអាចប្រើដើម្បីនាំ-មកនូវការរីកចំរើនប្រសើរជាងមុន?

ខ) -តើយើងមានបទពិសោធន៍អ្វីខ្លះនៅក្នុងក្រុមជំនុំ ឬក្នុងសហគមន៍ដែលអាចចែករំលែកដល់អ្នកដទៃ?

សេចក្តីណែនាំនានា:

នៅក្នុងការពិភាក្សាអ្នកអាចរំលឹកអ្នកចូលរួមទាំងអស់ថា ធនធានដែលពួកគេមានរួមញ្ចូលទាំងចំណេះដឹង ពេលវេលានិងការអធិស្ឋាន។

នៅពេលអ្នកចូលរួមរៀបលទ្ធផលនៃការពិភាក្សាជារាងឈើឆ្កាងរួចហើយ អ្នកអាចចាក់បទភ្លេង ឬបទចំរៀងទុកអោយអ្នកចូលរួមពិចារណាបន្ថែមទៀតទៅលើធនធាន អំណោយទាន និងសមត្ថភាពផ្សេង១។

✳ ជំហានទី៤ ៖ វាយតម្លៃទៅលើអ្វីដែលក្រុមជំនុំមាន និងអ្វីដែលក្រុមជំនុំត្រូវការ

១-បំផុសគំនិតក្រុមធំទៅលើតម្រូវការនានាដែលក្រុមជំនុំកំពុងតែត្រូវការ បន្ទាប់មកជ្រើសរើសតម្រូវការជាអទិភាពចំនួន៣។

២-ចូរប្រើពតិមានខាងក្រោមនេះដើម្បីធ្វើការពិចារណាទៅលើធនធានផ្សេងៗដែលក្រុមជំនុំរបស់អ្នកមាន និងរបៀបប្រើប្រាស់ធនធានទាំងនោះដើម្បីដោះស្រាយនូវរាល់តម្រូវការផ្សេងៗដែលបានកំណត់នៅក្នុងក្រុមជំនុំ។



**-ធនធានធម្មជាតិនានា**

អនុផលនានានៃព្រៃឈើ ទឹក រ៉ែ



**-ធនធានមនុស្ស**

កំលាំងពលកម្ម ជំនាញ និងបទពិសោធន៍



**-ធនធានហិរញ្ញវត្ថុ**

ប្រាក់ សត្វ គ្រាប់ធញ្ញជាតិ ផលិតផលសម្រាប់លក់



**-ធនធានផ្នែកសាច់ឈាម**

អាគារ ផ្លូវ ស្ពាន អណ្តូងទឹក



**-ធនធានផ្នែកព្រលឹងវិញ្ញាណ**

ការអធិស្ឋាន ការថ្វាយបង្គំ ការតមអាហារ និងការសិក្សាព្រះគម្ពីរ

## ផ្នែកទី៣ ៖ ការផ្ដួចផ្ដើមគំនិតនៃក្រុមជំនុំមូលដ្ឋាន

❖ គោលបំណងនៃជំហានទី៣៖

ដើម្បីជួយអោយក្រុមជំនុំរៀបចំផែនការ និងអនុវត្តសកម្មភាពដើម្បីឆ្លើយតបទៅនឹងតម្រូវការនៅក្នុងក្រុមជំនុំដោយប្រើធនធានដែលខ្លួនមាន។

❖ ជំហានគន្លឹះនានា៖

១-លេងល្បែងបង្កើនថាមពលដោយប្រើប្រអប់ធំ។

២-សិក្សាព្រះគម្ពីរទៅលើប្រធានបទអំបិល និងពន្លឺ។

៣-ប្រើតារាងរួមនឹងលំហាត់ឡានតូចដើម្បីរៀបចំគម្រោងតូចមួយ។

៤-បង្កើតក្រុមអ្នកស្ម័គ្រចិត្តមួយក្រុមដើម្បីអនុវត្តគម្រោងនេះ។

៥-ពិនិត្យឡើងវិញនូវដំណើរការអនុវត្តគម្រោង។



**✳ ជំហានទី១ : ល្បែង-ប្រអប់ធំ**

គោលបំណង : ដើម្បីជួយអោយអ្នកចូលរួមអនុវត្តការដោះស្រាយបញ្ហាដោយប្រើធនធានក្នុងលក្ខណៈមានកំណត់ និងស្វែងរកពីរបៀបដែលធ្វើការជាមួយគ្នាជាក្រុមអោយមានប្រសិទ្ធិភាព ។

- សម្ភារៈដែលត្រូវការលេង :

-ខ្សែសម្រាប់ធ្វើជាទីធ្លាដែលមានផ្ទៃ ០៣ម៉ែត្រការ៉េ

-ខ្សែពួរប្រវែង៤ម៉ែត្រចំនួន៣កំណាត់

-ធុងទឹកធំមួយដាក់ទឹករួច មានចំណុះពី ៣-៥លីត្រ

-វត្ថុមួយចំនួនដែលធ្វើអោយមានការរំខានដល់ការអនុវត្តន៏ការងារដូចជាអំបោស ធុងសំរាមជាដើម ។

- ជំហានសំខាន់ៗ :

១.យកខ្សែមកធ្វើជាការ៉េដែលមានទំហំ ៣ម គុណនឹង ៣ម រួចដាក់ធុងដែលមានទឹកពេញនៅចំកណ្ដាល ។

២.ពន្យល់សមាជិកក្រុមថា ពួកគេត្រូវតែយកធុងទឹកចេញពីទីនោះដោយប្រើសម្ភារៈដែលគេផ្ដល់អោយ ។ ពួកគេមិនត្រូវដាក់ជើង ឬដៃចូលទៅក្នុង ឬពីលើការ៉េទេ ។គេត្រូវតែលើកធុងទឹកឡើងចេញពីការ៉េ មិនអោយអូសឬទាញធុងចេញទេ ។

៣.បែងចែកអ្នកចូលរួមជាពីរក្រុម បន្ទាប់មកផ្ដល់ពេលអោយក្រុមនីមួយៗចំនួនពីរនាទីដើម្បីអោយពួកគេរៀបចំដើម្បីសម្រេចកិច្ចការនេះ ។

៤.ក្រុមនីមួយៗត្រូវធ្វើកិច្ចការនេះម្ដងម្នាក់ៗដើម្បីសម្រេចកិច្ចការនេះ ។

នៅពេលពួកគេធ្វើបានជោគជ័យហើយ ត្រូវធ្វើវេទិកាសំនួរចំលើយ និងធ្វើការរំលឹកឡើងវិញពីអ្វីដែលពួកគេបានរៀន ។ ចំនុចពាក់ព័ន្ធអាចរួមបញ្ចូលទាំង :

-ការចូលរួមរបស់អ្នកគ្រប់គ្នានៅក្នុងការសម្រេចចិត្ត និងចែកចាយយោបល់

-បង្ហាញនូវជំនាញ និងបទពិសោធន៏នានា

-ការរៀបចំតួនាទី និងការរួមចំណែកផ្សេងៗ ។

*តើអ្វីជាចំនុចដូចគ្នារវាងល្បែងនេះ និងវិធីដែលក្រុមជំនុំអាចឆ្លើយតបទៅនឹងតម្រូវការរបស់ខ្លួន ?*

- សេចក្ដីណែនាំចុងក្រោយរបស់គ្រូ :

គេអាចប្រើខ្សែពួរពីរខ្សែដាក់សងខាងធុងទឹករួចចងចុងទាំងពីរនៃធុង ហើយទាញអោយតឹងដើម្បីអោយខ្សែរិតធុងទឹកអោយជាប់ ដូច្នេះគេអាចលើកធុងទឹកនោះឡើងបានដោយងាយស្រួល ។

**✲ ជំហានទី២ : ការសិក្សាព្រះគម្ពីរ : អំបិល និងពន្លឺ**



*សូមអានម៉ាថាយ៥:១៣-១៦*

រួចពិចារណាអំពីវិធីផ្សេងៗដែលអ្នកអាចធ្វើការពន្យល់ពីអត្ថន័យនៃខគម្ពីរនេះដោយ គូររូបបង្ហាញ (ឧទាហរណ៍ : ធ្វើអាហារមានរសជាតិពីរបែប មួយបែបដាក់អំបិល និងមួយទៀតមិនដាក់អំបិល ដាក់ទៀនដែលអុជរួចនៅក្រោមចាន) ។

១-តើអ្វីជាលក្ខណៈធម្មជាតិរបស់អំបិល ហើយគេប្រើអំបិលសម្រាប់ធ្វើអ្វី?

២-តើអ្នកគិតថាព្រះបន្ទូលរបស់ព្រះយេស៊ូគ្រីស្ទមានន័យដូចម្ដេច? នៅពេលទ្រង់មានបន្ទូលថា" អ្នករាល់គ្នាគឺជាអំបិលនៃផែនដី" តើអ្នក ឬក្រុមជំនុំរបស់អ្នកប្រព្រឹត្តយ៉ាងណាដើម្បីអោយដូចជា" អំបិល" នៅក្នុងសហគមន៍?

៣-តើមានអ្វីកើតឡើងនៅពេលដែលអំបិលបាត់ជាតិប្រៃ-ចំពោះអំបិល និងវត្ថុដែលត្រូវការអំបិល? តើអ្វីជាការលំបាកសម្រាប់យើងទាំងអស់គ្នាជាក្រុមជំនុំ?

៤-តើគេប្រើពន្លឺសម្រាប់ធ្វើអ្វី ?



៥-តើមានន័យដូចម្ដេចនៅពេលដែលព្រះយេស៊ូគ្រីស្ទមានបន្ទូលថា " ចូរអោយពន្លឺរបស់អ្នករាល់គ្នាបានភ្លឺនៅមុខមនុស្សលោក" ? តើអ្នក ឬក្រុមជំនុំរបស់អ្នកប្រព្រឹត្តយ៉ាងណាដើម្បីអោយដូចជា " ពន្លឺ" នៅក្នុងសហគមន៍?

៦-តើគំនិតថ្មីរបស់ក្រុមជំនុំអ្នក អាចជួយអ្នកអោយធ្វើជាអំបិលនិងជាពន្លឺក្នុងសហគមន៍ដោយរបៀបណា?



### ✳ ជំហានទី៣ : លំហាត់ដោយប្រើឡានក្រុងតូចមួយ

១.តើពួកយើងចង់ធ្វើអ្វី?

២.ហេតុអ្វីបានជាយើងចង់ធ្វើការនោះ?

៣. តើពួកយើងនឹងធ្វើដោយរបៀបណា?

៤.តើយើងមានធនធានអ្វីខ្លះ?



៧. តើអ្វីអាចជាឧបសគ្គនៅតាមផ្លូវ?

៥.តើនរណាខ្លះទៅធ្វើជាមួយយើង?

៦. តើអ្វីដែលអាចធ្វើអោយយើងថយក្រោយវិញ?

- គោលបំណង :

លំហាត់នេះជួយអោយអ្នកចូលរួមរៀបចំគម្រោងមួយដែលសមាជិកគ្រប់គ្នាអាចយល់ និងចងចាំបាន ។ ប្រសិនបើអាច ស្នើសុំអោយនរណាម្នាក់គូររូបឡានស្រដៀងនឹងឡានក្នុងរូបខាងលើ ឬថតចំលងរូបភាពនេះមកបង្ហាញ ហើយអ្នកចូលរួមគ្រប់គ្នាអាចមើលឃើញ ។ បន្ទាប់មកពិភាក្សាទៅលើសំនួរទាំងអស់ដែលនៅជុំវិញឡាន ។





- **គំរូនៃល្បែងឡានក្រុងតូច :**

*១.តើពួកយើងចង់ធ្វើអ្វី ?*

-គាំពារនិទាឃរដូវបានល្អ វានឹងផ្តល់អោយយើងវិញនូវទឹកស្អាត

*២.ហេតុអ្វីបានជាយើងចង់ធ្វើការនោះ ?*

-យើងដឹងថា ទឹកស្អាតផ្តល់អោយយើងនូវសុខភាពល្អនិងបញ្ចៀសយើងពីជំងឺផ្សេងៗ

*៣.តើយើងនឹងធ្វើដោយរបៀបណា ?*

-ហៅមនុស្សអោយមកប្រជុំគ្នាដើម្បីរៀបចំផែនការដែលយើងនឹងធ្វើ

-រៃអង្គាសថវិកាដើម្បីទិញស៊ីម៉ង់ត៍

-ប្រមែប្រមូលសំភារៈនានាដើម្បីសាងសង់កន្លែងការពារ

-សង់របងដើម្បីការពារកុំអោយសត្វដើរចេញពាសវាលពាសកាល

*៤.តើយើងមានធនធានអ្វីខ្លះ ?*

-ថ្ម និង ដីខ្សាច់

-មានថវិការមួយចំនួនតូច

-ក្រុមមនុស្សដែលអាចធ្វើការបាន

*៥.តើនរណាខ្លះទៅធ្វើជាមួយយើង ?*

-អ្នកដឹកនាំក្រុមជំនុំទាំងឡាយ

-សមាជិកពួកជំនុំទាំងអស់

-អ្នកដឹកនាំសហគមន៏ទាំងអស់

-ម្ចាស់បសុសត្វទាំងអស់

*៦.តើអ្វីដែលអាចធ្វើអោយយើងថយក្រោយវិញ ?*

-មនុស្សគ្រប់គ្នារវល់ពេកមកមិនកើត

-មិនមានការប្រឹក្សាគ្រប់គ្រាន់ពីបច្ចេកទេស

*៧.តើអ្វីដែលជាឧបសគ្គ ?*

-មានភ្លៀងធ្លាក់ខ្លាំង

-មានជំលោះនៅក្នុងក្រុម

-មិនបានដោះស្រាយបញ្ហានានាជាមួយកសិករដែលជាម្ចាស់សត្វផ្សេងៗ



- ការណែនាំសម្រាប់ការរៀបចំគម្រោង :

១.ត្រូវដឹងអោយបានច្បាស់លាស់ពីបញ្ហាដែលអ្នកនឹងស្វែងរកដំណោះស្រាយ ។
២.ត្រូវត្រួតពិនិត្យអោយបានច្បាស់លាស់ថា ក្រុមមនុស្សដែលអ្នកនឹងធ្វើការជាមួយមានជំនាញ បទពិសោធន៍ និងចំណេះដឹងគ្រប់គ្រាន់ដើម្បីអនុវត្តគម្រោងដែលពួកគេបានជ្រើសរើសដែរឬទេ។ ប្រសិនបើពួកគេមិនមាននូវអ្វីដែលរៀបរាប់ខាងលើទេ ត្រូវពិភាក្សាគ្នាថា តើពួកគេអាចទទួលបានសមត្ថភាពបន្ថែមនេះនៅកន្លែងណា ។
៣.នៅពេលប្រើប្រាស់លំហាត់នេះ ត្រូវអញ្ជើញអ្នកចូលរួមទាំងអស់អោយចូលរួមឆ្លើយសំនួរទាំងឡាយដែលមាន
៤.ប្រសិនបើក្រុមទាំងមូលធំពេក ត្រូវបែងចែកជាក្រុមតូចៗដែលមានសមាជិកពី ៤-៥នាក់ដើម្បីធ្វើការពិភាក្សាទៅលើសំនួរនានា ។ប្រសិនបើសំនួរនីមួយៗមានចំលើយច្រើនត្រូវអោយក្រុមជ្រើសរើសចំលើយដែលសំខាន់បំផុត ។

- ផែនការសកម្មភាពនានា :

នៅពេលលំហាត់ឡាននេះចប់ ចូរប្រើតារាងខាងក្រោមនេះដើម្បីបង្កើតផែនការសកម្មភាព ហើយចែកចាយទៅក្រុមជំនុំទាំងមូល ។

| ***ផែនការ*** | ***សេចក្តីលំអិត*** |
|---|---|
| តើយើងចង់ធ្វើអ្វី? | |
| ហេតុអ្វីបានជាយើងចង់ធ្វើការងារនេះ ? | |
| តើយើងនឹងធ្វើកិច្ចការនេះដោយរបៀបណា? | |
| តើយើងមានធនធានអ្វីខ្លះ? | |
| តើធនធានរបស់យើងជួយនូវមហន្តរាយយ៉ាងណាបើយើងប្រើប្រាស់វាហួសល្បត់នោះ ? | |
| តើយើងត្រូវការអ្នកណាខ្លះដើម្បីជួយយើង? | |
| តើអ្វីដែលអាចធ្វើអោយយើងថយក្រោយ? (នៅពេលគម្រោងចាប់ផ្តើមរួចហើយ) | |
| តើអ្វីខ្លះដែលជាឧបសគ្គនៅតាមផ្លូវរបស់យើង ? (នៅពេលដែលគម្រោងមួយបានចាប់ផ្តើម) | |
| តើយើងនឹងធ្វើកិច្ចការនេះនៅពេលណា? | |

✲ **ជំហានទី៤ : បង្កើតក្រុមតូចមួយដើម្បីអនុវត្តគម្រោង**

ជ្រើសរើសអ្នកដែលមានពេលវេលា មានកំលាំង និងទទួលការជំរុញទឹកចិត្តមិនបោះបង់ចោលការងារកណ្ដាលទី ។ ក្រុមនេះអាចជា ក្រុមសម្របសម្រួលក្រុមជំនុំ (ក.ស.ក) (CCG) រួមជាមួយនឹងមនុស្សពីរបីនាក់ថែមទៀត ដែលពួកគេជាអ្នកដែលមានជំនាញនិងចាប់អារម្មណ៏ក្នុងគំរោង ។ត្រូវប្រាកដថាពួកគេយល់ យ៉ាងច្បាស់នូវតួនាទីផ្សេងៗគ្នារបស់ពួកគេដែលត្រូវការក្នុងការបំពេញការ ងារ ។ ត្រូវចាប់យករាល់ឱកាសដើម្បីគាំទ្រ និងលើកទឹកចិត្តពួកគេ ។សេចក្ដីបន្ថែមសូមមើលក្នុង តំណាក់កាលទី៤ :ការធ្វើសកម្មភាព ។



✲ **ជំហានទី៥ : រំលឹកឡើងវិញនូវដំណើរការប្រព្រឹត្តទៅនៃគម្រោង**

ធ្វើការរំលឹកឡើងវិញនូវដំណើរការប្រព្រឹត្តទៅនៃគម្រោងដោយប្រើសំនួរដូចខាងក្រោមជាមួយនឹងក្រុមសម្របសម្រួលក្រុមជំនំុ និងជាមួយក្រុមជំនុំទាំងមូល ។ នេះគឺជាឱកាសមួយដ៏អស្ចារ្យសម្រាប់ក្រុមជំនុំក្នុងការអបអរនូវអ្វីដែលខ្លួនសម្រេចបាន និងអ្វីដែលខ្លួនបានរៀនពីកិច្ចការនេះ ។



## ផ្នែកទី៤.ការរៀនសូត្រនិងឆ្លុះបញ្ចាំង

ផ្នែកនេះគឺសំខាន់ដោយសារតំរូវការក្រុមជំនុំត្រូវបានរំលឹកនិងឆ្លុះបញ្ចាំងត្រឡប់លើអ្វីដែលបានធ្វើល្អនិងអ្វីដែលអាចធ្វើអោយបានប្រសើរជាងនេះទៅតាមមធ្យោបាយដែលយើងបានរៀននិងធ្វើការជាមួយគ្នា។

### ការឆ្លុះបញ្ចាំងលើផ្នែកទីមួយៈការបង្កើតនិមិត្តក្រុមជំនុំ

១.តើសកម្មភាពនានានិងការសិក្សាព្រះគម្ពីរផ្សេងៗ ជួយអោយក្រុមជំនុំមាននិមិត្តយ៉ាងម៉េចដែរសំរាប់សហគមន៏?

២.តើការសិក្សាព្រះគម្ពីរនិងសកម្មភាពណាមួយដែលមានប្រយោជន៏? ហេតុអ្វី?

៣.តើសមាជិកក្រុមជំនុំមានអារម្មណ៏យ៉ាងដូចម្តេចអំពីការទំនាក់ទំនងជាមួយសហគមន៏?



### ការឆ្លុះបញ្ចាំងផ្នែកទីពីរៈការប្រើធនធានរបស់យើង

១.តើសកម្មភាពនានានិងការសិក្សាព្រះគម្ពីរផ្សេងៗបានជួយក្រុមជំនុំនិងសមាជិកទទួលស្គាល់គុណតំលៃនៃការប្រើធនធានរបស់ខ្លួនយ៉ាងដូចម្តេចដែរ?

២.តើអ្វីជាមេរៀនសំខាន់ដែលពួកគេបានរៀនពីផ្នែកនេះ?



### ការឆ្លុះបញ្ចាំងផ្នែកទីបីៈគំនិតផ្តួចផ្តើមក្រុមជំនុំមូលដ្ឋាន

១.តើអ្វីខ្លះដែលសមាជិកក្រុមជំនុំបានរៀនពីការធ្វើការជាមួយគ្នាក្នុងការរៀបចំផែនការនិងដំណើរការគំរោង?

២.តើអ្វីខ្លះដែលក្រុមជំនុំគួរធ្វើអោយបានប្រសើរជាងនេះនៅពេលក្រោយ?

៣.តើអ្វីជាបទពិសោធន៏របស់សមាជិកក្រុមជំនុំក្នុងការរៀបចំគំរោងផ្ទាល់ខ្លួននិងរបៀបដែលពួកគេធ្វើការជាមួយសហគមន៏ក្នុងការបង្កើតគំរោងផ្សេងៗទៀត?



# ដំណាក់កាលទី២:



# ការបង្កើតនិមិត្តដល់សហគមន៍

## ទិដ្ឋភាពទូទៅនៃដំណាក់កាល២ ៈការបង្កើតនិមិត្តផល់សហគមន៍

### ❖ គោលបំណងនៃដំណាក់កាលនេះ :

ដើម្បីជួយទាំងក្រុមជំនុំនិងសហគមន៍ ឱ្យយល់ច្បាស់ពីស្ថានភាពរបស់ពួកគាត់ដ៏ប្រសើរ និងស្គាល់អ្វីជាចំនុចវិជ្ជមាននិងអវិជ្ជមានហើយនឹងដាក់អាទិភាពនូវរាល់តំរូវការសំខាន់ៗរបស់ពួកគាត់ ។

**ដំណាក់កាលទី ២ គឺបែងចែកជាប្រាំផ្នែកដូចនៅក្នុងរូបខាងក្រោម:**




នោះ គឺការសិក្សាព្រះគម្ពីរទាំងស្រុងតាមដំណាក់កាលនេះ ។ ពួកគេអាចប្រើប្រាស់មួយណាក៏បានៈ

- គ្រាន់តែជួយអោយក្រុមជំនុំគិតអំពី និងអធិដ្ឋានសំរាប់កម្មវិធី សាមគ្គី មុនពេលចាប់ផ្តើមធ្វើសកម្មភាពផ្សេងៗ ជាមួយសហគមន៍ទាំងមូល ។ ឬ
- ជាមួយក្រុមជំនុំ និងសហគមន៍ ដូចជាផ្លូវមួយដើម្បីជួយសហគមន៍ទាំងមូល ពិភាក្សាលើបញ្ហាជាច្រើន ។ ចំណុចតំរូវឱ្យធ្វើដោយការយល់ពីគាត់ និងគោរពចំពោះការយល់ឃើញនៃសេចក្តីជំនឿរបស់ពួកគាត់ ។

របៀបនៃការសិក្សាព្រះគម្ពីរ គឺវាអាស្រ័យទៅលើបរិបទ និងអ្វីដែលអ្នកមើលទៅឃើញថាសមរម្យ ។



## ផ្នែក ១: តើយើងគួរតែធ្វើការជាមួយសហគមន៍របស់យើងយ៉ាងដូចម្តេច?

### គោលបំណងនៃផ្នែកនេះ

ដើម្បីជួយឱ្យសហគមន៍គ្រាប់ៗគ្នាដឹង និងទទួលស្គាល់ពីតំរូវការរបស់ខ្លួន ហើយប្រើប្រាស់ធនធានផ្ទាល់ខ្លួនគាត់ម្នាក់ៗដើម្បីដោះស្រាយនូវរាល់តំរូវការរបស់ពួកគាត់។

### ជំហ៊ានគន្លឹះ

១. សាងទំនាក់ទំនងជាមួយសហគមន៍ និងអ្នកដឹកនាំសហគមន៍។

២. រៀបចំផែនការប្រជុំលើកដំបូងជាមួយសហគមន៍។

៣. នៅពេលចាប់ផ្តើមការប្រជុំ ត្រូវពន្យល់អំពីគោលបំណងនៃកម្មវិធីសាមគ្គី និងអត្ថប្រយោជន៍របស់វាទៅសហគមន៍ និងប្រសិនបើអាចធ្វើទៅបានបង្រៀនព្រះគម្ពីរ អំពីសាសន៍សាម៉ារីល្អម្នាក់។

៤. ប្រើប្រាស់សកម្មភាព "ការបង្កាត់ភ្លើង" និង"ការឆ្លងកាត់ទន្លេ" ដើម្បីបង្ហាញពីគោលការណ៍នៃការធ្វើការជាមួយគ្នាជាសហគមន៍។

៥. ធ្វើតារាងមួយអំពីរបៀបដែលអ្នកចង់ធ្វើការរួមគ្នាជាសហគមន៍។

៦. ជ្រើសរើស និងបង្ហាត់បង្រៀន ក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ (LCG = Local Co-ordination group)



## ❖ ជំហានទី ១: ការសាងទំនាក់ទំនងជាមួយសហគមន៍

ពេលដែលសាងទំនាក់ទំនងជាមួយសហគមន៍ វាគឺជាការសំខាន់ដែលមានភាពរួសរាយរាក់ទាក់តាមតែអាចធ្វើ ទៅបាន និងមានការចំណាយពេលជាមួយពួកគាត់ ដែលជាមូលដ្ឋានអាចអោយពួកគាត់ស្គាល់ នឹងទុកចិត្តអ្នក។ នៅ ពេលមានការប្រជុំជាមួយប្រជាជន វាគឺជាការល្អដែល:

- ធ្វើអាកប្បកិរិយាជាអ្នករៀនពីពួកគាត់ និងអនុញ្ញាតឱ្យពួកគាត់ធ្វើជាគ្រូរបស់យើងវិញ
- បង្ហាញអោយគេនូវអ្វីដែលគេមានមោតនភាព ប្រវត្តិសាស្ត្រ ស្នាដៃ និងសេចក្ដីប្រាថ្នារបស់ពួកគាត់
- ប្រសិនបើអាចទៅរួច រៀនភាសានៃការស្វាគមន៍ក្នុងតំបន់និងប្រយោគដែលពួកគាត់ធ្លាប់ប្រើឬក៏សុភាសិតផ្សេងៗ
- រកមើលថាតើអ្នកណាជាមនុស្សសំខាន់ និង មានឥទ្ធិពលបំផុតនៅក្នុងសហគមន៍
- រកមើលថាតើអ្វីដែលធ្វើឱ្យសហគមន៍មានកម្លាំង និងរំភើបសប្បាយរីករាយ។



## ❖ ជំហានទី ២: ការរៀបចំផែនការប្រជុំលើកដំបូងជាមួយសហគមន៍

- អញ្ជើញអ្នកដឹកនាំសហគមន៍មក និងមើលឃើញពីគំរោងរបស់ក្រុមជំនុំ ហើយនឹងពិភាក្សាជាមួយពួកគាត់នូវសំណួរខាងក្រោមនេះ:

  – តើគំរោងបានចាប់ផ្ដើមឡើងយ៉ាងដូចម្ដេច?
  – តើបានសម្រេចអ្វីខ្លះ?
  – តើពួកគាត់បានរៀនអ្វីខ្លះ?
  – តើអ្វីដែលអាចយកទៅអនុវត្តន៍ក្នុងសហគមន៍បាន?

- រៀបគំរោងប្រជុំជាមួយអ្នកដឹកនាំសហគមន៏ និងស្វែងរកទីកន្លែងណាមួយ ដែលអាចទទួលយកបានគ្រប់ គ្នា។ នេះមិនគួរនៅក្រុមជំនុំទេ។
- សមាជិកក្រុមជំនុំ និងអ្នកដឹកនាំសហគមន៏ គួរតែអញ្ជើញប្រជាជនមកប្រជុំរួមគ្នា (ជាពិសេស គឺអ្នកដែលងាយរងគ្រោះ ឬអ្នកដែលគេមិនយកចិត្តទុកដាក់)។
- វាពិតជាមានសារៈសំខាន់ ដែលមានការប្រាស្រ័យទាក់ទងគ្នា អំពីដំណើរការនៃការប្រើប្រាស់រូបភាព និងរឿងអោយបានច្រើនក្នុងការប្រជុំលើកដំបូងនៅក្នុងសហគមន៏។
- ប្រើប្រាស់រឿង នឹងសកម្មភាព ដើម្បីបង្ហាញហេតុការណ៏ពិតដែលអាចកើតមានក្នុងសហគមន៏របស់គេ រួមមាន ជំនាញផ្ទាល់ខ្លួនក្នុង ការអភិវឌ្ឍន៏ និងចំណុចសំខាន់ផ្សេងៗទៀតដោយធនធានផ្ទាល់របស់ពួកគាត់។ (ឧទាហរណ៏: ដោយការសិក្សាព្រះគម្ពីរអំពី "សាសន៏សាម៉ារីល្អម្នាក់" ឬក៏សកម្មភាព "ការឆ្លងកាត់ ទន្លេ")។
- សម្រួលដល់សហគមន៏ក្នុងការធ្វើការសម្រេចចិត្ត អំពីការចាប់ផ្តើមដំណើរការកម្មវិធី **សាមគ្គី**។
- ជួយសហគមន៏ឱ្យយល់ព្រម ពីរបៀបដែលពួកគាត់ចង់ធ្វើការរួមគ្នា ជាសហគមន៏ (មើលទំព័រ ៥៧)
- ពន្យល់ពីតួនាទី នៃក្រុមសម្របសម្រួលសហគមន៏ និងជួយសហគមន៏ដើម្បីជ្រើសរើសប្រជាជនមកធ្វើជាសមាជិកនៃក្រុមនេះ (មើលទំព័រ ៥៨)

## ❖ ជំហានទី ៣: សិក្សាព្រះគម្ពីរ

### សាសន៏សាម៉ារីល្អម្នាក់

អានលូកា ១០:២៥-៣៧

ជាការល្អត្រូវសម្តែងពីហេតុការណ៏នៅក្នុងរឿង ធ្វើដូច្នេះប្រជាជននឹងអាចយល់ថា តើរឿងនោះមានហេតុការណ៏អ្វីកើតឡើងខ្លះ?



១. តើមានអ្វី កើតឡើងនៅក្នុងរឿងនេះ? សរសេរឈ្មោះតួអង្គទាំងអស់ ដែលពាក់ព័ន្ធនៅក្នុងរឿងនេះ និង អ្វីដែលពួកគេធ្វើ។

២. តើអ្នកគិតយ៉ាងដូចម្តេច ចំពោះបំណងចិត្តរបស់បុគ្គលម្នាក់ៗ ចំពោះអ្វីដែលពួកគេធ្វើនៅក្នុងរឿងនេះ?

៣. តើអ្នកគិតថាតួអង្គនិមួយៗនៅក្នុងរឿងនេះ តំណាងឱ្យអ្នកណានៅក្នុងសហគមន៍របស់អ្នកថ្ងៃនេះ? តើអ្នកណាមួយដែលអ្នកគួរធ្វើតាម?

៤. ក្នុងសហគមន៍ តើនរណាជាអ្នកជិតខាងរបស់យើង? តើពួកគេមានតម្រូវការអ្វី? តើព្រះយេស៊ូគ្រីស្ត បានប្រាប់ពួកយើងឱ្យស្រឡាញ់អ្នកជិតខាងរបស់យើងដូចម្តេច?

៥. របៀបនៃការរស់នៅរបស់យើង ធ្វើឱ្យយើងមានការលំបាក ក្នុងការធ្វើការទំនាក់ទំនងជាមួយមនុស្ស ដ៏ទៃ ដែលមានអាយុខុសគ្នា កំរិតនៃការសិក្សាខុសគ្នា វណ្ណៈខុសគ្នា ក្រុមជនជាតិភាគតិច ឬអ្នកក្រីក្រ បំផុត។ តើយើងអាចយកឈ្នះអារម្មណ៍បែបនេះ ដោយរបៀបណា? តើយើងអាចជួយឱ្យកូនចៅរបស់យើងធំធាត់ឡើង តាមរបៀបមួយដែលអាចមានទំនាក់ទំនងល្អ ជាមួយមនុស្សគ្រប់ប្រភេទបាន ដោយរបៀបណា?

៦. តាមរយៈរឿងនេះ តើអ្នកគិតថាព្រះយេស៊ូគ្រិស្តត្រូវការអ្វីខ្លះពីក្រុមជំនុំ?

***ចំនុចគន្លឹះ: ក្រុមជំនុំមិនគួរបដិសេធតម្រូវការរបស់ប្រជាជនទេ ប៉ុន្តែគួរតែប្រើពេលវេលា និងធនធានផ្ទាល់ របស់ខ្លួន ដើម្បីជួយដល់អ្នកណាដែលកំពុងតែមានតម្រូវការ ទោះបីជាលំបាក ឬមានបញ្ហាកើតឡើងច្រើនក៏ដោយ។***

## ❖ ជំហានទី ៤: សកម្មភាពផ្សេងៗ

### ការចាប់ផ្តើមបង្កាត់ភ្លើង

នេះជាសកម្មភាពមួយដែលអ្នកអាចប្រើ នៅក្នុងការចាប់ផ្តើមធ្វើការប្រជុំជាមួយសហគមន៍ហើយចាប់ផ្តើមឱ្យពួកគាត់គិតអំពីការបង្កាត់ភ្លើង តើវាមានន័យដូចម្តេច ចំពោះការធ្វើការងារជាក្រុមនិងចំពោះការដោះស្រាយជាក្រុម? (ត្រូវយល់ពីសកម្មភាពនេះឱ្យបានច្បាស់ គឺប្រសើរនៅកន្លែងសុវត្ថិភាពហើយអណ្តាតភ្លើងមិនអាចរាល ដាល និងមិនបង្កឱ្យមានការខូចខាត)។

បន្ទាប់ពីស្វាគមន៍ប្រជាជន ធ្វើការណែនាំ និងពន្យល់ អ្នកដឹកនាំគួរតែសួរថាៈ"តើយើងអាចមានការបង្កាត់ភ្លើង នៅទីនេះក្នុងរយះពេល២ ៣នាទីបានទេ?"

នៅពេលដំបូង ប្រហែលជាធ្វើអោយពួកគាត់ ឆ្ងល់ ហើយយល់ច្រឡំថាអ្នកដឹកនាំតឹងរឹង។ បន្ទាប់មកមានម្នាក់ក្នុងចំណោមពួកគេ នឹងរត់ទៅយកអុស ឈើគូស ចង្ក្រាន។ ភ្លើង គឺឆេះយ៉ាងលឿន ហើយល្អនៅក្នុងពេលពីរបី នាទី។ បន្ទាប់មកទៀត វានឹងរលត់ទៅវិញ ទាល់តែមានមនុស្សពីរ បីនាក់យកអុសមកដាក់បន្ថែមទៀត វាអាចឆេះបន្តទៀតបាន។

ប្រើការអនុវត្តឧទាហរណ៍នេះនៅពេលចាប់ផ្តើមការពិភាក្សា ដើម្បីឱ្យដឹងថាអ្វីដែលយើងបានរៀនពីការបង្កាត់ ភ្លើងនេះ ។



**ការពិភាក្សា**

១. តើបានធនធានបង្កាត់ភ្លើងមកពីណា?

២. តើមាននរណាម្នាក់ថែទាំភ្លើងឬទេនៅពេលភ្លើងកំពុងតែឆេះខ្លាំងនោះ?

៣. តើនរណាជាអ្នកថែរក្សា "ភ្លើងនៃការអភិវឌ្ឍ" នៅក្នុងតំបន់របស់យើង? តើមានធនធានអ្វីខ្លះដែលអាចប្រើប្រាស់បានសំរាប់ការអភិវឌ្ឍ?

៤. តើក្រុម ឬអង្គការ ដូចជា "អ្នកដឹកនាំព្រះវិហារ អ្នកដឹកនាំសហគមន៍ អាជ្ញាធរ មានតួនាទីផ្សេងៗគ្នាអ្វីខ្លះក្នុងការរក្សាភ្លើងឱ្យនៅតែឆេះ?

៥. តើមានអង្គការ ឬក្រុមផ្សេងទៀត ដែលអាចជួយផ្តល់ការគាំទ្រ និងដឹកនាំសម្រាប់កិច្ចការនេះឬទេ?

៦. តើមានសមាជិកសហគមន៍ណាខ្លះ ដែលមិនបានចូលរួមប្រជុំ? តើអ្នកបានដឹងទេ ហេតុអ្វីបានជាពួកគាត់មិនបានមកចូលរួមប្រជុំ? តើអ្នកលើកទឹកចិត្តពួកគាត់ដោយរបៀបណា ដើម្បីឱ្យពួកគាត់ចូលរួមប្រជុំនៅថ្ងៃអនាគត?

**ការឆ្លងកាត់ទន្លេ**

នេះគឺជាការធ្វើត្រាប់តាម (ល្ខោនដែលស្ងៀមស្ងាត់មួយ) ជួយដល់សហគមន៍គិតអំពី តើគួរអភិវឌ្ឍន៍អ្វីមួយសំរាប់ពួកគេនិងមិនពឹងផ្អែកលើជំនួយសុខុមាលភាពពីខាងក្រៅ ។ សូមអ្នកចូលរួមបីនាក់អានតាមសកម្មភាពនិងធ្វើត្រាប់តាមល្ខោននេះ ។ បន្ទាប់មក ពួកគេអាចបង្ហាញវា ដល់ក្រុមដែលកំពុងតែសំរាក ហើយប្រើប្រាស់សំណួរមុនពេលបញ្ចប់ការពិភាក្សា ។

គូសបន្ទាត់ពីរឱ្យស្របគ្នានៅលើដី ឬកំរាលឃ្លាតពីគ្នាឱ្យឆ្ងាយបន្តិច ជាតំណាងឱ្យច្រាំងទន្លេទាំងសងខាង ។ អ្នកអាចប្រើខ្សែធ្វើជាច្រាំងទន្លេក៏បាន ប្រសិនបើអ្នកមិនចង់ប្រើដីស ។ ដាក់ក្រដាសតូចៗនៅចន្លោះគំនូរ នេះតំណាងឱ្យដុំថ្ម សម្រាប់ជាន់ដើរ ហើយដាក់ក្រដាសផ្ទាំងធំមួយផ្ទាំងតំណាងឱ្យកោះ ។



មនុស្សពីរនាក់ដើរទៅកាន់ទន្លេរកមើលកន្លែងសម្រាប់ឆ្លងទៅត្រើយម្ខាងទៀត ចរន្តទឹកហូរយ៉ាងខ្លាំង ដែលធ្វើឱ្យអ្នកទាំងពីរភ័យខ្លាចក្នុងការឆ្លង ។

មនុស្សម្នាក់ទៀតដើរទៅកាន់ទីនោះដែរ ហើយមើលពួកគេទាំងពីរ ។ គាត់បង្ហាញដុំថ្មសម្រាប់ដើរពីរលើដល់អ្នកទាំង ពីរ ។ គាត់លើទឹកចិត្តឱ្យអ្នកទាំងពីរដើរលើដុំថ្មទាំងនោះ ប៉ុន្តែពួកគេនៅតែភ័យខ្លាច ដូច្នេះគាត់ក៏យល់ព្រម អៀវពួកគេម្នាក់ម្តងឆ្លងទៅត្រើយម្ខាងទៀត ។







ពេលមកដល់ពាក់កណ្តាលទន្លេ គាត់កាន់តែធ្ងន់ទៅៗធ្វើឱ្យអស់កម្លាំង ដូច្នេះគាត់សម្រេចចិត្តដាក់មនុស្សម្នាក់នេះនៅ លើកោះ ។ បន្ទាប់មកគាត់ត្រឡប់ក្រោយវិញ ទៅយកមនុស្សម្នាក់ទៀតនៅឯច្រាំងទន្លេ មនុស្សម្នាក់នេះចង់ឱ្យគាត់អៀវ តែគាត់មិនព្រម គាត់យល់ព្រមដឹកដៃនាងដោយឱ្យនាងដើរលើដុំថ្មដោយខ្លួនឯង ។





ពេលមកដល់ពាក់កណ្តាលទន្លេ នាងអាចដើរដោយខ្លួនឯងបាន ដូច្នេះពួកគេទាំងពីរអាចឆ្លងទន្លេបាន ។

ពេលពួកគេឆ្លងទៅដល់ត្រើយម្ខាងទៀត ពួកគេសប្បាយចិត្តយ៉ាងខ្លាំង ហើយក៏ដើរចេញទៅភ្លេចបុរសម្នាក់ទៀតនៅលើកោះ ។ គាត់ព្យាយាមធ្វើកាយវិការ ដើម្បីឱ្យពួកគេចាប់អារម្មណ៍ ប៉ុន្តែពួកគេមិនបានចាប់អារម្មណ៍បន្តិចទាល់តែសោះ ។



សំនួរពិភាក្សា

១. តើអ្នកឃើញមានអ្វី កើតឡើងនៅក្នុងការសម្តែងនេះ?

២. តើមានមធ្យោបាយខុសគ្នាអ្វីខ្លះ ដែលប្រើដើម្បីជួយមនុស្សទាំងពីរនាក់នេះឱ្យឆ្លងទន្លេទៅត្រើយម្ខាងទៀត?

៣. តើម្នាក់ៗក្នុងចំណោមពួកគេ តំណាងឱ្យអ្នកណានៅក្នុងជីវិតជាក់ស្តែង?

៤. តើច្រាំងទន្លេទាំងសងខាងតំណាងឱ្យអ្វី?

៥. ហេតុអ្វី បានជាយើងធ្វើកម្មវិធីសាមគ្គីនេះ?

៦. តើគម្រោងសហគមន៍បង្កើតនិមិត្ត នៃភាពឯករាជ្យដោយវិធីណាខ្លះ?

៧. តើយើងត្រូវតែធ្វើអ្វី ដើម្បីធានាថា អ្នកដែលយើងធ្វើការជាមួយមានការអភិវឌ្ឍនិមិត្តដោយភាពឯករាជ្យ?

## ❖ ជំហានទី ៥:តារាងបញ្ជីរពីរបៀបដែលអ្នកចង់ធ្វើការរួមគ្នាជាសហគមន៍

នេះគឺជាលំហាត់មួយដែលល្អប្រសើរ ដើម្បីជួយឱ្យសហគមន៍ គិតពិចារណាពីរបៀបដែលពួកគេនឹងធ្វើការជា មួយគ្នា។ អ្វីដែលគេធ្វើអាចប្រើជាច្បាប់មូលដ្ឋាន និងអាចប្រើក្នុងការចូលរួមជាផ្នែកមួយសម្រាប់ ណែនាំក្នុងការត្រួត ពិនិត្យ និងវាយតម្លៃគម្រោងរបស់ពួកគាត់។

បំផុសគំនិតអ្នកចូលរួមស្តីពីច្បាប់មូលដ្ឋាន និងសរសេរនៅលើផ្ទាំងក្រដាសធំ។ បន្ទាប់មកសួរប្រជាជនអោយ បោះឆ្នោតលើអាទិភាព (ចំណុចទាំងប្រាំ Top five) ឬ (ចំណុចទាំងដប់ Top ten)

ឧទាហរណ៍



អ្នកប្រហែលជាចង់សួរក្រុម ចំពោះការគិតអំពីតួនាទីនានាដែលជាមូលដ្ឋាន ដែលនឹងជួយឱ្យអ្នកកាន់តែច្បាស់ថា ប្រជាជនណាម្នាក់ តែងតែមានការបដិសេធនូវឱកាស ចំពោះការចែកចាយមតិយោបល់របស់ពួកគាត់ ដូចជា មិនអនុញ្ញាតឱ្យ អ្នកមានផ្ទុក ជំងឺអេដស៍ ស្ត្រី ឬក្មេងៗជាដើមដើម្បីចែកចាយ ។

## ❖ ជំហានទី ៦: ជ្រើសរើស និងបង្ហាត់បង្រៀន ក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ (LCG)

### គោលបំណងនៃក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ



គោលបំណងនៃក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ គឺជាមើលខុសត្រូវពីរបៀប ដែលសហគមន៍ប្រមូលពតិមានអំពីតំរូវការ ធ្វើការវិភាគ និងការធ្វើផែនការ ហើយនិងការចាប់ផ្តើមដំណើរការគម្រោងនៅក្នុងសហគមន៍ ។

### កិច្ចការជាក់លាក់នានានៃក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ

- លើកទឹកចិត្តប្រជាជនមកចូលរួមប្រជុំឱ្យបានទៀងទាត់ និងទាន់ពេលវេលា ។
- លើកទឹកចិត្តប្រជាជនអោយមកចូលរួមក្នុងគម្រោងសហគមន៍ ។
- មានការយល់ព្រមគ្នាពី ទីកន្លែង និងពេលវេលា អំពីការប្រជុំសហគមន៍ ។
- កំណត់ចំនួនពេលវេលានៅក្នុងការប្រជុំ និងពេលប្រជុំលើកក្រោយ ។
- ការចែករំលែកកិច្ចការក្នុងការប្រមូលពតិមាន ការប្រមូលធនធាន និងការចាត់ចែងក្រុមប្រជាជនឱ្យចេះចូលរួមកំលាំងពលកម្ម ។
- មានការប្រជុំជាមួយក្រុមទៀងទាត់ ដើម្បីរំលឹកអំពីដំណើរ នឹងប្រារព្ធអបអរចំពោះការជោគជ័យ ។
- ការចូលរួមគ្នានូវក្រុមជំនុំ និងអ្នកដឹកនាំសហគមន៍ ហើយរាយការណ៍អំពីដំណើរការ ។
- បញ្ចុះបញ្ចូលឱ្យមានលុយ ពីមុខរបរតាមតំបន់ ឬអំណោយពីអាជ្ញាធរ ។
- ត្រួតពិនិត្យសីលធមិ និងការលើកទឹកចិត្តសមាជិក ដែលបានចូលរួមនៅក្នុងគម្រោង ។
- រៀនស្គាល់ពីឧបករណ៍នៅក្នុងការណែនាំនេះ នឹងរបៀបរៀបត្រៀមដើម្បី ដឹកនាំការពណិនាសហគមន៍ ការប្រមូលពតិមាន និងការវិភាគពតិមាន ។

## ការជ្រើសរើសសមាជិកនៃក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ

ក្រុមជំនុំ និងសហគមន៍ ត្រូវព្រមព្រៀងគ្នានូវលក្ខណៈសម្បត្តិមួយចំនួន ដែលប្រជាជនបានជ្រើសរើសលក្ខណៈសម្បត្តិអាចរួមបញ្ចូលៈ

- តើសហគមន៍គោរពពួកគាត់ដែរឬទេ?
- តើពួកគាត់នដឹងពីអ្វី ដែលធ្វើឱ្យពួកគាត់មានកំលាំងកាយ និងចិត្តឬទេ?
- តើពួកគាត់មានជំនាញក្នុងការអនុវត្តឬទេ?

វាមានសារៈសំខាន់ណាស់ ក្នុងការដែលមានវត្តមានរួមគ្នារវាងសមាជិកសហគមន៍និងក្រុមជំនុំ នឹងត្រូវប្រាកដថា ក្នុងនោះមានក្រុមស្ត្រី យុវជន និងអ្នកដែលក្រ តូចទាបផ្សេងៗទៀត។ វាជាការសំខាន់ត្រូវនឹកចាំថា ក្រុម សម្របសម្រួលប្រជាជនក្នុងភូមិ មិនមែននៅក្រោមការគ្រប់គ្រងរបស់ក្រុមជំនុំ ប៉ុន្តែគឺជាក្រុមតំណាង ដែលតំណាង ឱ្យសហគមន៍ និងក្រុមដែលមានជំនឿផ្សេងៗគ្នា។

ក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ នឹងត្រូវផ្តល់ឱ្យពេលវេលាច្រើន ចំពោះកម្មវិធីសាមគ្គីពេលវេលាផ្សេងទៀតដែលពួកគាត់ត្រូវធ្វើស្រែ ឬបង្កើនប្រាក់ចំណូលរបស់ពួកគាត់។ សហគមន៍ត្រូវគិតដូចម្តេចចំពោះការឧបត្ថម្ភដល់ក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ។ ឧទាហរណ៍ ការផ្គត់ផ្គង់របស់ពួកគាត់ប្រហែលជាការទទួលខុសត្រូវរបស់សហគមន៍ផ្សេងទៀតឬពួកគាត់ប្រហែលជាទទួលបានបដិភាគម្ហូបអាហារពីសហគមន៍ផ្សេងរាល់អាទិត្យនីមួយៗ។

### កំណត់តួនាទីជាក់លាក់ចំពោះសមាជិកក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ

វាមានសារៈសំខាន់ណាស់ ក្នុងការកំណត់តួនាទីជាក់លាក់ ចំពោះសមាជិកក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ។ តួនាទីទាំងនេះ អាចរំលឹកឡើងបន្ទាប់ពីមួយរយះពេលក្រោយមកដើម្បីឱ្យដឹងថា តើសមាជិកនីមួយៗគឺសប្បាយរីករាយ ជាមួយអ្វីដែលពួកគាត់កំពុងធ្វើឬមួយក៏ត្រូវផ្លាស់ប្តូរតួនាទីទៅជារបៀបផ្សេងទៀត។ ខាងក្រោម គឺជាបញ្ជីអំពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកសម្របសម្រួលដែលត្រូវធ្វើ។



**➡ អ្នកដឹកនាំ / ប្រធាន / អ្នកសម្របសម្រួល**

- ដើរតួជាអ្នកនិយាយ ឬក៏តំណាងឱ្យមន្ត្រីកម្មវិធីសាមគ្គី ជាមួយសហគមន៍ ហើយនិងលទ្ធផលនៃគម្រោងសហគមន៍ផ្សេងៗទៀត
- ទទួលខុសត្រូវក្នុងការដឹកនាំក្រុម
- ធ្វើជាអ្នកដឹកនាំ និងធ្វើរបៀបវីរៈ ក្នុងការប្រជុំ
- តាមដាន បញ្ជាក់ឱ្យប្រាកដថា កិច្ចការទាំងអស់បានធ្វើហើយ
- លើកទឹកចិត្ត និងគាំទ្រ អ្នកដែលធ្វើការងារផ្សេងៗគ្នា
- ជួយសមាជិកក្រុមផ្សេងៗទៀត និងសហគមន៍ធ្វើការឆ្លុះបញ្ចាំងលើកម្មវិធីសាមគ្គី ថាតើវាដំណើរការយ៉ាងម៉េចហើយ? តើអាចធ្វើអ្វី ដើម្បីឱ្យការងារហ្នឹងមានលក្ខណៈកាន់តែប្រសើរឡើង?
- ជួយក្រុមដើម្បីដោះស្រាយបញ្ហាផ្សេងៗ ក្នុងវដ្តនៃគំរោង
- ជួយក្រុមគិតពីមធ្យោបាយថ្មី ក្នុងការអបអរសារទ អ្វីដែលសំរេចបាន។

**➡ លេខាធិការ**

- រក្សាឈ្មោះអ្នកចូលរួមគំរោង ហើយនឹងពតិមានទំនាក់ទំនងរបស់សមាជិកសហគមន៍ ដែលបានចូលរួមគំរោងកម្មវិធីសាមគ្គីទាំងអស់
- សរសេរសំបុត្រជំនួសឱ្យគណៈកម្មាការនៃក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ
- ត្រូវរក្សាឯកសារថតចំលងផ្សេងៗ
- ជួយធ្វើការរៀបចំ និងបង្ហាញរាល់ឯកសារសំខាន់ៗទាំងអស់ ដែលទាក់ទងទៅនឹងដំណើរកម្មវិធីសាមគ្គី។

**➡ អ្នកកាន់លុយ**

- ត្រួតពិនិត្យលុយ និងធនធានផ្សេងៗ
- ត្រូវប្រាកដថា ចំណូល និងចំណាយ គឺត្រូវបានត្រួតពិនិត្យ និងកត់ត្រាបានត្រឹមត្រូវ
- បង្កើត និងរក្សាច្បាប់គ្រប់គ្រងលុយសំរាប់កម្មវិធីសាមគ្គី និងគំរោង
- ត្រូវប្រាកដថាប្រព័ន្ធនៃការគ្រប់គ្រងសាច់ប្រាក់តិចតួចគឺដំណើរការយ៉ាងមានប្រសិទ្ធិភាព
- មានតួនាទីជួយរៀបចំផែនការកញ្ចប់ថវិការចាយលុយ និងទទួលខុសត្រូវរាយការណ៍របាយការណ៍ប្រចាំខែនិងការចំណាយប្រចាំត្រីមាសរបស់ក្រុម
- មុនពេលប្រជុំគណៈកម្មាការ ត្រូវប្រាកដថាលុយជាក់ស្តែង និងសៀវភៅបញ្ជីកត់ត្រាចំណូលចំណាយត្រូវ គ្នា
- ត្រួតពិនិត្យយ៉ាងល្អិតល្អន់ និងរាយការណ៍នូវលុយដែលបានប្រើប្រាស់ មិនបានត្រឹមត្រូវ។

## តួនាទី និងការទទួលខុសត្រូវនៃសមាជិកក្រុមសម្របសម្រួលប្រជាជនក្នុងភូមិផ្សេងទៀត

- មានចិត្តត្រៀមខ្លួន មានចិត្តក្នុងការធ្វើការ
- មកឱ្យទាន់ពេលវេលា
- ចេះធ្វើការងារជាក្រុម
- បើចាំបាច់ត្រូវរក្សាការសំងាត់នូវអ្វីដែលបានពិភាក្សានៅក្នុងការប្រជុំ មិនត្រូវប្រាប់អ្នកដ៏ទៃឡើយ ។



## ការបង្ហាត់បង្រៀនសំរាប់ក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ

ក្រុមសម្របសម្រួលប្រជាជនក្នុងភូមិ គួរតែទទួលការបង្ហាត់នូវចំនុចដូចខាងក្រោម:

- ដំណាក់គន្លឹះនៃកម្មវិធីសាមគ្គី និងតើអ្វីជាតម្រូវការក្នុងដំណាក់កាលនីមួយៗ
  ( មើលនៅទំព័រទី ៣-៦ )
- ជំនាញការសម្របសម្រួលជាមូលដ្ឋាន និងការដឹកនាំក្រុម
  ( មើលនៅទំព័រទី ១០-១៤ )
- ការប្រើប្រាស់ឧបករណ៏ សម្រាប់ប្រមូលពតិមាន និងការវិភាគពតិមាននៅក្នុងសហគមន៏
  ( មើលនៅទំព័រទី ៦៤-៧៣ )
  - ធ្វើផែនទីសហគមន៏
  - ដើមឈើបញ្ហា "Problem Tree"
  - ពេលវេលា
  - ការដាក់អត្ថិភាព
  - ប្រតិទិន ឬកាលវិភាគតាមរដូវកាល

– ប្រើប្រាស់តារាងទិន្នន័យ
– ការដាក់អត្ថិភាព និងការបង្ហាញជូននូវពតិមាន

សំរាប់ពតិមានបន្ថែមទៀត លើការគ្រប់គ្រងប្រជាជន មានភាពសាកសិទ្ធក្នុងការប្រជុំ និងការសាងជាក្រុម មើលទៅដំណាក់កាលទី ៤ ការធ្វើសកម្មភាព ។( មើលនៅទំព័រទី ១៣៣-១៥៣ ក្នុងភាសាអង់គ្លេស ) ។

## ផ្នែកទី២: ការពិពណ៌នាអំពីសហគមន៍

### គោលបំណងនៃផ្នែកទី ២:

ជួយសម្របសម្រួលសហគមន៍ ឱ្យប្រាប់អំពីប្រវត្តិរឿងផ្ទាល់ខ្លួនរបស់ពួកគាត់ ថាតើពួកគាត់ជា នរណា ពួកគាត់អញ្ជើញមកពីណា និងអ្វីដែលជាស្ថានភាពបច្ចុប្បន្នរបស់ពួកគាត់ ។

### ការណែនាំ

មុនពេលប្រើប្រាស់ឧបករណ៍ផ្សេងៗ នៅក្នុងការប្រមូលពតិមានអំពីសហគមន៍ វាជាការសំខាន់ដែលពិភាក្សា អំពីអ្វីដែលសហគមន៍ ឱ្យនិយមន័យចំពោះសហគមន៍របស់ពួកគាត់ រួមទាំងរយះនៃប្រវត្តិសាស្ត្រ និងក្រុមជាក់លាក់ ដែលគេចង់បូកបញ្ចូល ។

អ្នកសម្របសម្រួលត្រូវដើរតួនាទីជាអ្នកជួយសហគមន៍គិតពីអ្វីដែលអាចបញ្ចូលគ្នាបានទៅក្នុងសហគមន៍របស់ ពួកគាត់ ហើយនឹងរបៀបដែលបានកំនត់វា ។

### ជំហានគន្លឹះនានា:

១. លើកទឹកចិត្តក្រុមជំនុំឱ្យសិក្សាព្រះគម្ពីរ ដើម្បីបង្ហាញឱ្យឃើញពីបញ្ហាការនៅក្នុងការពិពណ៌នារបស់សហ-គមន៍ ។
២. ណែនាំសហគមន៍ឱ្យដាក់លេខចំពោះឧបករណ៍ជាច្រើន ដែលនឹងជួយពួកគាត់ឱ្យយល់ច្បាស់អំពីស្ថានភាពបច្ចុប្បន្នរបស់ពួកគាត់ ។
៣. ក្នុងការជ្រើសរើស អ្នកណាដែលអាចធ្វើជាផ្នែកនៃក្រុមអ្នកប្រមូលពតិមាន ។



## ❖ ជំហានទី ១: សិក្សាព្រះគម្ពីរ



លោក នេហេមា ធ្វើការត្រួតពិនិត្យជញ្ជាំង

**សូមអាន នេហេមា ២:១១-១៨**



១. បន្ទាប់ពីបាននិរទេសជាច្រើនឆ្នាំមក លោកនេហេមាក៏បានត្រឡប់ទៅទីក្រុងយេរូសាឡិមដើម្បីមើលទីក្រុងដែលបានបាក់បែក តើគាត់ធ្វើអ្វី? (ខទី ១១-១៦)

២. នៅពេលគាត់មកដល់ក្រុងយេរូសាឡិម គិតថាជួសជួលជញ្ជាំងឡើងវិញ។ ហេតុអ្វី បានជាអ្នកគិតថាគាត់ធ្វើបែបហ្នឹង?

៣. ហេតុអ្វីអ្នកគិតថា គាត់មិនចង់ចាប់ផ្តើមភ្លាមៗ តើយើងគិតដូចម្តេច? ប្រសិនបើ គាត់គិតភ្លាមក្នុងការកសាងកំផែងឡើងវិញ តើយើងគិតដូចម្តេច?

៤. តើមធ្យោបាយអ្វី ដែលយើងអាចចាប់ផ្តើម នៅក្នុងសហគមន៍របស់យើង មុនពេលយើងចាប់ផ្តើមធ្វើសកម្មភាព?

***ចំនុចគន្លឹះ: វាគឺមានសារៈសំខាន់សំរាប់ពួកយើង ក្នុងការគិតឱ្យបានច្រើន អំពីតំរូវការក្នុងសហគមន៍របស់យើង បន្ទាប់មកគ្រាន់តែគិតក្នុងចិត្ត ហើយយកទៅធ្វើ។***

## ❖ ជំហានទី ២: ឧបករណ៍សំរាប់ពិពណ៌នាសហគមន៍របស់អ្នក

ឧបករណ៍ជាច្រើន នៅក្នុងជំហ៊ាននេះអាចយកមកប្រើ តាមតែអាចធ្វើទៅបាន នៅពេលប្រជុំធំក្នុងសហគមន៍ ឬជាមួយក្រុមតូច។ វាមិនចាំបាច់ប្រើប្រាស់ឧបករណ៍ទាំងអស់ទេ ប៉ុន្តែត្រូវបញ្ចូលគ្នានៃឧបករណ៍ខ្លះ ដើម្បីមើលឃើញ ពីរូបភាពទូលំទូលាយក្នុងសហគមន៍។ ឧបករណ៍ទាំងនេះគឺត្រូវបានរៀបចំឡើង ដើម្បីឱ្យប្រជាជនចូលរួមយ៉ាងច្រើន

តាមតែអាចធ្វើទៅបាន ហើយអ្នកដែលសម្រួបសម្រួលពួកគាត់ត្រូវតែយល់ និងធ្លាប់មានអនុវត្តរួចហើយ។

ឧបករណ៍ដែលអាចគូរបានមានដូចជា ការធ្វើផែនទីកំណាត់ពេលវេលា និងកាលវិភាគ តាមរដូវកាល វាគឺមាន សារៈសំខាន់ក្នុងការរក្សាកំណត់ត្រានៃគំនូរ ដែលសហគមន៍បានឃើញពីស្ថានភាពពួកគាត់មុនពេលចាប់ផ្តើមគម្រោង ផ្សេងៗ។ កំណត់ត្រាទាំងនេះអាចបញ្ជាក់ពីភាពខុសគ្នារវាងមុន និងក្រោយពេលមានគម្រោង ដើម្បីយកទៅធ្វើការ វាយតម្លៃពេលក្រោយ។

ឧបករណ៍ និងសកម្មភាពទាំងនេះមានពិពណ៌នាយ៉ាងលំអិតក្នុងទំព័របន្តបន្ទាប់ខាងក្រោមនេះ:

- ឧបករណ៍គូរផែនទីសហគមន៍ ( ទំព័រ ៦៥ )
- ប្រវត្តិសាស្ត្រនៃសហគមន៍របស់យើង ( ទំព័រ ៦៦ )
- រូបភាពប្រវត្តិសាស្ត្រនៃសហគមន៍ ( ទំព័រ ៦៧-៦៨ )
- កាលវិភាគតាមរដូវកាល ( ទំព័រ ៦៨-៦៩ )
- តើអ្នកណាធ្វើអ្វីខ្លះ នៅក្នុងសហគមន៍របស់យើង? ( ទំព័រ ៧០ )
- ល្ពៅ ( ទំព័រ ៧២ )
- ការដាក់អទិភាព ( ទំព័រ ៧៣ )

### ឧបករណ៍គូរផែនទីសហគមន៍

ផែនទីសហគមន៍ គឺអាចប្រើប្រាស់បានតាមរបៀបផ្សេងៗគ្នាជាច្រើន។ គោលបំណងរបស់ផែនទីសហគមន៍នេះគឺជួយសហគមន៍ឱ្យមានការចូលរួមនិងបញ្ជាក់បង្ហាញពីខ្លួនគាត់ផ្ទាល់ដោយគ្មានការបង្ខិតបង្ខំ។ ផែនទីសាមញ្ញខ្លះ មានរួមបញ្ចូលខ្សែបន្ទាត់ព្រំដែន ទ្រង់ទ្រាយធម្មជាតិ ដូចជាទន្លេ កូនភ្នំតូច ធនធានមានដូចជា ព្រៃឈើនិងទីកន្លែង មាន ដូចជាសាលារៀន និងមន្ទីរពេទ្យជាដើម ដើម្បីបង្ហាញពីជីវភាពរស់នៅរបស់ប្រជាជន។

**ការណែនាំជាជំហានៗ**



១. ដាក់ក្រដាសធំនៅលើតុ ឬក៏កំរាលឥតក៏បានសម្រាប់ គូរផែនទី។ ជំរើសផ្សេងទៀត អាចគូរផែនទីនៅលើដី ឬលើខ្សាច់ក៏បាន។

២. គូរចំនុចទ្រង់ទ្រាយសំខាន់ៗនៃតំបន់ ដូចជា ផ្លូវ ទន្លេ បឹង កូនភ្នំតូចៗ និង អូរ។

៣. គូរកន្លែងអាគារសំខាន់ៗដូចជា សាលារៀន មណ្ឌលសុខភាព ក្រុមជំនុំ អណ្ដូងទឹក ផ្ទះសំណាក់ សហករណ៍ ផ្សារ និងតារាងបាល់ទាត់ជាដើម។

៤. ពិភាក្សានិងគូរនូវផ្នែកសំខាន់ៗ នៃតម្រូវការ ឬបញ្ហាកង្វល់របស់សហគមន៍។ នេះអាចដាក់បញ្ចូលធន ធាន ឬ ប្រជាជនរងការគំរាមកំហែង។

៥. គូររូបភាព ឬទីកន្លែងផ្សេងៗនៅលើផែនទី ដើម្បីឆ្លុះបញ្ចាំងពីបញ្ហាដែលបានពិភាក្សា។

៦. ឱ្យគ្រួស ឬគ្រាប់សណ្ដែកដល់អ្នកចូលរួមទាំងអស់នូវចំនួនស្មើៗគ្នា។ ពួកគាត់ត្រូវដាក់គ្រួស ឬសណ្ដែក ទាំងនេះ លើផែនទីដើម្បីបង្ហាញថាតើបញ្ហាណាមួយ ដែលពួកគាត់គិតថាសំខាន់បំផុត។

**សេចក្ដីណែនាំនានា:**

១. ប្រសិនបើមាន ក្រុមធំពេកត្រូវបែងចែកជាក្រុមតូច ធ្វើការផ្អែកតាមចំនួចផែនទី។ ត្រូវដឹងថាកិច្ចការនេះ ត្រូវចំណាយពេលវេលាយូរ ដើម្បីទទួលបានយោបល់ត្រឡប់មកវិញ។

២. ជួនកាល វាមានប្រយោជន៍ខ្លាំងណាស់ ចំពោះការបែងចែកអ្នកចូលរួមជាក្រុមទៅតាម អាយុ ឬភេទ។

៣. កិច្ចការសំខាន់បំផុតទី១គឺត្រូវគូរផ្លូវ និងទីកន្លែងមុនគេ ដើម្បីងាយស្រួលក្នុងការគូរបែងចែកដាក់របស់ ផ្សេងទៀតនៅលើផែនទី។

៤. ដើម្បីធ្វើឱ្យសកម្មភាពនេះកាន់តែមានភាពប្រសើរថែមទៀត អ្នកអាចលើកទឹកចិត្តអ្នកចូលរួមឱ្យ ថតរូប សហគមន៍របស់ពួកគាត់។

៥. ផែនទីនេះអាចជាធនធានដ៏សំខាន់មួយ ក្នុងការរៀបចំផែនការសម្រាប់អនាគត ដូច្នេះបើអាចទៅរួចគួរ រក្សាផែនការទីនេះ នៅកន្លែងដែលប្រជាជនអាចមើលឃើញ ហើយនិងអាចបន្ថែមបាន។

៦. បន្ទាប់ពីពិភាក្សារកតម្រូវការរួចហើយ អ្នកអាចយកទៀនមកដាក់ចំកន្លែងដែលជាតម្រូវការរួចអធិដ្ឋាន សម្រាប់កន្លែងទាំងនេះម្ដងមួយៗ។

## ប្រវត្តិរបស់សហគមន៍យើង

សកម្មភាពនេះ វាទាក់ទងជាមួយនឹងការពិភាក្សាអំពីព្រឹត្តិការណ៍ជាចំបងនានា ដែលបាននាំទៅដល់ការបង្កើតសហគមន៍ដែលមានសព្វថ្ងៃ ។ព្រឹត្តិការណ៍ទាំងនេះ គួររួមបញ្ចូលទាំង ព្រឹត្តិការណ៍សង្គម នយោបាយ និងព្រឹត្តិការណ៍ធម្មជាតិនានាដែរ ។សហគមន៍ក៏គួរតែវិភាគទៅលើការផ្លាស់ប្ដូរនានាដែលកើតមានឡើងក្នុងប្រវត្តិសាស្ត្រដែរ ថាតើវាអាចនឹងផ្ដល់ផលប្រយោជន៍ចំពោះសហគមន៍ ឬធ្វើអោយខូចប្រយោជន៍ដល់សហគមន៍ហើយតើនរណាបានធ្វើអោយព្រឹត្តិការណ៍នោះកើតឡើង ។

### ការណែនាំជាជំហាន១

១. ធ្វើការព្រមព្រៀងគ្នានៅក្នុងក្រុម ថាតើគួរចាប់ផ្ដើមកត់ចុះនូវព្រឹត្តិការណ៍សំខាន់ៗណាខ្លះ ។
២. សរសេរចុះនូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនានាដែលមានសារសំខាន់ចំពោះសហគមន៍នេះដោយប្រើក្ដារខៀន ឬក្រដាសធំមួយផ្ទាំង ។
៣. នៅពេលបានកត់ចុះរួចហើយ សូមអោយគេពិភាក្សារកមើលថាតើព្រឹត្តិការណ៍នីមួយៗវាមានផលប្រយោជន៍ និងផលលំបាកយ៉ាងណាខ្លះចំពោះសហគមន៍ ។
៤. សូមអោយគេពិភាក្សារកពីរបៀបដែលធ្វើអោយសហគមន៍បានផ្លាស់ប្ដូរនិងលទ្ធផលនានាចេញពីព្រឹត្តិការណ៍ទាំងនេះ ទាំងចំនុចវិជ្ជមានទាំងចំនុចអវិជ្ជមាន ។
៥. ធ្វើការសង្ខេបនូវចំនុចគន្លឹះទាំងឡាយដែលបានពិភាក្សារួច ហើយធ្វើការពិភាក្សាបន្តទៅលើចំនុចខ្លាំងនានារបស់សហគមន៍ ថាតើវាអាចធ្វើអោយសហគមន៍បានប្រសើរនាពេលអនាគតដែរឬទេ ។

### សេចក្ដីណែនាំនានា:

១. ប្រសិនបើក្រុមធំពេក ចូរបំបែកអោយទៅជាក្រុមតូចៗ ដែលមានមនុស្សពី៤ ទៅ ៥នាក់ បន្ទាប់មកអោយក្រុមតូចៗទាំងនោះឆ្លើយសំនួរពិភាក្សានោះទៅក្នុងក្រុមធំវិញ ។ធ្វើដូចនេះ ពួកគេអាចធ្វើការពិភាក្សាទៅលើព្រឹត្តិការណ៍សំខាន់ៗផ្សេងៗបានគ្រប់ៗគ្នា ។
២. អ្នកអាចចែកក្រុមទៅតាមក្រុមមនុស្សបាន ដូចជាទៅតាមភេទ អាយុជាដើម ។
៣. បើសិនជាមានលទ្ធភាព ចូរព្យាយាមសរសេរចុះនូវពតិមាននៅក្នុងក្រដាសធំៗ តែបើមិនមានវិញ អាចសូមអោយនរណាម្នាក់ចំលងពតិមានទាំងអស់ដែលនៅលើក្ដារខៀនចូលទៅក្នុងសៀវភៅ ដើម្បីយើងអាចទុកវាប្រើនៅថ្ងៃក្រោយទៀត ។
៤. ប្រសិនបើអាចធ្វើបាន ចូរធ្វើការអបអរទៅចំពោះក្រុមមនុស្សដែលបានរកឃើញនូវព្រឹត្តិការណ៍សំខាន់ៗវិជ្ជ

មាននានាព្រមទាំងធ្វើការអរគុណដល់ពួកគេចំពោះការដែលពួកគេអាចរកឃើញនូវព្រឹត្តិការណ៍ពិតជាក់ស្តែងផ្សេងៗដែលមានដូចជា ការចាប់ផ្តើមនូវដំណើរការសាលាឬមន្ទីរព្យាបាលរោគ ការសាងសង់ស្ពាន ឬក៏ការជួយដល់សហគមន៍នានាអោយបានជានឹងគ្នាឡើងវិញជាដើម ។

៥. ជួយសហគមន៍អោយចេះកំណត់បាននូវបញ្ហាផ្សេងៗដែលនាំអោយជួបនូវគ្រោះមហន្តរាយ ដែលមានដូចជា បញ្ហាសុខភាព ការប្រើប្រាស់ហួសល្បត់នូវធនធានធម្មជាតិនានា ជាដើម ។

៦. ប្រសិនបើមានលទ្ធភាព ចូរធ្វើការស្រាវជ្រាវខ្លះទុកមុន ធ្វើដូចនេះអ្នកអាចដាក់រឿងរ៉ាវនេះបានត្រូវទៅក្នុងបរិបទដែលបានកើតមានឡើងនៅជុំវិញសហគមន៍ផ្សេងៗឬក៏នៅក្នុងប្រជាជាតិនានា ។ដែលជាឧទាហរណ៍មាន ដូចជា តើជំងឺអេដស៍វាជាបញ្ហាតូចឬក៏ជាបញ្ហាតូចនៅក្នុងប្រទេស? តើប្រភេទសត្វឬរុក្ខជាតិនានាបាត់បង់ពីតំបន់នានាដែរឬទេ?

## រូបភាពបង្ហាញពីប្រវត្តិសហគមន៍:

សហគមន៍គួរគូររូបភាពមួយដែលបង្ហាញពីលក្ខណៈនៃស្ថានភាព ដែលកើតមានឡើងនៅក្នុងអតីតកាលក្នុងតំបន់ ។ អ្នកសម្របសម្រួលត្រូវលើកទឹកចិត្តអ្នកចូលរួមអោយពិភាក្សាពីការផ្លាស់ប្តូរនានាដែលកើតមានឡើងតាំងពីពេលនោះមក ។ នៅពេលយើងប្រើរូបភាពនេះប្រៀបធៀបនឹងផែនទីបច្ចុប្បន្ននោះធ្វើអោយការពិភាក្សានេះមានដំណើរការនិងទទួលបានលទ្ធផលល្អ ។

### ការណែនាំតាមជំហាន

១.ដំបូងក្រុមទាំងមូលត្រូវជ្រើសរើសយកកំឡុងពេលដែលពួកគេចង់បង្ហាញ អាចពី១០-២០ឆ្នាំមុន ។

២.បន្ទាប់មកអ្នកចូលរួមត្រូវចែកចាយពីរឿងរ៉ាវដែលកើតមានឡើងក្នុងកំឡុងពេលនោះ ហើយចាត់អោយអ្នកចូលរួម២-៣នាក់គូររូបភាពពីអ្វីដែលអ្នកដទៃបាននិយាយព្រមទាំងសរសេរចុះនូវពាក្យសំខានៗដែលបង្ហាញពីរឿងរ៉ាវទាំងអស់នោះ ។

៣.បន្ទាប់មកទៀតក្រុមពិភាក្សា ត្រូវគូររូបភាពពីស្ថានភាពបច្ចុប្បន្នរបស់សហគមន៍ ហើយគិតពិចារណាទៅលើស្ថានភាពសង្គម និងសេដ្ឋកិច្ចនៃសហគមន៍ដោយផ្អែកលើរូបភាពទាំងពីរ ។

៤.ផ្តល់ពេលវេលាដល់អ្នកចូលរួមដើម្បីមើលរូបភាពទាំងពីរដោយស្ងៀមស្ងាត់ បន្ទាប់មកពិភាក្សាទៅលើចំនុចខុសគ្នាសំខាន់ៗនៃរូបភាពទាំងពីរនេះ និងពិភាក្សាសំនួរដូចខាងក្រោម :

ក-តើអ្វីជាការផ្លាស់ប្តូរដ៏សំខាន់ដែលកើតមានឡើងរវាងរូបភាពទាំងពីរទាក់ទងទៅនឹង សុខភាព ប្រាក់ចំណូល ផ្ទះ កសិកម្ម ក្រុមជំនុំ និងការទំនាក់ទំនងផ្សេងៗ ?

ខ-តើការផ្លាស់ប្តូរទាំងនោះល្អ ឬមិនល្អ ? មូលហេតុអ្វី?

គ-តើអ្វីជាកិច្ចការល្អដែលយើងអាចប្រើដើម្បីធ្វើការអភិវឌ្ឍន៍ទៅថ្ងៃអនាគត?

**សេចក្តីណែនាំនានា:**



១. ក្នុងការគូររូបភាពសហគមន៍នៅក្នុងអតីតកាល គួរតែទុកពេលវេលាអោយបានគ្រប់គ្រាន់ដល់អ្នកចូលរួមណាដែលមានវ័យចំណាស់ក្នុងសហគមន៍ដើម្បីចែកចាយពីរឿងរ៉ាវ និងការចងចាំរបស់ពួកគាត់ ។

២. គួរតែបែងចែកអ្នកចូលរួមតាមអាយុ និងភេទនៅក្នុងការគូររូបទាំងនេះ ។

៣. គួរព្យាយាមរក្សារូបភាពទាំងនេះទុកសម្រាប់ការពិភាក្សាលើកក្រោយៗទៀតឬអាចថតជារូបភាពទុកក៏បាន ។

**ប្រតិទិនតាមរដូវកាល:**



ប្រតិទិនតាមរដូវកាលជាវិធីមួយដ៏មានប្រយោជន៍ក្នុងការកត់ត្រាពីភាពខុសគ្នានៃអាកាសធាតុ និងរដូវ កាលធ្វើកសិកម្មប្រចាំឆ្នាំ ។ នេះជាពត៌មានមួយដ៏មានសារៈសំខាន់ដែលអាចជួយយើងបាននៅពេលដែលយើងត្រូវ ការកំលាំងជាចាំបាច់ដើម្បីធ្វើការដាំដុះ និងប្រមូលផល និងម្យ៉ាងទៀតអាចជួយអោយយើងដឹងពីសណ្ឋាននៃជំងឺ ឆ្លងផ្សេងៗដូចជា ជំងឺគ្រុនចាញ់ជាដើម ។

**ការណែនាំតាមជំហាន**

១.ត្រូវប្រើក្រដាសផ្ទាំងធំ ឬអ្វីផ្សេងៗទៀតដែលអាចប្រើប្រាស់បានសម្រាប់ការបង្កើតប្រតិទិននេះ ។

២.ត្រូវរកដុំគ្រួសតូចៗ កំណាត់ឈើ ស្លឹកឈើប្រើសម្រាប់សំគាល់រដូវកាលនីមួយៗ និងការងារកសិកម្ម បន្ទាប់មកសរសេរខែទាំង១២នៅលើក្រដាស ឬលើដី ។

៣.ប្រើដុំថ្ម ឬហ្វីតកត់សំគាល់ទៅលើខែណាដែលមានកំរិតទឹកភ្លៀងតិច ឬច្រើនជាងគេ ឧទាហរណ៍ អ្នកអាចប្រើដុំថ្ម៥ដុំដាក់ចំខែណាដែលមានភ្លៀងធ្លាក់ច្រើនជាងគេ និងដុំថ្ម១ដុំចំខែណាដែលមានភ្លៀងធ្លាក់តិចជាងគេ ។




៤.បែងចែកអ្នកចូលរួមជាក្រុមតូចៗដើម្បីពិភាក្សាទៅលើខែណាដែល :

ក-ត្រូវការកំលាំងដើម្បីធ្វើការច្រើនជាងគេ តើមានការបែងចែកការងាររវាងបុរស និងស្ត្រីឬទេ?

ខ-ប្រជាជនត្រូវទទួលរងការឆ្លងជំងឺច្រើនជាងគេ។

គ-ត្រូវដាំដុះ សំអាតស្មៅ និងប្រមូលផល។

ឃ-ស្បៀងអាហារឡើងថ្លៃខ្លាំងជាងគេ។

៥.ប្រមូលលទ្ធផលនៃការពិភាក្សាគ្រប់ក្រុមទាំងអស់មកដាក់រួមបញ្ចូលគ្នានៅលើក្រដាសតែមួយ រួចហើយធ្វើការពិភាក្សាទៅលើសំនួរនានាដូចខាងក្រោម :

ក-តើនៅខែណាខ្លះដែលក្រុមគ្រួសារនីមួយៗត្រូវការកំលាំងដើម្បីធ្វើការច្រើនបំផុត?

ខ-តើនៅខែណាខ្លះដែលប្រជាជនប្រឈមមុខនឹងបញ្ហាសន្តិសុខស្បៀងខ្លាំងជាងគេ?

គ-តើត្រូវធ្វើអ្វីខ្លះដើម្បីដោះស្រាយបញ្ហាទាំងនេះ?

ឃ-តើសហគមន៍ដោះស្រាយបញ្ហាខ្វះស្បៀងតាមរបៀបណាខ្លះ?

ង-តើក្រុមជំនុំដើរតួនាទីអ្វីដើម្បីជួយប្រជាជនទទួលបាននូវសុវត្ថិភាពផ្នែកស្បៀងអាហារ?



## តើអ្នកណាខ្លះ ធ្វើអ្វីខ្លះនៅក្នុងសហគមន៍របស់យើង?

នេះជាលំហាត់ខ្លីមួយបង្កើតឡើងដើម្បីព្យាយាមស្វែងរកថាបច្ចុប្បន្នមានអ្នកណាខ្លះហើយកំពុងធ្វើអ្វីខ្លះនៅក្នុងសហគមន៍របស់យើង ។ កិច្ចការនេះអាចជួយយើងតាមវិធីពីរយ៉ាងគឺ :

១. ជួយអោយដឹងពីធនធានផ្សេងៗទៀតដែលយើងមានហើយដែលអាចប្រើដើម្បីអោយគម្រោងរបស់យើងកាន់តែមានដំណើរការល្អប្រសើរថែម ទៀត ។

២. ជួយយើងអោយជៀសផុតពីការធ្វើច្រំដែលៗនូវសកម្មភាពដែលមានរួចហើយ ។ ឧទាហរណ៍ជាក់ស្តែងនៅប្រទេសមួយចំនួន មាននិកាយជាច្រើនបានបង្កើតមណ្ឌលសុខភាពនៅក្នុងភូមិតែមួយ នេះជាការខ្ជះខ្ជាយយ៉ាងខ្លាំងនូវធនធាន និងការខិតខំប្រឹងប្រែង ព្រមទាំងបានធ្វើអោយសហគមន៍មានការច្របូកច្របល់ថែមទៀត ។



ចូរធ្វើបញ្ជីមួយ ដោយកត់ត្រាពីគ្រប់ស្ថាប័នទាំងអស់ដែលមាននៅក្នុងសហគមន៍របស់អ្នកដូចមានឧទាហរណ៍បង្ហាញនៅទំព័រមុន។ សូមបំពេញតារាងដើម្បីឆ្លើយតបទៅនឹងសំនួរដូចខាងក្រោម :

-ពិភាក្សាទៅលើស្ថាប័ននីមួយៗ និងកិច្ចការនានាដែលគេធ្វើនៅក្នុងសហគមន៍

-ធ្វើការពិចារណាពីគម្រោងថ្មីសម្រាប់សហគមន៍ តើស្ថាប័នណាខ្លះដែលសហគមន៍ និងក្រុមជំនុំអាចធ្វើការជាមួយបាន។

| ឈ្មោះស្ថាប័ន | កិច្ចការដែលគេធ្វើ | តើយើងអាចធ្វើការជាមួយគេបានដោយរបៀបណា ? |
|---|---|---|
| | | |

សេចក្តីសន្និដ្ឋានចេញពីវិធីសាស្រ្តនេះ ដោយ

-ធ្វើបញ្ជីឈ្មោះស្ថាប័នដែលមាននៅក្នុងសហគមន៍ និងតួនាទីរបស់ស្ថាប័នទាំងនោះ។

-ធ្វើការពណ៌នាពីប្រភេទទំនាក់ទំនងរវាងសហគមន៍ និងស្ថាប័ននីមួយៗ ដោយបង្ហាញថាតើមានចំនុចខ្លាំងច្រើន ឬចំនុចខ្សោយច្រើន។

-ការទទួលស្គាល់ពីរបៀបដែលស្ថាប័នចូលរួមចំណែកនៅក្នុងការអភិវឌ្ឍន៍សហគមន៍។

## ការសំដែងរឿងខ្លី

សុំសមាជិកក្រុមអោយសំដែងរឿងខ្លីមួយបង្ហាញពីព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងសហគមន៍របស់ពួកគេ។

ឧទាហរណ៍ :

បញ្ហានានាដែលស្ត្រីនៅក្នុងភូមិជួបប្រទះ នៅពេលដែលពួកគាត់លក់បន្លែទៅអោយឈ្មួញមកពីទីប្រជុំជនក្នុងសហគមន៍ ហើយពួកឈ្មួញទាំងនោះមិនផ្តល់តម្លៃសមស្របដល់ពួកគាត់ ម្យ៉ាងវិញទៀតពួកគាត់ពឹងផ្អែកលើឈ្មួញទាំងនោះសម្រាប់ការរស់នៅ។



នៅពេលរឿងកំពុងសំដែងអ្នកអាចសួរសំនួរនានាទៅគេដូចខាងក្រោម :

១.តើអ្នកឃើញ និងឮអ្វីខ្លះតាមរយៈរឿងនេះ? តើរឿងខ្លីនេះឆ្លុះបញ្ចាំងពីការពិតនៅក្នុងសហគមន៍របស់យើងបច្ចុប្បន្នឬទេ?

២.នៅក្នុងរឿងនេះតើមានកិច្ចការអ្វីខ្លះដែលធ្វើអោយអ្នកមានមោទនភាពចំពោះសហគមន៍របស់អ្នក? ហេតុអ្វី?

៣.តើនៅក្នុងរឿងនេះមានបញ្ហាអ្វីខ្លះដែលធ្វើអោយអ្នកខកចិត្ត? ហេតុអ្វី?

៤.ស្វែងរកបញ្ហាដែលមាននៅក្នុងរឿងនេះ។ មូលហេតុអ្វីបានជាបញ្ហាទាំងនេះមានសារសំខាន់ចំពោះអ្នក?

៥.អោយអ្នកសំដែងបន្តសំដែងរឿងនេះ បង្ហាញពីរបៀបណាមួយដែលពួកគេអាចផ្លាស់ប្តូរនាពេលអនាគត។



## ការសម្តែងរឿងម្នាក់ឯង

វិធីមួយផ្សេងទៀតនៃការប្រើការសម្តែងរឿងខ្លីនេះគឺអោយប្រជាជននៅក្នុងសហគមន៍សញ្ជឹងគិតពីកិច្ចការដែលពួកគេជួបប្រទះ កិច្ចការល្អ និងមិនល្អ ទំនាក់ទំនងរបស់ពួកគេជាមួយអ្នកដទៃនៅក្នុងសហគមន៍។ បន្ទាប់មកពួកគេត្រូវយកកិច្ចការទាំងនេះមករៀបចំជារឿងខ្លី ហើយសម្តែងម្នាក់ម្តងៗ។ ការសំដែងរឿងតែម្នាក់ឯងនេះគឺជាទំរង់មួយនៃរឿងដោយបញ្ចេញសកម្មភាពសំដែងពិសេសតែម្នាក់ឯងដោយនិយាយទៅកាន់ក្រុម។

បន្ទាប់ពីការសំដែងនេះបានច្រើនហើយ អ្នកអាចសួរសំនួរដូចគ្នា ដូចសំនួរនៃការសំដែងខាងលើខាងលើ ។

## ការធ្វើចំណាត់ថ្នាក់

តម្រូវការក្នុងសហគមន៍តែងតែបណ្ដាលមកពីកត្តាមួយចំនួនខុៗគ្នា ហើយកត្តានីមួយៗមានទំហំសំខាន់នៃលក្ខណពិសេសមិនស្មើគ្នាទេ ។ ជាការសំខាន់គួរតែគិតពិចារណាអំពីកត្តាទាំងអស់នោះថាតើកត្តាណាខ្លះមានសារសំ ខាន់ជាងគេ ។ ធ្វើដូច្នេះ យើងអាចបញ្ចៀសនូវការចំណាយពេលវេលានិងកំលាំងទៅលើកត្តាណាដែលមិនសូវចាំបាច់ចំពោះការដោះស្រាយចំពោះតម្រូវការ ។



*ការណែនាំជាជំហាន :*

១. កំណត់បញ្ហាដែលអ្នកចង់លើកយកមកពិភាក្សា បន្ទាប់មកធ្វើការបំផុសគំនិតក្រុមទៅលើកត្តាដែលនាំអោយកើតមានបញ្ហានេះ ។

២. សរសេរកត្តាទាំងនេះនៅលើក្រដាសផ្សេងៗពីគ្នា ។

៣. អោយអ្នកចូលរួមបិទក្រដាសទាំងអស់នៅលើក្ដារខៀន ឬជញ្ជាំងដោយរៀបតាមលំដាប់នៃភាពសំខាន់ ។ ផ្តល់ពេលវេលាសម្រាប់ក្រុមពិភាក្សាពីមូលហេតុដែលពួកគាត់ធ្វើចំណាត់ថ្នាក់កត្តាទាំងអស់នេះតាមរបៀបនេះ ។

៤. ធ្វើរបៀបនេះអាចធ្វើអោយយើងទទួលបាននូវការស្វែងយល់កាន់តែច្បាស់ពីរបៀបដែលអ្នកចូលរួមយល់ពីបញ្ហា ។ ប្រសិនបើអ្នកចង់ស្វែងយល់ពីបញ្ហាទាំងនេះអោយកាន់តែស៊ីជម្រៅថែមទៀត អ្នកអាចសួរថាតើការធ្វើ ចំណាត់ថ្នាក់នេះសមស្របសម្រាប់មនុស្សគ្រប់គ្នាឬទេ ឬក៏សម្រាប់តែក្រុមណាមួយ ។

៥. អ្នកអាចនៅតែបន្តប្រើលំហាត់នេះដើម្បីអោយអ្នកចូលរួមធ្វើចំណាត់ថ្នាក់បញ្ហាឬតម្រូវការណាដែលមានសារសំខាន់បំផុតចំពោះសហគមន៍ ដែលធ្វើអោយសហគមន៍ផ្លាស់ប្តូរជាវិជ្ជមាន ។ចូរលើកទឹកចិត្តអ្នកចូលរួមអោយគិតគូរអោយបានច្បាស់លាស់ និងអាចទទួលយកបានចំពោះបញ្ហា ឬតម្រូវការរបស់ពួកគេ បន្ទាប់មកចាប់ផ្ដើមប្រមូលគំនិតទាក់ទងទៅនឹងវិធីនៃការឆ្លើយតបចំពោះតម្រូវការទាំងនោះក្នុងសហគមន៍ ។

***ចំនុចគន្លឹះ :*** *នេះជាលំហាត់មួយដ៏មានសារៈសំខាន់ដែលយើងអាចប្រើនៅដំណាក់កាលផ្សេងៗគ្នានៃគម្រោងដូចជាតើត្រូវដាក់តំរូវការជាអាទិភាពរបស់សហគមន៍នៅពេលណានៅខាងដើមឬចុងគំរោងនិងធ្វើការវាយតំលៃបញ្ចប់គំរោងនៅពេលណាដែរ ។*

## ❖ ជំហានទី៣: ការបង្កើតក្រុមប្រមូលពតិមាន

ផ្នែកបន្ទាប់នៃដំណើរការ គឺនិយាយអំពីការប្រមូលពតិមានពីសហគមន៍ ដែលនឹងជួយអ្នកក្នុងការធ្វើការសម្រេចចិត្តជ្រើសរើសតម្រូវការដែលធំបំផុត និងត្រូវការដោះស្រាយ។ ដើម្បីធ្វើកិច្ចការនេះបាន អ្នកត្រូវបង្កើតក្រុមប្រមូលពតិមាន(ក.ប.ព) ជាមួយគ្នានេះដែរអ្នកត្រូវគិត និងចងចាំក្នុងចិត្តនូវចំនុចមួយចំនួនដូចខាងក្រោម :

១. សមាជិកក្រុមនេះគួរតែជាអ្នកដែលសហគមន៍មានទំនុកចិត្ត និងមានភាពកក់ក្ដៅក្នុងផ្ដល់ពតិមានឬគំនិតផ្សេងៗ។
២. ទំហំក្រុមដែលបង្កើត គឺលំអោនទៅតាមទំហំតំបន់ដែលគេរស់នៅ។
៣. ពួកគេអាចសរសេរ និងរក្សាពតិមានដែលខ្លួនប្រមូលបាន។
៤. ត្រូវអោយមានតំណាងស្ត្រី យុវជន និងអ្នកគេមិនសូវយកចិត្តទុកដាក់បានចូលរួមនៅក្នុងក្រុមនេះដែរ។
៥. បើកវគ្គហ្វឹកហ្វឺនពីរបៀបក្នុងការសម្ភាសន៍ប្រជាជន និងរបៀបកត់ត្រាពតិមានដែលប្រមូលបាន។យកល្អអោយសមាជិកក្រុមអនុវត្តសាកល្បងកិច្ចការនេះជាមុនសិនដើម្បីអោយពួកគេយល់ច្បាស់លាស់ពីតួនាទីរបស់ខ្លួននិងពីអ្វីដែលត្រូវធ្វើ។
៦. មានសំនួរខ្លះពាក់ព័ន្ធនឹងរឿងផ្ទាល់ខ្លួន ដូច្នេះត្រូវរំលឹកដល់ក្រុមប្រមូលពតិមានអោយប្រយ័ត្នចំពោះវិធីសួរសំនួររបស់ខ្លួន ( *មើលផ្នែកនិយាយពីអាកប្បកិរិយានៃការប្រមូលពតិមាននៅទំព័រ៨២ ស.ភ អង់គ្លេស*)។ ជាពិសេសទៅទៀតនោះត្រូវរំលឹកដល់ពួកគេអោយយកចិត្តទុកដាក់ស្តាប់ក្រុមមនុស្សដែលគេពុំសូវយកចិត្តទុកដាក់ មិនចាប់អារម្មណ៍ពីតម្រូវការរបស់ពួកគេ។
៧. ជាកត្តាសំខាន់ក្រុមអ្នកប្រមូលពតិមានត្រូវរំលឹកហើយរំលឹកទៀតដល់សហគមន៍ថាពតិមានដែលប្រមូលបានគឺសម្រាប់អោយពួកគាត់ប្រើ មិនមែនសម្រាប់អ្នកខាងក្រៅប្រើទេ។ប្រការនេះគឺដើម្បីជួយពួកគេអោយចេះធ្វើការសម្រេចចិត្តពីអនាគតរបស់ខ្លួន។



## ផ្នែកទី៣: ការប្រមូលពត៌មាន

### គោលបំណងនៃផ្នែកទី៣:

ដើម្បីសម្របសម្រួលអោយសហគមន៍ប្រមូលពតិមានដែលជាជំនួយដល់ការធ្វើសេចក្ដីសម្រេចចិត្តតាមតម្រូវការ និងធនធាននានាដែលខ្លួនមាន។

### ជំហានគន្លឹះនានា :

១. រៀបចំក្រុមប្រមូលពតិមានដោយអោយគេមើលទៅលើការសិក្សាព្រះគម្ពីរនិងអាកប្បកិរិយានានាដើម្បីប្រមូល។
២. ជ្រើសយកវិធីសាស្ត្រប្រមូលពតិមានពីឧបករណ៍ផ្សេងៗនៅក្នុងផ្នែកនេះ និងពីរបៀបបង្ហាញពតិមានដែលប្រមូលបាន។
៣. ពិនិត្យមើលទៅលើតារាងប្រមូលពតិមាន ហើយជ្រើសរើសវិធីដែលសមស្របបំផុតសម្រាប់អ្នកប្រើក្នុងសហគមន៍របស់អ្នក។



## ជំហានទី១ : ការរុករកអោយឃើញនូវអាកប្បកិរិយាដើម្បីប្រមូលពត៌មាន

- ការសិក្សាព្រះគម្ពីរ– ស្ត្រីនៅឯអណ្តូងទឹក

សូមអាន យ៉ូហាន៤:១-២៦



១. តើមានហេតុការណ៍អ្វីខ្លះកើតឡើងនៅក្នុងរឿងនេះ?
២. តើអ្វីជាភាពខុសគ្នារវាងព្រះយេស៊ូគ្រីស្ទ និងស្ត្រីម្នាក់នេះ ដែលធ្វើអោយព្រះយេស៊ូគ្រីស្ទមានការលំបាកក្នុងការស្តាប់ និងនិយាយទៅកាន់នាង?
៣. តើព្រះយេស៊ូគ្រីស្ទប្រព្រឹត្តយ៉ាងដូចម្តេចចំពោះស្ត្រីម្នាក់នេះ? អ្នកគិតថាវិធីនេះលើកទឹកចិត្ត ឬមិនលើកទឹកចិត្តនាងក្នុងការនិយាយជាមួយព្រះអង្គ?
៤. តើពួកសាវកមានប្រតិកម្មបែបណានៅពេលដែលគេឃើញព្រះយេស៊ូគ្រីស្ទនិយាយជាមួយស្ត្រីនេះ?
៥. តើអ្នកគិតថាយើងគួរមានការភ្ញាក់ផ្អើល និងខ្មាស់អៀនឬទេចំពោះរបៀបនៃការសេពគប់មិត្តរបស់ព្រះយេស៊ូគ្រីស្ទ?
៦. តើយើងធ្លាប់ជៀសវាងនិយាយជាមួយមនុស្សទូទៅឬទេដើម្បីរក្សាកេរ្តិ៍ឈ្មោះរបស់យើងអោយនៅតែល្អ? តើព្រះយេស៊ូគ្រិស្តគួរតែប្រព្រឹត្តយ៉ាងដូចម្តេចចំពោះអ្នកទាំងនោះ?
៧. ទាក់ទងនឹងការប្រមូលពតិមាននៅក្នុងសហគមន៍ តើមេរៀនអ្វីខ្លះពីអត្ថបទគម្ពីរនេះដែលយើងអាចប្រើបានចំពោះអ្នកដែលយើងគួរនិយាយជាមួយ និងស្តាប់ជាមួយ?

**ចំនុចគន្លឹះ :** *ថ្វីបើមានពួកគេមានភាពខុសគ្នាខ្លះៗដូចជា វប្បធម៌ ភេទ សាសនាក៏ដោយ ក៏ព្រះយេស៊ូវនៅតែផ្តល់ពេលវេលាអោយស្ត្រីនោះនៅឯអណ្តូងទឹកដោយទ្រង់ស្តាប់គាត់និងឆ្លើយនូវសំនួរនានារបស់នាងដែរ ។*

- **អាកប្បកិរិយាសំខាន់ៗចំពោះការប្រមូលពត៌មាន**

នៅពេលប្រមូលពតិមាន ការគោរព និងអោយតម្លៃចំពោះអ្នកដែលយើងចង់បានពតិមានពីគាត់គឺជាកត្តាមួយដ៏សំខាន់បំផុត។ ពេលយើងធ្វើដូច្នេះបាន យើងអាចទទួលបានពតិមានដែលមានលក្ខណៈកាន់តែសុក្រិត្យ និងអាចប្រើប្រាស់បានកាន់តែច្រើន ម៉្យាងវិញទៀតការប្រើអាកប្បកិរិយាត្រឹមត្រូវ ធ្វើអោយការប្រមូលពតិមានគឺជាការកសាងទំនាក់ទំនង។

បញ្ជីខាងក្រោមនេះគឺជាអាកប្បកិរិយាមួយចំនួនដែលយើងត្រូវប្រកាន់យកនៅពេលប្រមូលពតិមានពីសហគមន៍។ជាការសំខាន់គួរតែពិភាក្សាទៅលើអាកប្បកិរិយានីមួយៗនិងពីវិធីដែលយើងបង្ហាញនូវអាកប្បកិរិយាទាំងនេះ។



ការបន្ទាបខ្លួន : ទទួលស្គាល់ថាអ្នកដែលយើងត្រូវសម្ភាសន៍មានចំណេះដឹងនិងបទពិសោធន៍ទៅលើអ្វីដែលយើងចង់សួរគាត់ជាងយើង។

ការស្ដាប់ : ប្រើសំនួរបើក កុំនិយាយកាត់ ផ្ដល់ពេលវេលាគ្រប់គ្រាន់ដល់គាត់ក្នុងការនិយាយអ្វីដែលគាត់ពិតជាចង់ និយាយ បង្ហាញថាអ្នកកំពុងស្ដាប់អ្វីដែលគាត់និយាយ។



ការបើកចំហរ : បើកចិត្តស្ដាប់ និងស្វែងយល់ពីគ្រប់មជ្ឈដ្ឋានទាំងអស់ដោយមិនគិតពីជាតិសាសន៍ កាយសម្បទា អាយុ និងភេទ។

ការរក្សាការសំងាត់: គោរពចំពោះបញ្ហាផ្សេងៗផ្ទាល់ខ្លួន។ មិនចែកចាយពតិមានផ្ទាល់ខ្លួនជាសាធារណៈ។

ការច្នៃប្រឌិត : ប្រមូលពតិមានក្នុងបរិយាកាសរីករាយ មិនធុញទ្រាន់ មិនមានការគំរាមកំហែង



ការចង់បានអ្វីដែលល្អបំផុតសម្រាប់សហគមន៍ : មិនត្រូវមានគោលបំណងផ្សេងក្នុងការប្រមូលពតិមានឡើយ។

### ❖ ជំហានទី២ : វិធីសាស្ត្រនៃការប្រមូលពត៌មាន

*ប្រសិនបើអ្នកចង់បានចម្លើយល្អ ត្រូវសួរសំនួរល្អ* (Anonymous)។

ចំនុចសំខាន់បំផុតនៃការប្រមូលពតិមានគឺត្រូវយល់អោយច្បាស់ពីសំនួរដែលអ្នកចង់សួរ។ គួរតែចំណាយពេលជាមួយក្រុមប្រមូលពតិមានដើម្បីពិភាក្សាទៅលើសំនួរគន្លឹះដែលពួកគេត្រូវសួរ។ ពេលដែលយើងគិតពីការប្រមូលពតិមាន ជាការចាំបាច់ត្រូវប្រើវិធីសាស្ត្រមួយចំនួនក្នុងលក្ខណៈជាទូទៅដើម្បីទាញយកពតិមានពីប្រភពសំខាន់ៗចំនួន៣ដែលមានដូចខាងក្រោម :

**អ្នកតំណាងសហគមន៍**
ប្រើការពិភាក្សាក្រុម និងកំរងសំនួរ លំហាត់ផែនទី និងពេលវេលា។



**មន្ត្រីរដ្ឋាភិបាល** រួមមានអ្នកជំនាញផ្នែកសុខភាព អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ប្រើការសម្ភាសន៍ដើម្បីប្រមូលពតិមាន។

**ទិន្នន័យលើបញ្ហានានា** ដូចជា ផ្នែកសុខភាព ការអប់រំ ការចិញ្ចឹមជីវិត និងរកប្រាក់ចំណូល។ ពតិមាននេះមានលក្ខណៈជាតារាងហើយអាចទទួលបានពីអាជ្ញាធរមូលដ្ឋាន។

ប្រភពពតិមានទាំងបីនេះអាចជួយអោយយើងបង្កើតនូវរូបភាពមួយដ៏សមហេតុផលស្តីពីស្ថានភាពនិងតម្រូវការរបស់សហគមន៍។ ការសំខាន់គឺមិនត្រូវប្រើវិធីសាស្ត្រច្រើនពេកទេ គឺប្រើវិធីសាស្ត្រណាដែលមនុស្សគ្រប់គ្នាងាយស្រួលយល់ តែត្រូវចំនាយពេលហាត់សមនូវវិធីសាស្ត្រទាំងនោះជាមួយអស់អ្នកដែលចេញទៅប្រមូលពតិមានវិញ។

## ជំនាញកត់ត្រា និងបង្ហាញពតិមាន

***សេចក្តីផ្តើម :***

ការគិតអំពីរបៀបកត់ត្រាពតិមានគឺជាកិច្ចការមួយដ៏សំខាន់ ដែលយើងអាចប្រើប្រាស់ពតិមានទាំងនេះនៅលើកក្រោយៗទៀតនៅពេលប្រជុំសហគមន៍ និងក្នុងការបង្កើតផែនការនៃគម្រោង។ ម៉្យាងទៀតពតិមានទាំងនេះមានសារៈសំខាន់នៅពេលបញ្ចប់គម្រោងក្នុងការប្រៀបធៀបស្ថានភាពមុន និងក្រោយគម្រោងថាតើមានការផ្លាស់ប្តូរកើតឡើងឬទេ។

***សៀវភៅកត់ត្រាផ្សេងៗ***

ការកត់ត្រានូវអ្វីដែលប្រជាជននិយាយគឺជាកិច្ចការមួយដ៏សំខាន់ តែត្រូវពិនិត្យអោយច្បាស់លាស់ថា អ្នកកត់ត្រាត្រូវតែជាអ្នកដែលអាចសរសេរបានល្អដើម្បីអោយអ្នកដទៃអាចអាន និងយល់បាន។



***ផែនទី***

គួរតែអោយក្រុមប្រមូលពតិមានកត់ត្រាពតិមានទាំងអស់នៅលើផែនទី នេះជាវិធីមួយយ៉ាងល្អក្នុងការធ្វើ អោយប្រជាជនភាគច្រើនអាចយល់ពីពតិមានទាំងនោះ។



***ផ្ទាំងក្រដាសធំៗ***

យើងអាចបង្ហាញពីទិន្នន័យផ្សេងៗនៅលើផ្ទាំងក្រដាសធំៗ ទិន្នន័យទាំនេះរួមមាន ការចូលរៀន អាយុអ្នកបោះបង់ចោលសាលា សមាមាត្រនៃក្មេងស្រី និងក្មេងប្រុសដែលចូលរៀន និងចំនួននៃសត្វចិញ្ចឹមជាដើម។



***រឿងខ្លី ចំរៀង និងកំណាព្យ***

យើងអាចប្រើវិធីសប្បាយរីករាយដើម្បីធ្វើការសរុបលទ្ធផលតាមរយៈរឿងខ្លី ចំរៀង និងកំណាព្យ។ នៅសហគមន៍ខ្លះប្រជាជនអាចប្រើពាក្យដំណាលតគ្នាឬសុភាសិតដើម្បីបង្ហាញពីផ្នែកខ្លះនៃពតិមានដែលប្រមូលបាន។

## ក្រុមពិភាក្សា

***គោលបំណង***

ដើម្បីជួយអោយអ្នកចូលរួមយល់ពីតម្លៃនៃការប្រមូលពតិមានជាក្រុមតូចៗ និងផ្តល់បច្ចេកទេសងាយៗសម្រាប់ធ្វើកិច្ចការនេះ ។



***សេចក្តីណែនាំតាមជំហាន***

១. ត្រូវព្រមព្រៀងជាមួយគ្នាជាមុននូវសំនួរគន្លឹះដែលអ្នកចង់សួរក្នុងការប្រមូលពតិមានទាក់ទងនឹងបញ្ហាជាក់លាក់ណាមួយ ។ ជាមួយគ្នានេះផងដែរអ្នកត្រូវកំណត់ក្រុមមនុស្សដែលអ្នកចង់ពិភាក្សាជាមួយដែលក្រុមទាំងនោះមាន ដូចជា សហព័ន្ធមាតា ក្រុមកសិករ ឬក្លឹបបាល់ទាត់ជាដើម ។

២. ត្រូវពន្យល់ពីគោលបំណង និងតម្លៃនៃការប្រជុំពិភាក្សាគ្នានៅពេលចាប់ផ្តើមការប្រជុំ ។

៣. ត្រូវប្រើសំនួរដើម្បីបំផុសគំនិតអ្នកចូលរួមដោយអោយពួកគាត់ធ្វើការជាក្រុម ២ឬ៣នាក់ក្នុងមួយក្រុម ធ្វើដូច្នេះធ្វើអោយអ្នកចូលរួមទាំងអស់អាចចូលរួមបានទាំងអស់គ្នាតាំងពីពេលចាប់ផ្តើម ។

៤. យើងអាចប្រើវិធីសាស្ត្រផ្សេងៗក្នុងការចាត់ចែងលទ្ធផលនៃការប្រើសំនួរបំផុសដូចជា សរសេរនៅលើក្រដាសធំ ឬសរសេរនៅលើក្រដាសតូចៗ ឬកាត (កាតមួយសរសេរគំនិតមួយ) ។

៥. អោយអ្នកចូលរួមធ្វើការផ្តល់អាទិភាពដល់គំនិតដែលពួកគេបានផ្តល់ព្រមទាំងធ្វើចំណាត់ថ្នាក់អ្វីដែលគេបានផ្តល់ នៅលើក្រដាសធំ ឬបែងចែកកាតរបស់ពួកគេជាក្រុមតាមប្រភេទ ។

៦. នៅពេលដែលធ្វើចំណាត់ថ្នាក់ និងរៀបចំជាអទិភាពនូវគំនិត និងបញ្ហាទាំងនោះរួចហើយ អ្នកអាចបន្តការពិភាក្សាអោយកាន់តែស៊ីជម្រៅថែមទៀត ដោយសួរសំនួរបើកអោយកាន់តែច្រើន និងចំបញ្ហា ដូចជាហេតុអ្វីបានជាពួកគេគិតថាបញ្ហាទាំងអស់នេះគឺជាឫសគល់នៃបញ្ហា និងធ្វើអោយមានផលប៉ះពាល់ ។

*សំនួរខាងក្រោមនេះជាសំនួរដ៏ល្អសម្រាប់ចាប់ផ្តើមការបំផុសគំនិត :*

-តើអ្វីខ្លះជាបញ្ហាលំបាកបំផុតនៅក្នុងសហគមន៏?

-តើអ្វីខ្លះជាឧបសគ្គធ្វើអោយរាំងស្ទះដល់ការអភិវឌ្ឍន៏សហគមន៏?

-តើអ្វីខ្លះជាឱកាសសម្រាប់ធ្វើអោយសហគមន៏មានភាពប្រសើរឡើង?

-តើអ្វីដែលអ្នកចូលចិត្តធ្វើបំផុតដើម្បីជួយសហគមន៏របស់អ្នក?

-តើអ្វីដែលផ្តល់ថាមពលខ្លាំងបំផុតដល់អ្នកសម្រាប់ធ្វើអោយសហគមន៏មានភាពប្រសើរឡើង?

*សំនួរខាងក្រោមនេះគឺជាសំនួរដ៏ល្អសម្រាប់ផ្តល់អទិភាព ឬធ្វើចំណាត់ថ្នាក់ទៅលើចំលើយរបស់អ្នកចូលរួមបន្ទាប់ពីបំផុសគំនិតរួចហើយ :*

-តើបញ្ហាអទិភាពចំនួន៣មានអ្វីខ្លះ?

-តើការលំបាក ឬបញ្ហាណាខ្លះដែលយើងមានសមត្ថភាពក្នុងការដោះស្រាយ?

-តើកិច្ចការណាខ្លះចំនួន៣ដែលយើងមានថាមពល និងចំណាប់អារម្មណ៍បំផុត?

-តើការលំបាកណាខ្លះដែលយើងអាចចាត់ជាក្រុមតាមផ្នែកបាន?

-តើការលំបាកណាខ្លះដែលជារបស់យុវជន មនុស្សចាស់ ឪពុកម្តាយឬអាណាព្យាបាល?

## ❖ ជំហានទី៣ : តារាង និងសំនួរសម្រាប់ការប្រមូលពត៌មាន




សេចក្តីផ្តើម

តារាងខាងក្រោមនេះគឺបង្កើតឡើងដើម្បីជួយដល់ក្រុមប្រមូលពតិមានក្នុងការប្រមូលពតិមានពីសហគមន៍របស់ពួកគេ ។ ពតិមានភាគច្រើនគេអាចប្រមូលបានពីសាលារៀននានា មណ្ឌលសុខភាពនានា អ្នកដឹកនាំមូលដ្ឋានវាក៏មានសារសំខាន់ផងដែរក្នុងការប្រមូលពតិមានបន្ថែមនានាពីមណ្ឌលតំបន់ ដែលមានដូចជា ស្ថិតិសុខភាព ចំនួនប្រជាជន ការអប់ជាដើមរបស់រដ្ឋាភិបាល ។ ពតិមានទាំងនេះយើងអាចធ្វើការប្រមូលមកនិងវិភាគបាន ។នៅពេលប្រមូលនិងវិភាគចប់ គួរតែសរសេរនៅលើផ្ទាំងក្រដាសធំៗឬប័ណ្ណហើយបិទភ្ជាប់នៅលើជញ្ជាំងផ្នែកខាងក្រោយក្រុម ជំនុំ ឬសហគមន៍ដើម្បីអោយប្រជាជនទាំងអស់អាចឃើញពតិមានទាំងនោះ ។អ្នកសម្របសម្រួលគួរចំនាយពេលជាមួយអ្នកតំណាងសហគមន៍ និងក្រុមសម្របសម្រួលសហគមន៍ដើម្បីធ្វើការវិភាគទៅលើពតិមានទាំងនេះ និងកំណត់នូវសំនួរគន្លឹះនានាដើម្បីយកទៅពិភាក្សាជាមួយសហគមន៍ទាំងមូល ។

តារាងទី១ : ប្រជាសាស្ត្រ

| អាយុ | សហគមន៍ | | សរុប |
|---|---|---|---|
| | បុរស | ស្ត្រី | |
| ០-៥ | | | |
| ៦-១៥ | | | |
| ១៦-២១ | | | |
| ២២-៤៩ | | | |
| ៥០-៦៥ | | | |
| ៦៦+ | | | |
| សរុប | | | |

| | បុរស | ស្ត្រី | សរុប |
|---|---|---|---|
| មេម៉ាយ/ពោះម៉ាយ | | | |
| កំព្រាម្តាយ រឺ ឪពុក | | | |
| ជនពិកា | | | |
| កុមារកំព្រា | | | |

តារាងទី២ : គ្រួសារ

| | សរុប | ចំនួនសមាជិកជាមធ្យមក្នុងគ្រួសារ |
|---|---|---|
| គ្រួសារដឹកនាំដោយបុរស | | |
| គ្រួសារដឹកនាំដោយស្ត្រី | | |
| សរុប | | |

តារាងទី៣ : ក្រុមមនុស្សក្នុងសហគមន៍




| ប្រភេទក្រុមមនុស្ស | ចំនួនសមាជិក | សកម្មភាព |
|---|---|---|
| ក្រុមយុវជន | | |
| ក្រុមស្ត្រី | | |
| ក្រុមបុរស | | |
| ក្រុមជួយខ្លួនឯង | | |
| ក្រុមហ៊ុន | | |
| ក្រុមមនុស្សដែលមានជំនឿតែមួយ | | |
| ក្លឹប ( បាល់ទាត់ជាដើម) | | |
| សរុប | | |

តារាងទី៤: ជំងឺឆ្លងទូទៅ

បើសិនអាចធ្វើបាន សូមចុះទៅសួរនៅមណ្ឌលសុខភាពមូលដ្ឋានហើយប្រមូលពតិមានអំពីជំងឺទូទៅ ពីអ្នកធ្វើការនៅមណ្ឌលភូមិ ។ប្រការនេះអាចជាសេចក្តីយោងទៅនឹងសេចក្តីយោងនៃស្ថិតិសុខភាពមូលដ្ឋាននានា ។

| ឈ្មោះជំងឺ | ប្រភេទមនុស្សដែលឆ្លង | ចំនួនអ្នកឆ្លងក្នុងរយៈពេល៦ខែចុងក្រោយ | ផលប៉ះពាល់ទៅលើសហគមន៍ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |



តារាងទី៥ : សេវាកម្មផ្នែកសុខភាព

| ធនធាន | ចំនួន | ទីតាំង | ចំងាយពីសហគមន៍ | ម្ចាស់កម្មសិទ្ធិ |
|---|---|---|---|---|
| មន្ទីរពេទ្យ | | | | |
| មណ្ឌលសុខភាព | | | | |
| ឱសថស្ថាន | | | | |
| គ្លីនិកចល័ត | | | | |
| គ្លីនិកឯកជន | | | | |
| ឱសថស្ថានក្នុងភូមិ | | | | |
| វេជ្ជបណ្ឌិត | | | | |
| គិលានុបដ្ឋាយិកា | | | | |
| បុគ្គលិកគ្លីនិក | | | | |
| អ្នកធ្វើការផ្នែកសុខភាពក្នុងសហគមន៍ | | | | |
| វត្តមាននៃឆ្មបបុរាណ<br>-ទទួលការបណ្តុះបណ្តាល<br>-មិនបានទទួលការបណ្តុះបណ្តាល | | | | |
| កន្លែងលក់ថ្នាំបូរាណ<br>-ចុះឈ្មោះ<br>-មិនបានចុះឈ្មោះ | | | | |
| គ្រូពេទ្យបូរាណ | | | | |
| គ្រូមន្តអាគម | | | | |

តារាងទី៦ : ការសិក្សាអប់រំ

| | ក្មេងប្រុស | ក្មេងស្រី | សរុប |
|---|---|---|---|
| ចំនួនសរុបនៃកុមារគ្រប់អាយុចូលរៀន | | | |
| ចំនួនកុមារបានចូលរៀន | | | |
| ចំនួនកុមារមិនបានចូលរៀន | | | |
| ភាគរយនៃកុមារមិនបានចូលរៀន | | | |
| សរុប | | | |



តារាងទី៧ : បរិក្ខាសម្រាប់ការសិក្សា

| ប្រភេទសាលា | ចំនួន | ចំនួនក្មេងចូលរៀន | | | ចំនួន | |
|---|---|---|---|---|---|---|
| | | ក្មេងប្រុស | ក្មេងស្រី | សរុប | រដ្ឋ | ឯកជន |
| មត្តេយ្យសិក្សា | | | | | | |
| បឋមសិក្សា | | | | | | |
| អនុវិទ្យាល័យ | | | | | | |
| វិទ្យាល័យ | | | | | | |

ក. អាយុដែលកុមារត្រូវចូលរៀន

ខ. តើមានភាពលំអៀងទៅលើភេទឬទេ?.....................................ហេតុអ្វី?.......................................

តារាងទី៨ : បរិក្ខានៅក្នុងសាលាមត្តេយ្យសិក្សា

| បរិក្ខា | សាលាទី១ | សាលាទី២ | សាលាទី៣ |
|---|---|---|---|
| ចំនួនគ្រូ | | | |
| ចំនួនបន្ទប់រៀន | | | |
| តុការិយាល័យ | | | |
| តុសិស្ស | | | |



តារាងទី៩ : ចំនួនកុមារដែលរៀនតាមថ្នាក់និងតាមភេទ

| ថ្នាក់ / ភេទ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | សរុប |
|---|---|---|---|---|---|---|---|---|---|
| | សាលាបឋមសិក្សា ទី១ | | | | | | | | |
| ប្រុស | | | | | | | | | |
| ស្រី | | | | | | | | | |
| សរុប | | | | | | | | | |
| | សាលាបឋមសិក្សា ទី២ | | | | | | | | |
| ប្រុស | | | | | | | | | |
| ស្រី | | | | | | | | | |
| សរុប | | | | | | | | | |

តារាងទី១០ : បរិក្ខានៅក្នុងសាលាបឋមសិក្សា

| បរិក្ខា | សាលាទី១ | | | សាលាទី២ | | |
|---|---|---|---|---|---|---|
| | ចំនួនដែលមាន | តម្រូវការសរុប | ចំនួនសល់ | ចំនួនដែលមាន | តម្រូវការសរុប | ចំនួនសល់ |
| តុការិយាល័យ | | | | | | |
| តុសិស្ស | | | | | | |
| បន្ទប់រៀន | | | | | | |
| កៅអី | | | | | | |
| បង្គន់កុមារា | | | | | | |
| បង្គន់កុមារី | | | | | | |
| លោកគ្រូ | | | | | | |
| អ្នកគ្រូ | | | | | | |
| បន្ទប់បុគ្គលិក | | | | | | |
| ផ្ទះគ្រូ | | | | | | |

តារាងទី១១ : សកម្មភាពនៅសាលាបឋមសិក្សាក្នុងមូលដ្ឋាន

| | ប្រុស | ស្រី | សរុប |
|---|---|---|---|
| ចំនួនសិស្សបញ្ចប់ថ្នាក់បឋមសិក្សា | | | |
| ចំនួនសិស្សដែលអាចចូលអនុវិទ្យាល័យបាន | | | |
| ចំនួនសិស្សជាក់ស្តែងដែលចូលអនុវិទ្យាល័យ | | | |

តើក្នុងសហគមន៍មានសាលាអនុវិទ្យាល័យឬទេ? មាន / មិនមាន

ប្រសិនបើមិនមាន តើសិស្សដែលត្រូវចូលអនុវិទ្យាល័យទៅរៀននៅឯណា?.................................................

ក-អាយុដែលក្មេងច្រើនបំផុតបោះបង់ចោលសាលា :

ខ-មូលហេតុនៃការបោះបង់ចោលសាលា :

ក្មេងប្រុស

:.........................................................................................................................

ក្មេងស្រី

:............................................................................................................................

តារាងទី១២ : បរិក្ខានៅសាលាអនុវិទ្យាល័យ

| បរិក្ខា | អនុវិទ្យាល័យទី១ | | | អនុវិទ្យាល័យទី២ | | |
|---|---|---|---|---|---|---|
| | ចំនួនដែលមាន | តម្រូវការសរុប | ចំនួនសល់ | ចំនួនដែលមាន | តម្រូវការសរុប | ចំនួនសល់ |
| តុការិយាល័យ | | | | | | |
| បន្ទប់រៀន | | | | | | |
| បន្ទប់ពិសោធន៍ | | | | | | |
| បណ្ណាល័យ | | | | | | |
| កៅអី | | | | | | |
| បង្គន់ប្រុស | | | | | | |
| បង្គន់ស្រី | | | | | | |
| លោកគ្រូ | | | | | | |
| អ្នកគ្រូ | | | | | | |
| បន្ទប់បុគ្គលិក | | | | | | |
| ផ្ទះគ្រូ | | | | | | |

តារាងទី១៣ : ចំនួនក្មេងនៅក្នុងសហគមន៍ដែលចូលរៀនសាលាអនុវិទ្យាល័យតាមថ្នាក់ និងភេទ

| ថ្នាក់ / ភេទ | ក | ខ | គ | ឃ | សរុប | ចំនួនក្មេងមិនបានចូលរៀន |
|---|---|---|---|---|---|---|
| ប្រុស | | | | | | |
| ស្រី | | | | | | |
| សរុប | | | | | | |

មូលហេតុក្មេងមិនបានចូលរៀន

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

មូលហេតុក្មេងបោះបង់ចោលសាលា

ក្មេងប្រុស :..............................................................................................................................

..............................................................................................................................................

ក្មេងស្រី

:..............................................................................................................................................

..............................................................................................................................................

តារាងទី១៤ : កំរិតនៃការសិក្សាអប់រំនៃប្រជាជនដែលរស់នៅក្នុងសហគមន៍នេះ

| | ប្រុស | ស្រី | សរុប |
|---|---|---|---|
| បញ្ចប់អនុវិទ្យាល័យ | | | |
| បញ្ចប់សាលាបច្ចេកទេស | | | |
| បញ្ចប់សាកលវិទ្យាល័យ | | | |
| កំពុងរៀននៅសាលាបច្ចេកទេស | | | |
| កំពុងរៀននៅសាកលវិទ្យាល័យ | | | |



តារាងទី១៥ : ចំនួនសត្វចិញ្ចឹម និងការប្រើប្រាស់

| ប្រភេទ | ចំនួន | ការប្រើប្រាស់ | | | | | |
|---|---|---|---|---|---|---|---|
| | | ប្រាក់ | អាហារ | ប្រាក់ជំនួន | ពិធីនានា | ថ្នាំពេទ្យ | ការដឹកជញ្ជូន |
| ហ្វូងគោក្របីក្នុងតំបន់ | | | | | | | |
| ការបង្កាត់ពូជ | | | | | | | |
| ហ្វូងចៀមក្នុងតំបន់ | | | | | | | |
| ការបង្កាត់ពូជ | | | | | | | |
| ហ្វូងពពែក្នុងតំបន់ | | | | | | | |
| ការបង្កាត់ពូជ | | | | | | | |
| ហ្វូងលា | | | | | | | |
| ឃ្មុំផ្លិត | | | | | | | |
| បសុបក្សី | | | | | | | |
| ផ្សេងៗ | | | | | | | |

តារាងទី១៦ : ចំនួន និងសេវាកម្មសត្វចិញ្ចឹម

| ប្រភេទនៃសេវាកម្ម | សរុប | ប្រភេទនៃសេវាកម្ម | សរុប |
|---|---|---|---|
| ការធ្លាក់ចុះនៃហ្វូងគោក្របី | | តូបលក់ថ្នាំបសុសត្វ | |
| ផលប៉ះពាល់ហ្វូងគោក្របី | | សេវាកម្មបន្តពូជសត្វដោយមិនប្រើបា | |
| ភ្នាក់ងារពន្លាតកសិកម្ម | | កន្លែងទុកដាក់ពូជបសុសត្វ | |
| ភ្នាក់ងារបសុសត្វ | | ស្ថានីយ៍ស្រាវជ្រាវ | |

តារាងទី១៧ : ប្រភេទធញ្ញជាតិ និងការប្រើប្រាស់

| ការប្រើប្រាស់ / ប្រភេទ | អាហារ | ប្រាក់ | ការប្រើប្រាស់ផ្សេងៗទៀត | | |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

តារាងទី១៨ : ទិន្នផលជាមធ្យមក្នុងមួយគ្រួសារ

| ប្រភេទធញ្ញជាតិ | ទិន្នផលជាមធ្យមក្នុង១អា | ទិន្នផលជាមធ្យមក្នុង១រដូវ |
|---|---|---|
| | | |
| | | |
| | | |
| | | |

ក-តើនៅខែណាខ្លះដែលប្រជាជនមានស្បៀងអាហារហូបគ្រប់គ្រាន់?.....................................................

ខ-តើនៅខែណាខ្លះដែលប្រជាជនខ្វះស្បៀងអាហារ?...........................................................................

គ-តើសហគមន៍ដោះស្រាយដោយរបៀបណានៅពេលខ្វះស្បៀងអាហារ?..............................................

យើងអាចកំណត់កត្តាទាំងអស់នេះបានតាមរយៈការប្រើប្រាស់ប្រតិទិនប្រចាំរដូវ ។(សូមមើលទំព័រទី៦៨) ។

តារាងទី១៩ : បរិក្ខាផ្នែកសុខភាពអនាម័យ

| បរិក្ខា | ចំនួនគ្រួសារ | | សរុប |
|---|---|---|---|
| | មាន | គ្មាន | |
| បង្គន់ជីកដី | | | |
| ធ្មើរដាក់ចាន | | | |
| ប្រជាជនដែលហូបទឹកឆ្អិន | | | |
| រណ្តៅសំរាម | | | |
| លំនៅដ្ឋានស្អាត | | | |
| បន្ទប់ទឹក | | | |
| សួនគ្រួសារ | | | |



តារាងទី២០ : ប្រាក់ចំណូល

| | ចំនួនម៉ោងធ្វើការជាមធ្យមក្នុង១ខែ | |
|---|---|---|
| | ប្រុស | ស្រី |
| មនុស្សពេញវ័យ | | |
| កុមារ | | |

តារាងទី២១ : និន្នាការ និង ការសង្ខេប

តារាងនេះអាចជួយប្រមូលពតិមានទាំងអស់ដាក់ជាមួយគ្នានិងធ្វើការសង្ខេបវាំដែលបានប្រមូលមកពីសហគមន៍និងតារាងនានា។

| វិស័យ | និន្នាការគន្លឹះ/បញ្ហា ចេញពីទិន្នន័យ | សង្ខេប |
|---|---|---|
| ក. ពតិមានដែលប្រមូលបានពីសហគមន៍<br>*-ឧបករណ៍គូរផែនទីសហគមន៍*<br>*-ប្រវត្តិសហគមន៍*<br>*-រូបភាពសហគមន៍*<br>*-ប្រតិទិនរដូវកាល*<br>*-ដើមឈើបញ្ហា* | | |
| ខ. ចំនួនប្រជាជន<br>*-ប្រជាសាស្ត្រ*<br>*-ចំនួនគ្រួសារ*<br>*-ក្រុមផ្សេងៗ* | | |
| គ. សុខភាព<br>*-ជំងឺឆ្លង*<br>*-សេវាកម្មសុខភាព* | | |
| ឃ. ការអប់រំ<br>*-អក្សរសាស្ត្រ*<br>*-បរិក្ខាអប់រំ*<br>*-ការអប់រំកំរិតមត្តេយ្យ*<br>*-ការអប់រំកំរិតបឋមសិក្សា*<br>*-ការអប់រំកំរិតអនុវិទ្យាល័យ* | | |
| ង. សន្តិសុខស្បៀង | | |

| | | |
|---|---|---|
| *-សត្វចិញ្ចឹម*<br>*-សេវាកម្មសត្វចិញ្ចឹម*<br>*-ការធ្វើកសិកម្ម*<br>*-សុខភាពអនាម័យ* | | |
| ច. មេរោគអេដស៍/ជំងឺអេដស៍<br>*-រូបភាពពីសន្តិសុខស្បៀង* | | |

**ផ្នែកទី៤ : ការវិភាគពត៌មាន**

➤ គោលបំណងនៃផ្នែកទី៤:

ដើម្បីអោយសហគមន៍អាចធ្វើការវិភាគលើគ្រប់ពតិមានដែលប្រមូលបាន និងធ្វើការសន្និដ្ឋានជាចុងក្រោយនូវតម្រូវការ និងធនធានរបស់ពួកគេ។

➤ សេចក្តីផ្តើម:

ការវិភាគពតិមានគឺវាពិតជាការសំខាន់មែនដើម្បីជួយអោយសហគមន៍កំនត់នូវបញ្ហាគន្លឹះនានាជាមួយគ្នាដែលជាតំរូវការដើម្បីដោះស្រាយ ។ការនេះវាពាក់ព័ន្ធទៅនឹងពតិមានទាំងអស់ដែលបានប្រមូលមកហើយព្យាយាមកំនត់នូវប្រធានបទធំៗទូទៅ ។ដំណើរការនេះគួរតែកុំបន្ទាយពេលយូរពេកព្រោះវាអាចធ្វើអោយអ្នកចូលរួមធុញទ្រាន និងអាចខូចផលថែមទៀត ។ដូចច្នេះគួរតែរៀបចំអោយមានពេលសំរាកអោយបានច្រើននិងលេងល្បែងបង្កើនកំលាំងដើម្បីអោយអ្នកចូលរួមទាំងអស់នៅតែមានចិត្តផ្តោតសំខាន់លើដំណើរការនេះ ។មួយវិញទៀត ពេលកំពុងតែធ្វើការវិភាគយើងក៏អាចលើយកបញ្ហាគន្លឹះសង្ខេបមួយចំនួនដែលក្រុមស្វែងរកឃើញដែលគិតថាមានប្រយោជន៍ យកមកវិភាគដែរ ធ្វើដូចនេះ នាំអោយពួកគេអាចយកចិត្តទុកដាក់និងចូលចិត្តចង់ធ្វើជាបន្តទៅទៀត។

➤ ជំហានគន្លឹះ:

១. អញ្ជើញប្រជាជនក្នុងសហគមន៍ទាំងមូលមករួមប្រជុំ ប្រសិនបើអាចធ្វើការសិក្សាព្រះគម្ពីរមុនពេលចាប់ផ្តើមពិភាក្សាគឺជាការល្អ ។តែបើមិនបាន អ្នកគួរតែធ្វើការសិក្សាព្រះគម្ពីរនេះជាមួយសមាជិកក្រុមជំនុំ ពីរបីថ្ងៃសិនមុនប្រជុំជាមួយសហគមន៍ទាំងមូល។

២. ក្រុមសម្របសម្រួលមូលដ្ឋានបង្ហាញពតិមានដែលប្រមូលបានដោយក្រុមប្រមូលពតិមាន។

៣. សម្របសម្រួលការពិភាក្សាទៅលើលទ្ធផលដែលរកឃើញ លើកទឹកចិត្តសហគមន៍អោយវិភាគទៅលើទិន្នន័យនៅក្នុងតារាងថាតើត្រឹមត្រូវឬទេ។

៤. ធ្វើចំណាត់ថ្នាក់បញ្ហាអទិភាពដោយប្រើតារាងកំណត់អទិភាព។

៥. វិភាគទៅលើបញ្ហាអទិភាពមួយឬពីរអោយបានកាន់តែស៊ីជម្រៅថែមទៀតដោយប្រើវិធីសាស្ត្រ "ប៉ុន្តែ/ហេតុអ្វី" ឬដើមឈើបញ្ហា។

៦. សង្ខេប និងកត់ត្រាពីលទ្ធផលនៃការពិភាក្សាដោយប្រើគំរូដែលគេផ្តល់អោយ។



### ❖ ជំហានទី១ : ការសិក្សាព្រះគម្ពីរ-បើកផ្លូវអោយមនុស្សដទៃ

### ⇨ ការពាល់ជាយព្រះពស្ត្រព្រះយេស៊ូ:

*អានលូកា៨:៤០-៥៦*

ថ្វីបើមានភាពឯកា ខ្វះទំនុកចិត្ត និងគេអោយតម្លៃខ្លួនទាបក៏ដោយ ស្ត្រីម្នាក់ខិតខំមុលកាត់ហ្វូងមនុស្សទៅមុខដោយមានបំណងចង់ត្រឹមតែប៉ះជាយអាវក្រៅរបស់ព្រះយេស៊ូគ្រីស្ទប៉ុណ្ណោះ ។ព្រះយេស៊ូ បានឆ្លើយតបទៅនាងវិញដោយផ្តល់ឱកាសអោយនាង ។



### ⇨ សំនួរ:

១. តើព្រះយេស៊ូគ្រីស្ទគ្រាន់តែគិតគូរពីតម្រូវការសាច់ឈាម ឬតម្រូវការព្រលឹងវិញ្ញាណរបស់នាង ឬទាំងពីរ?

២. ចុះបើយើងគិតពីតម្រូវការរបស់សហគមន៍យើងវិញ តើក្រុមជំនុំអាចធ្វើជាអាវក្រៅដើម្បីប្រោសជំងឺ និងផ្តល់ភាពសុខសាន្តដល់អ្នកដែលកំពុងមានតម្រូវការដោយរបៀបណា?

### ⇨ ការឆ្លុះបញ្ចាំង:

ព្រះយេស៊ូគ្រីស្ទប្រទានឱកាសដល់ស្ត្រីដែលមានជំងឺធ្លាក់ឈាមរូបនេះទោះបីជាទ្រង់កំពុងតែយាងទៅប្រោសក្មេងស្រីដែលស្លាប់អោយរស់ឡើងវិញក៏ដោយ ។ ព្រះអង្គប្រទានតម្លៃដល់នាងហើយប្រទានឱកាសអោយនាងនិយាយប្រាប់ពីរឿងរបស់នាង ។ ទ្រង់មានបន្ទូលទៅនាងថា " កូនស្រីអើយ ជំនឿរបស់នាងសង្គ្រោះនាងហើយ សូមអោយ មានសេចក្តីសុខសាន្ត "។ កិច្ចការនេះលើសពីការប្រោសអោយជាទៅទៀត គឺទ្រង់យកចិត្តទុកដាក់ចំពោះតម្រូវការ ពិតប្រាកដរបស់នាងចំពោះសេចក្តីសុខសាន្ត និងភាពគ្រប់ជ្រុងជ្រោយ ។

*ចំនុចគន្លឹះ : ផលលំបាកនានានៅក្នុងសហគមន៍របស់យើងគឺបញ្ហាផ្នែកព្រលឹងវិញ្ញាណ ក៏ដូចជាផ្នែកសាច់ឈាម ហើយព្រះជាម្ចាស់ប្រើក្រុមជំនុំដើម្បីពុះពារ និងយកជ័យជំនះលើអំពើបាបរបស់យើង ព្រមទាំងជួយប្រជាជនដែលកំពុងរងគ្រោះ ។*

### ❖ ជំហានទី២ : ការបង្ហាញពត៌មាន

ក្រុមសម្របសម្រួលមូលដ្ឋានត្រូវពិនិត្យមើលពតិមានដែលប្រមូលបានហើយរៀបចំដាក់លើក្រដាសផ្ទាំងធំៗដែលអាចអោយអ្នកមើលឃើញគេអាចយល់បាន ។ ត្រូវរៀបចំអោយរួចជាស្រេចមុននឹងឡើងបង្ហាញក្នុងអង្គប្រជុំសហគមន៍ ។

បន្ទាប់មកក្រុមនេះដដែលត្រូវរៀបចំការប្រជុំសហគមន៍និងឡើងបង្ហាញពតិមានអោយបាន ច្បាស់លាស់ប្រាប់រាល់ព្រឹត្តិការណ៍ដែលសំខាន់ៗ ។ ត្រូវធ្វើការបង្ហាញតារាងម្តងមួយៗដោយមានអ្នកបង្ហាញផ្សេងៗគ្នាព្រមទាំងពន្យល់ពីរបៀបប្រមូលពតិមាន អ្នកពាក់ព័ន្ធ ការឆ្លើយតបរបស់ប្រជាជន និងផលលំបាកនានាដែលជួបប្រទះ ។




**⇨ ការណែនាំសម្រាប់ការបង្ហាញពតិមាន**

-ត្រូវរៀបចំតារាងនីមួយៗអោយបានច្បាស់លាស់ល្អតាមដែលអាចធ្វើទៅបាន ។

-ត្រូវចែកចាយពតិមានតាមរបៀបងាយយល់តាមដែលអាចធ្វើទៅបាន ក្នុងករណីដែលអ្នកចូលរួមមិនសូវយល់ពីតួលេខ ។ យកល្អពិភាក្សាពីការប្រើភាគរយ និងវិធីបង្ហាញលទ្ធផលដោយប្រើរូបភាព ( អ្នកអាចស្នើសុំគ្រូបង្រៀនគណិតវិទ្យាអោយជួយ ប្រសិនបើមាន) ។

-មុនពេលចាប់ផ្តើមប្រជុំ ជ្រើសរើសអ្នកចូលរួមពីរនាក់អោយឡើងបង្ហាញសម្រាប់តារាងនីមួយៗ ។ លើកទឹកចិត្តអ្នកដែលពុំសូវមានទំនុកចិត្តអោយឡើងបង្ហាញ ។

-ពតិមានទាំងនេះជារបស់សហគមន៍ ដូច្នេះត្រូវរកកន្លែងណាមួយដាក់តាំងពតិមាននេះជាអចិន្ត្រៃយ៍ ។

❖ **ជំហានទី៣ : ការពិភាក្សា**

ក្រោយពីបង្ហាញតារាងនីមួយៗ ត្រូវសួរអ្នកចូលរួមដើម្បីរកឯកភាពទៅលើលទ្ធផលទាំងនេះ ។ប្រសិនបើសមស្រប គួរតែបំបែកអង្គប្រជុំជាក្រុមតូចៗដើម្បីធ្វើការពិភាក្សា ។បន្ទាប់មកទុកពេល សម្រាប់សំនួរ និងចំលើយ ។ ចូរព្យាយាមសួរសំនួរមានដូចខាងក្រោម :

-តើយើងឃើញអ្វីខ្លះនៅក្នុងតារាងនេះ?

-ហេតុអ្វីមានករណីនេះកើតឡើង?

-តើពតិមាននេះមានអត្ថន័យយ៉ាងណា សម្រាប់យើង? តើមានបញ្ហាវិជ្ជមាននិងអវិជ្ជមានអ្វីខ្លះដែលជាទាក់ទង?

-តើសហគមន៍គួរតែធ្វើអ្វីខ្លះ ដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើង?



⇨ **ការណែនាំសម្រាប់ការដឹកនាំការពិភាក្សា:**

-នៅពេលធ្វើការពិភាក្សាទៅលើលទ្ធផល ត្រូវជ្រើសរើសអ្នកទទួលខុសត្រូវសួរសំនួរសំខាន់ៗ ។ អ្នកសួរសំនួរនេះត្រូវការអ្នកដែលពូកែខាងលើកទឹកចិត្ត និងគ្រប់គ្រងការពិភាក្សាជាក្រុមធំ ។ អ្នកចូលរួមទាំងអស់ត្រូវតែចូលរួមការពិភាក្សារួមគ្នាដើម្បីធ្វើសេចក្ដីសន្និដ្ឋានទៅលើសំនួរនីមួយៗ ។

-ត្រូវធានាថានៅពេលបញ្ចប់ការពិភាក្សាប្រជាជនក្នុងសហគមន៍ដឹងច្បាស់ពីធនធាន និងចំនុចខ្លាំងរបស់ខ្លួនព្រមទាំងផលលំបាកដែលយើងជួបប្រទះប្រសិនបើយើងចង់ផ្លាស់ប្ដូរស្ថានភាពអោយមានភាពប្រសើរជាងមុន ។

## ❖ ជំហានទី៤ : ធ្វើចំណាត់ថ្នាក់បញ្ហាអទិភាពនានា

ប្រើសំនួរ និងតារាងខាងក្រោមជាការជួយសម្រួលក្នុងការផ្តើមគំនិតបង្កើតនូវបញ្ជីតម្រូវការអទិភាព វាជាផ្នែកមួយនៃការពិភាក្សា។ យើងអាចសរសេរលទ្ធផលនៃការធ្វើចំណាត់ថ្នាក់នេះនៅលើក្តារខៀន ឬក្រដាសធំៗ អ្នកអាចប្រើវិធីធ្វើចំណាត់ថ្នាក់ ដូចដែលបានបង្ហាញរួចមកហើយនៅទំព័រ ៧២។



តើយើងដឹងថាបញ្ហានេះមានសារៈសំខាន់ ដោយរបៀបណា?

តើនឹងមានអ្វីកើតឡើងប្រសិនបើ យើងមិនរកវិធីដោះស្រាយបញ្ហានេះ?

តើបច្ចុប្បន្នប្រជាជនក្នុងសហគមន៍កំពុងធ្វើអ្វីខ្លះដើម្បីដោះស្រាយបញ្ហានេះ?

តើយើងមានធនធានអ្វីខ្លះដើម្បីដោះស្រាយបញ្ហាទាំងនេះ?

តើអ្នកពិតជាចង់ផ្លាស់ប្តូរបញ្ហានេះពិតមែនឬ?

| ល.រ | បញ្ជីអទិភាព | ហេតុអ្វីវាសំខាន់? | តម្រូវការអ្វីខ្លះត្រូវដោះស្រាយ | សមត្ថភាព និងធនធាន |
|---|---|---|---|---|
| ១-<br>២-<br>៣-<br>៤-<br>៥-<br>៦-<br>៧-<br>៨- | | | | |

❖ **ជំហានទី៥ : ការវិភាគអោយកាន់តែស៊ីជម្រៅ**

នៅពេលដែលអ្នកចូលរួមកំណត់បញ្ហាមួយដែលពួកគេគិតថាអាចរកដំណោះស្រាយបាន គឺយើងត្រូវគិតពិចារណាអោយកាន់តែស៊ីជម្រៅថែមទៀតទៅលើបញ្ហានេះ ។ ប្រការនេះអាចជួយអោយសហគមន៍អាចឆ្លើយតបទៅនឹងតម្រូវការនេះបាន ។ វិធីមួយក្នុងការធ្វើកិច្ចការនេះគឺត្រូវប្រើពាក្យ "ប៉ុន្តែ ហេតុអ្វី " ឬ ដើមឈើបញ្ហាដែល អាចជួយយើងអោយរកឃើញនូវឫសគល់ដ៏ជាក់លាក់នៃបញ្ហានេះ ។

⇨វិធីសាស្ត្រប្រើពាក្យ "ប៉ុន្តែ ហេតុអ្វី ? "

អ្វីដែលយើងត្រូវការសម្រាប់ប្រើវិធីសាស្ត្រនេះគឺ ក្រដាស ហ្វីត និងអ្នកសម្របសម្រួលម្នាក់ដែលមានតួនាទីក្នុងការសួរសំនួរទៅកាន់អ្នកចូលរួម ។ លំហាត់នេះចាប់ផ្តើមដោយ អ្នកត្រូវសួរពីបញ្ហាដែលបានរកឃើញតាមរយៈការប្រមូលពត៌មាន ។ រួចហើយអ្នកសួរពីមូលហេតុដែលធ្វើអោយបញ្ហានេះកើតឡើង ពេលអ្នកចូលរួមឆ្លើយចំពោះសំនួរនេះ អ្នកត្រូវសួរពួកគេបន្តទៀតថា "ប៉ុន្តែ ហេតុអ្វី ? "។ អ្នកត្រូវបន្តសួរសំនួរនេះរហូតដល់អ្នកទទួលបានចំលើយយ៉ាងច្បាស់លាស់ពីឫសគល់នៃបញ្ហាដែលកើតមានឡើង ។ សូមមើលឧទាហរណ៍ខាងក្រោម :

ប្រជាជនឈឺ

*ប៉ុន្តែ ហេតុអ្វី?*

ទឹកកខ្វក់

*ប៉ុន្តែ ហេតុអ្វី?*

គ្មានប្រភពទឹកដែលមានការការពារ

*ប៉ុន្តែ ហេតុអ្វី?*

គ្មានប្រាក់សម្រាប់ចំណាយលើការការពារប្រភពទឹក

*ប៉ុន្តែ ហេតុអ្វី?*

សហគមន៍មិនបានរៀបចំប្រមូលប្រាក់សម្រាប់ចំណាយលើកិច្ចការនេះទេ ។

*ប៉ុន្តែ ហេតុអ្វី?*

សហគមន៍គ្មានការដឹកនាំ ឬទស្សនៈវិស័យសម្រាប់កិច្ចការនេះទេ

*ប៉ុន្តែ ហេតុអ្វី?*

គ្មានអ្នកណាគិតថាបញ្ហានេះជាបញ្ហាធំនោះទេ

ប្រសិនបើក្រុមធ្វើលំហាត់នេះដោយជោគជ័យ នោះនឹងមានភាពកាន់តែងាយស្រួលថែមទៀតចំពោះវិធីសាស្ត្រទី២ គឺដើមឈើនៃបញ្ហាពីព្រោះមានលក្ខណៈស្រដៀងគ្នា ។

⇨ ការវិភាគដើមឈើបញ្ហា :

នេះគឺជាវិធីសាស្ត្រកាន់តែមានភាពស៊ីជម្រៅថែមទៀតនៃ វិធីសាស្ត្រ " ប៉ុន្តែ ហេតុអ្វី "ដែលមានដូចខាងក្រោម :



១.កំណត់បញ្ហា



២.ពណ៌នាពីផលប៉ះពាល់



៣.ពណ៌នាពីឫសគល់បញ្ហា



៤.អ្នកទទួលបានដើមឈើបញ្ហាមួយដើម

➡ *របៀបបង្កើតដើមឈើបញ្ហា:*

តាមរយៈបញ្ហាសំខាន់ៗដែលទទួលបានការព្រមព្រៀងតាមរយៈការពិភាក្សារួចមក សរសេរលទ្ធផលទាំងនោះនៅលើដើមឈើដោយចែកជាបីផ្នែក ។ ផ្នែកទី១គឺ ផលប៉ះពាល់ដែលមកពីបញ្ហាដែលកើតមានឡើង ត្រូវសរសេរនៅលើស្លឹក និងមែក យើងអាចសរសេរលើក្រដាសតូចៗហើយយកទៅបិតក៏បាន ។

បន្ទាប់មកសរសេរឫសគល់នៃបញ្ហានៅត្រង់ឫសនៃដើមឈើដោយប្រើក្រដាសតូចៗយកទៅបិត ។ លើកទឹកចិត្តអោយអ្នកចូលរួមពិភាក្សាបញ្ចេញយោបល់ទៅលើកិច្ចការនេះ ។ ត្រូវគូសបន្ទាប់ភ្ជាប់ពីឫសគល់បញ្ហាទៅផលប៉ះពាល់ដើម្បីបង្ហាញពីទំនាក់ទំនងរបស់វា ។

➡ *របៀបប្រើដើមឈើបញ្ហា:*

យើងប្រើដើមឈើបញ្ហាដើម្បីគិតពិចារណាថាតើក្រុមជំនុំ ឬសហគមន៍គួរដោះស្រាយលើផលប៉ះពាល់ ឬ ឫសគល់នៃបញ្ហា ។ ជាទូទៅការដោះស្រាយទៅលើផលប៉ះពាល់គឺងាយស្រួលជាង ប៉ុន្តែទទួលបានលទ្ធផលរយៈពេលខ្លី ចំណែកឯការដោះស្រាយទៅលើឫសគល់បញ្ហាគឺមានភាពលំបាកជាង និងត្រូវជួបប្រទះការលំបាកជាច្រើន ប៉ុន្តែមាននិរន្តរភាពចំពោះការផ្លាស់ប្តូរ ។

⇨ ឧទាហរណ៍ទី១ : ដើមឈើបញ្ហានៃការខ្វះខាតទឹកស្អាត :

ខាងក្រោមនេះគឺជាឧទាហរណ៍នៃការបង្កើតដើមឈើបញ្ហា។ លោកអ្នកអាចប្រើឧទាហរណ៍នេះដើម្បីពិចារណាថាតើក្រុមជំនុំរបស់អ្នកអាចឆ្លើយតបចំពោះផលប៉ះពាល់ ឬឫសគល់នៃបញ្ហាបានល្អក៏រិតណា។

**ផលប៉ះពាល់**




**ឫសគល់បញ្ហា**

⇨ ឧទាហរណ៍ទី២ : ដើមឈើបញ្ហានៃការរើសអើងអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ :

លោកអ្នកអាចប្រើឧទាហរណ៍នេះដើម្បីអោយក្រុមជំនុំអ្នកពិចារណាពីរបៀបដែលគេអាចឆ្លើយតបទៅនឹងបញ្ហាណាមួយ តើគួរឆ្លើយតបទៅនឹងឬសគល់បញ្ហា ឬក៏ ផលប៉ះពាល់ ។



### ❖ ជំហានទី ៦ : ការសរសេរព័ត៌មាន

នៅពេលអ្នកបានមើលព័ត៌មានទាំងអស់ និងទាញយកសេចក្តីសន្និដ្ឋានខ្លះៗហើយ នោះវាពិតជាសំខាន់ ដើម្បីសរសេរវាទាំងអស់ទុកនៅក្នុងរបាយការណ៍ខ្លីមួយ ។




នេះជាទូទៅត្រូវបានសំដៅទើលើរបាយការដំបូង ពីព្រោះវាជួយឱ្យអ្នកអាចធ្វើការប្រៀបធៀបពីស្ថានភាពបច្ចុប្បន្ន ទៅនឹងស្ថានភាពនៅពេលអនាគត ។

ប្រសិនបើនៅថ្ងៃអនាគត អ្នកទទួលបានមូលនិធិពីម្ចាស់ជំនួយ នេះពិតជាព័ត៌មានសំខាន់ ដើម្បីប្រើប្រាស់នៅពេលធ្វើរបាយការណ៍ទៅពួកគេអំពីការរីកចម្រើននៃគម្រោងសហគមន៍របស់អ្នក ។

**រចនាសម្ព័ន្ធសម្រាប់របាយការណ៍ដំបូងរបស់អ្នក**

១.ឈ្មោះ និងអាស័យដ្ឋានរបស់សហគមន៍ ។

២.កាលបរិច្ឆេទប្រជុំនិងវត្តមានអ្នកចូលរួម ។

៣.ពិពណ៌នាដោយសង្ខេបនូវលទ្ធផលចំបងៗទាំងអស់ (អ្នកអាចបញ្ចូលតារាងមួយចំនួនដែលបង្ហាញភស្តុតាងច្បាស់លាស់ចំពោះបញ្ហា) ។

៤.ការសន្និដ្ឋានគោល(ដើមឈើបញ្ហាអាចត្រូវបានប្រើប្រាស់ដើម្បីពន្យល់ពីចំនុចចំបងៗ) ។

៥.ការផ្តល់អនុសាសន៍សម្រាប់អនាគត ។

### ផ្នែកទី ៥ : ការសិក្សា និងការឆ្លុះបញ្ចាំង

ផ្នែកនេះសំខាន់ខណៈដែលក្រុមជំនុំ និងសហគមន៍ត្រូវការដើម្បីពិនិត្យឡើងវិញ ហើយឆ្លុះបញ្ចាំងទៅមើលថាតើអ្វីខ្លីដែលធ្វើបានល្អ ហើយអ្វីខ្លះដែលត្រូវការធ្វើឱ្យប្រសើរឡើង តាមវិធីដែលពួកគេបានរៀន និងធ្វើការជាមួយគ្នា។

**ការឆ្លុះបញ្ចាំងទៅលើផ្នែកទី ១ : តើយើងគួរតែធ្វើការងារយ៉ាងដូចម្តេចជាមួយសហគមន៍របស់យើង?**

១. តើយើងបានរៀនអ្វីខ្លះ អំពីរបៀបដែលយើងធ្វើការជាមួយសហគមន៍របស់យើង?

២. តើយើងអាចជួយក្រុមជំនុំ និងសហគមន៍ឱ្យធ្វើការជាមួយគ្នាកាន់តែមានប្រសិទ្ធភាពនៅថ្ងៃអនាគតយ៉ាងដូចម្តេច?

៣. តើយើងបានបញ្ចូលអ្នកដែលងាយរងគ្រោះ និងអ្នកទីទាល់ក្រទៅក្នុងការពិភាក្សា និងការប្រមូលព័ត៌មានរបស់យើងដែរឬទេ?

**ការឆ្លុះបញ្ចាំងលើផ្នែកទី ២ : ការពិព័ណ៌នាអំពីសហគមន៍**

១. តើយើងបានពិព័ណ៌ពីសហគមន៍ និងកំណត់ចំណុចខ្លាំង និងតម្រូវការរបស់វាបានត្រឹមត្រូវដែរឬទេ?

២. តើមតិយោបល់របស់អ្នកគ្រប់គ្នា តំណាងឱ្យការពិព័ណ៌នារបស់យើងអំពីសហគមន៍ដែរឬទេ?

៣. តើឧបករណ៍ (មតិយោបល់) ទាំងនោះមានប្រយោជន៍ដែរទេ? តើយើងអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឱ្យវាកាន់តែមានប្រសិទ្ធភាព?

**ការឆ្លុះបញ្ចាំងលើផ្នែកទី ៣ : ការប្រមូលព័ត៌មាន**

១. តើយើងបានបង្កើតគំនិតអំពីកម្មសិទ្ធភាពដែរឬទេ ខណៈដែលប្រមូលព័ត៌មានពីសមាជិកសហគមន៍?

២. តើយើងគិតថា យើងទទួលបានព័ត៌មានគ្រប់គ្រាន់ពីសហគមន៍ដែរឬទេ? ប្រសិនបើអត់ទេ តើមានប្រភពនៃព័ត៌មានផ្សេងទៀត ដែលយើងគួរតែប្រើដែរឬទេ?

**ការឆ្លុះបញ្ចាំងលើផ្នែកទី ៤ : ការវិភាគព័ត៌មាន**

១. តើសហគមន៍បានយល់ព័ត៌មានទាំងអស់ ដែលយើងបានបង្ហាញទៅពួកគាត់ដែរឬទេ? តើមានការយល់ដឹងដែលត្រូវបានចែកចាយអំពីអ្វីដែលជាបញ្ហាចម្បងដែរឬទេ?



# ដំណាក់កាលទី៣:

## សុបិន្តនិមិត្តនិងការរៀបចំផែនការសកម្មភាព



## ❖ ទិដ្ឋភាពទូទៅនៃដំណាក់កាលទី៣ : សុបិន្តនិម្មិត និង ការរៀបចំផែនការសកម្មភាព

គោលបំណងនៃដំណាក់កាលនេះ :

ដើម្បីជួយអោយប្រជាជនដឹងពីសុបិន្តនិម្មិតរបស់ពួកគាត់តាមរយៈការបង្កើតផែនការសកម្មភាពជាក់ស្តែង នៅក្នុងដំណាក់កាលនេះចែកចេញជាបួនផ្នែកធំៗដូចខាងក្រោម :




ជាមួយនឹងដំណាក់កាលទី២: ការបង្កើតនិមិត្តដល់សហគមន៍ មានការសិក្សាព្រះគម្ពីរក្នុងដំណាក់កាលនេះ ដែលយើងអាចប្រើប្រាស់បានជាមួយក្រុមជំនុំ ឬក៏ក្រុមជំនុំនិងសហគមន៍បានត្រឹមត្រូវ ។

### ❖ ផ្នែកទី១ : ការសុបិន្តនិម្មិត

### ➢ គោលបំណងនៃផ្នែកទី១:

ដើម្បីផ្តល់ឱកាសអោយប្រជាជនគ្រប់គ្នាដែលពាក់ព័ន្ធធ្វើការស្រមៃពីវិធីសាស្ត្រដ៏ល្អបំផុតក្នុងការឆ្លើយតបទៅនឹងតម្រូវការនានាដែលបានរកឃើញនៅក្នុងសហគមន៏ ។

ប្រសិនបើអ្នកចង់ធ្វើកិច្ចការនេះដោយអមជាមួយការសិក្សាព្រះគម្ពីរ សូមប្រើការសិក្សានៅទំព័របន្ទាប់ ។

### ➢ សេចក្តីផ្តើមការស្រមើស្រមៃ:

នៅក្នុងផ្នែកនេះគឺជាការផ្តល់ឱកាសដល់អ្នកចូលរួមនឹកស្រមៃពីដំណោះស្រាយខ្លះៗចំពោះបញ្ហាដែលពួក គាត់បានរកឃើញនៅក្នុងដំណាក់កាលមុនៗ ។ គ្រោះថ្នាក់តែងតែកើតមានឡើងនៅពេលដែលយើងរកតម្រូវការឃើញហើយ យើងរកដំណោះស្រាយភ្លាមៗតែម្តង ។ តាមបទពិសោធន៏របស់យើងគឺយើងផ្តល់ឱកាសដល់អ្នកចូល រួមដើម្បីនឹកស្រមៃពីកិច្ចការផ្សេងៗជុំវិញបញ្ហាទាំងនោះ ដែលអាចធ្វើអោយយើងរកឃើញនូវដំណោះស្រាយដែលយើងមិនបានគិតដល់ ។ ជាពិសេសនេះគឺជាការបើកចិត្តទទួលយកការដឹកនាំនិងជំរុញរបស់ព្រះជាម្ចាស់ទៅលើវិធី សាស្ត្រដែលយើងត្រូវអនុវត្តន៏ ។ ជាមួយគ្នានេះដែរយើងក៏ត្រូវការពេលវេលាខ្លះដើម្បីធ្វើការសម្រេចចិត្តជ្រើសរើស វិធីសាស្ត្រដែលសមស្របក្នុងការឆ្លើយតបទៅនឹងបញ្ហាដែលយើងបានរកឃើញ ។



ដំណាក់កាលនេះត្រូវរួមបញ្ចូលទាំងសម្ភារៈផ្សេងៗដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកចូលរួមក្នុងនឹកគិតពី រូបភាពនៃការស្រមៃរបស់ពួកគាត់ និងអាចអោយពួកគាត់ចែកចាយជាមួយអ្នកដទៃមុននឹងឈានដល់ការធ្វើសេចក្តីលំអិតនៃផែនការគម្រោង ។



កិច្ចសិក្សា : នៅតំបន់ដាច់ស្រយាលនៃប្រទេសកេនយ៉ា ពួកកុលសម្ព័ន្ធម៉ាស៊ី បង្កើតគម្រោងស្រដៀងនឹង យូម៉ូចាដែរ ។ ពួកគេនឹកស្រមៃចង់បានបណ្តាញទូរស័ព្ទផ្ទាល់ខ្លួនដែរ ។ អ្នកសម្របសម្រួលព្យាយាមលួងលោមពន្យល់ពួកគេកុំអោយនឹកគិតពីការស្រមៃដែលមិនកើតឡើងនេះបន្តទៀត ។ ប៉ុន្តែក្នុងកំឡុងពេល១៨ខែពួកគេទទួលបានបង្គោលបណ្តាញចែកចាយទូរស័ព្ទចល័តពីអ្នកផ្គត់ផ្គង់បណ្តាញធំ ។ ឥឡូវនេះពួកគេទទួលបានសេវាគ្របដណ្តប់យ៉ាងល្អមិនគួរអោយជឿ ព្រមទាំងមានប្រភពសម្រាប់សាកទូរស័ព្ទទៀតផង ។

### ➢ *សេចក្ដីណែនាំតាមជំហានសម្រាប់ការសុបិន្តនិម្មិត:*

១. រកទីកន្លែងដែលមានភាពងាយស្រួល និងអាចបន្ធូរអារម្មណ៍បាន។

២. ប្រាប់អ្នកចូលរួមទាំងអស់ថាពួកគេនឹងត្រូវចំណាយមួយពេលដើម្បីធ្វើការស្រមៃពីដំណោះស្រាយដ៏ល្អបំផុតចំពោះតម្រូវការដែលពួកគេរកឃើញនៅក្នុងសហគមន៍។

៣. អញ្ជើញអ្នកចូលរួមអោយទៅកន្លែងដែលអ្នកបានរៀបចំ រួចហើយអនុញ្ញាតអោយពួកគាត់ជ្រើសទីតាំងដែលពួកគាត់ពេញចិត្ត ធ្វើអោយពួកគាត់មានភាពកក់ក្ដៅ និងលើកទឹកចិត្តពួកគាត់អោយធ្វើការស្រមៃ។

៤. ក្រោយពីរយៈពេល១ម៉ោង ឬតាមពេលដែលអ្នកផ្ដល់អោយពួកគាត់ ស្នើសុំអោយពួកគាត់សរសេរ ឬគូរពីក្ដីស្រមៃរបស់គាត់នៅលើប័ណ្ណតូចៗ។

៥. បែងចែកអ្នកចូលរួមជាក្រុមតូចៗដោយអោយពួកគាត់សំដែងរឿងខ្លី ឬគូររូបភាពស្ដីការស្រមៃរបស់ពួកគាត់ដើម្បីចែកចាយគ្នាទៅវិញទៅមក។

៦. ពិភាក្សាក្រុមធំទៅលើការស្រមៃរបស់ពួកគាត់ ហើយរកវិធីសាស្ត្រដាក់ចំណាត់ថ្នាក់ឬរួមបញ្ចូលការស្រមៃទាំងនោះអោយទៅជាតែមួយ។

➢ ការសិក្សាព្រះគម្ពីរ : សេចក្តីសង្ឃឹមសម្រាប់អនាគត

សូមអាន សាការី៨:៣-២៣

អត្ថបទគម្ពីរនេះនិយាយអំពីការសន្យាប្រទានពរដល់ក្រុងយេរូសាឡិមរបស់ព្រះអម្ចាស់ ។ ព្រះអង្គគូររូបភាពពីរបៀបដែលក្រុងយេរូសាឡិមទទួលព្រះពរ ។

១. ស្នើរអោយអ្នកចូលរួមសរសេរពីព្រះពរទាំងនោះ ឬគូររូបភាពក្រុងយេរូសាឡិមនាពេលអនាគត ។



២. បន្ទាប់មកអោយពួកគាត់រូបភាពអនាគតនៃសហគមន៍ដែលពួកគាត់ចង់បាន ។

៣. ជំហានបន្តអោយពួកគាត់ ធ្វើការជាដៃគូរបង្ហាញរូបភាពដល់គ្នាទៅវិញទៅមក ចុងបញ្ចប់អោយពួកគាត់ខ្លះៗបង្ហាញរូបភាពដល់ក្រុមធំ ។



## ការណែនាំនិងអនុសាសន៍ដែលមានប្រយោជន៍

- អ្នកសម្របសម្រួលគួរតែជួយជំរុញអោយសហគមន៍ពិចារណាស៊ីជម្រៅទៅលើបញ្ហាដែលពួកគេរកឃើញនិងធ្វើការនឹកស្រមៃពីដំណោះស្រាយដែលអាចកើតឡើង ។
- សហគមន៍មួយចំនួនយករូបភាពស្រមៃនៃសហគមន៍របស់ពួកគេនាពេលអនាគតមករចនា និងតុបតែងយ៉ាងស្អាត បន្ទាប់មកយកទៅតាំងនៅកន្លែងសាធារណៈណាមួយដែលមានសុវត្ថិភាព ហើយប្រជាជនទាំងអស់ក្នុងសហគមន៍អាចមើលឃើញនេះចាត់ទុកជាការជំរុញនិងលើកទឹកចិត្ត និងឆន្ទៈរបស់ប្រជាជនអោយខិតខំដើម្បីធ្វើអោយមានការផ្លាស់ប្តូរកើតឡើង ។
- អ្នកសម្របសម្រួលត្រូវតែជួយជំរុញសហគមន៍គិតទៅលើបញ្ហា ឬភាពប្រថុយប្រថានដែលអាចកើតមានឡើងចំពោះគម្រោងថ្មីនេះដែលបណ្តាលមកពីបរិស្ថានជុំវិញ ឬសហគមន៍ដទៃទៀត ។ ឧទាហរណ៍ជាក់ស្តែងដូចជាសហគមន៍ដទៃទៀតបានប្រើប្រាស់ប្រភពទឹករបស់សហគមន៍ដែលធ្វើអោយទឹករីងមិនអាចផ្គត់ផ្គង់តទៅ ទៀតបាន ។
- កិច្ចការសំខាន់មួយទៀតដែលអ្នកសម្របសម្រួលត្រូវអោយប្រជាជនគិតពិចារណាគឺរបៀបដែលក្តីស្រមៃរបស់ពួកគាត់សមស្របជាមួយនឹងគុណតម្លៃនៃក្រុមជំនុំនិងសហគមន៍ ។

## ❖ ផ្នែកទី២ : បញ្ជាក់អោយច្បាស់ពីអ្វីដែលនឹងត្រូវធ្វើ

### ➢ *គោលបំណងនៃផ្នែកទី២:*

ដើម្បីជួយអោយប្រជាជនគិតគូរអោយបានច្បាស់លាស់ និងប្រុងប្រយ័ត្នទៅលើគម្រោងដែលខ្លួនចង់ធ្វើ ដូច្នេះអាចធ្វើអោយពួកគាត់យល់កាន់តែស៊ីជម្រៅចំពោះការចូលរួម និងភាពជាម្ចាស់នៃក្រុមជំនុំ និងសហគមន៍។

### ➢ *ជំហានគន្លឹះ :*

១. បើអាចធ្វើបាន គួរតែសិក្សាព្រះគម្ពីរ នៅអេសាយ៦៥។

២. សូមប្រើត្រីកោណនៃការស្រមៃដើម្បីបំផុសពីមធ្យោបាយផ្សេងៗដែលត្រូវការដើម្បីសម្រេចបាននូវក្តីស្រមៃ។

៣. សូមប្រើលំហាត់ដើរផ្សារដើម្បីអោយអ្នកចូលរួមទាំងអស់មានឯកភាពគ្នា និងដើម្បីប្រមូលនូវគំនិតថ្មីៗដែលអាចមានប្រយោជន៍ចំពោះគម្រោង។



## ➢ ជំហានទី១ : ការសិក្សាព្រះគម្ពីរ

### ⇨ និមិត្តរបស់អេសាយ

សូមអានអេសាយ៦៥ :១៧-២៥

នៅពេលដែលគ្រោះកាចជាច្រើនបំរុងនឹងកើតមានឡើងចំពោះប្រទេសអ៊ីស្រាអែល ព្រះជាម្ចាស់មានព្រះបន្ទូលតាមរយៈលោកអេសាយប្រទាននូវទំនាយយ៉ាងអស្ចារ្យសម្រាប់អនាគតរបស់អ៊ីស្រាអែល ។



១-តើការផ្លាស់ប្តូរអ្វីខ្លះដែលព្រះជាម្ចាស់សន្យាប្រទានមក?

២-តើគ្រោះកាចអ្វីខ្លះដែលនឹងត្រូវបញ្ឈប់?

៣-តើកិច្ចការល្អអ្វីខ្លះដែលនឹងចាប់ផ្តើមកើតឡើង?

៤-តើអ្នកមានសេចក្តីសង្ឃឹមអ្វីខ្លះសម្រាប់សហគមន៍របស់អ្នក?

៥-តើផ្នែកណាខ្លះនៃនិមិត្តរបស់លោកអេសាយដែលអ្នកចង់អោយកើតឡើងសម្រាប់សហគមន៍របស់អ្នក?

៦-តើអ្នកសេចក្តីសង្ឃឹម ឬសុបិន្តនិមិត្តផ្សេងៗទៀតសម្រាប់សហគមន៍របស់អ្នកឬទេ? បើមានតើអ្វីខ្លះ?

៧-តើព្រះទ្រង់មានព្រះតំរិះផ្លាស់ប្តូរយ៉ាងដូចម្តេច ក្នុងការបំពេញសំរេចតាមរយះសេចក្តីសន្យានៅថ្ងៃមួយ? តើអ្នកធ្វើអ្វីខ្លះហើយឥឡូវនេះ?

***ចំនុចគន្លឹះ : ព្រះទ្រង់បានមានបន្ទូលសន្យាយ៉ាងអស្ចារ្យពីការផ្លាស់ប្តូរមួយដែលមិនគួរអោយជឿដល់ប្រជារាស្ត្រអ៊ីស្រាអែល ព្រមទាំងសន្យាធ្វើការនេះដល់សហគមន៍យើងផងដែរ ។***

## ➢ ជំហានទី២ : ត្រីកោណនៃការស្រមៃ :

បន្ទាប់ពីក្រុមទាំងមូលឯកភាពគ្នាលើការស្រមៃសម្រាប់អនាគតរួច ចូរបំផុសគំនិតពួកគេពីមធ្យោបាយផ្សេងៗ ដើម្បីធ្វើអោយការស្រមៃបានសម្រេច ។បន្ទាប់មកបែងចែកមធ្យោបាយទាំងនោះជាក្រុមតាមសំនួរនៅលើត្រី កោណដូចខាងក្រោម ។ គួរតែគូរត្រីកោណនេះអោយធំដើម្បីអោយអ្នកចូលរួមងាយស្រួលក្នុងការមើលនូវគំនិត ផ្សេងៗ ។ម៉្យាងវិញទៀតអាចជួយអោយក្រុមទាំងមូលជ្រើសរើសមធ្យោបាយជាអទិភាពដែលពួកគេអាចធ្វើដោយ ខ្លួនឯងបានយ៉ាងល្អបំផុត ។

**តើយើងចង់អោយអ្នកដទៃជួយអ្វីខ្លះ**
**ដល់យើង?**
ឧទាហរណ៏: អនុសាសន៏ពីអាជ្ញាធរ
មូលដ្ឋានឬពីស្ថាប័នផ្សេងៗស្តីពី
ទឹកនិងអនាម័យព្រមទាំងកសិកម្ម ។

**តើយើងត្រូវធ្វើការជាមួយសហគមន៏ណាទៀតដែរឬទេ**
**និងគេមានធនធានអ្វីខ្លះអាចចែករំលែកអោយយើងបាន?**
ឧទាហរណ៏: ដូចជាពីនិកាយផ្សេងៗឬសាសនាផ្សេងៗ គេអាចចែករំលែក
បទពិសោធន៏និងធនធានរបស់ពួកគេបានដែរ ដូចជា អាគារ និងសំភារះបរិក្ខារនានា ។

**តើកិច្ចការអ្វីខ្លះដែលយើងអាចធ្វើបានដោយខ្លួនឯង**
**និងជាមួយធនធានអ្វីខ្លះ?**
ឧទាហរណ៏: ជីកអណ្តូងទឹក ធ្វើចំការដំណាំ សង់ជង្រុកស្រូវ ដោយមានការចូលរួមពី
អ្នកភូមិយើង និងសំភារះដែលយើងមាន ។



## ➢ ជំហានទី៣ : ដើរផ្សារ

**គោលបំណង**

សកម្មភាពនេះបង្កើតឡើងដើម្បីអោយដឹងថាតើអ្នកចូលរួមមានការប្តេជ្ញាចិត្តយ៉ាងណាចំពោះគំនិតនៃផ្តួចផ្តើមគម្រោងនេះ។ សូមមើលការពិពណ៌នាខាងក្រោម បន្ទាប់មកគូរជារូបភាព ឬសរសេរនៅលើប័ណ្ណតូចៗបិទនៅលើជញ្ជាំងជុំវិញបន្ទប់ រួចហើយស្នើអោយអ្នកចូលរួមដើរមើលប័ណ្ណទាំងនេះដោយសញ្ជឹងគិតទៅលើគម្រោង។



១. នៅផ្ទះ មិនមានចំណូលចិត្តដូចទៅផ្សារ (មិនចាប់អារម្មណ៍ទៅលើគម្រោង)។
២. កំពុងតែធ្វើដំណើរទៅចំណតរថយន្តក្រុង (គិតថានេះជាគំនិតមួយដ៏ល្អប៉ុន្តែមិនទាន់មានការប្តេជ្ញាចិត្តពិតប្រាកដនៅឡើយទេ)។
៣. ឡើងរថយន្តក្រុង (ប្តេជ្ញាចិត្តរួចហើយប៉ុន្តែនៅត្រូវការពតិមានបន្ថែមទៀត)។
៤. កំពុងនៅលើរថយន្តរីករាយនឹងមើលទេសភាពតាមផ្លូវតាមបង្អួច (ប្តេជ្ញាចិត្តចូលរួមនិងទទួលការលើកទឹកចិត្ត)។
៥. ដើរជុំវិញផ្សារ ហើយរីករាយនឹងបរិយាកាសនិងមនុស្សនៅទីនោះ (មានការប្តេជ្ញាចិត្តយ៉ាងពេញទំហឹងនិង ត្រៀមខ្លួនរួចជាស្រេចសម្រាប់ការប្រឈមមុខនឹងការលំបាក)។



បន្ទាប់ពីអ្នកចូលរួមឈរនៅទីតាំងដែលជារបស់ខ្លួនរួចហើយ ត្រូវសួរពួកគេអោយពន្យល់ថាហេតុអ្វីទើបពួកគេជ្រើសរើសកន្លែងទាំងនេះ។ តើមានអ្វីដែលអាចជួយអោយពួកគាត់ផ្លាស់ប្តូរពីទីតាំងបច្ចុប្បន្នទៅកន្លែងដែលមានការប្តេជ្ញាចិត្តកាន់តែខ្ពស់។ កិច្ចការបន្ថែមនេះមានសារៈប្រយោជន៍យ៉ាងខ្លាំងដែលអាចជួយអោយក្រុមទាំងមូលនឹកឃើញពីគំនិតផ្សេងៗដែលពួកគាត់មិនបានគិតដល់ ហើយដែលគំនិតទាំងនេះឆ្លុះបញ្ចាំងពីចំនុចសំខាន់ៗនៃគម្រោងដែលប្រជាជនចង់ធ្វើ។

យើងអាចប្រើលំហាត់នៅដំណាក់កាលផ្សេងៗនៅក្នុងដំណើរការអនុវត្តន៍គម្រោងដើម្បីអោយដឹងថាតើប្រជាជននៅតែមានការប្តេជ្ញាចិត្តដូចពេលចាប់ផ្តើមដែរ ឬអត់ ឬតើមានអ្វីប្រែប្រួលឬទេ។

## ❖ ផ្នែកទី៣ : ការរៀបចំផែនការសកម្មភាព

### ➢ *គោលបំណងនៃផ្នែកទី៣:*

ដើម្បីជួយសហគមន៍ក្នុងការរៀបចំគោលដៅ និងបង្កើតផែនការសកម្មភាព ។

### ➢ *ជំហានគន្លឹះ:*

១. សិក្សាព្រះគម្ពីរត្រង់ចំនុចការដើរលើទឹកដើម្បីលើកទឹកចិត្តសហគមន៍អោយចាប់ផ្តើមធ្វើសកម្មភាព ។

២. ធ្វើផែនការគម្រោងដោយលេងល្បែងជិះរថយន្តឈ្នួល ។

៣. បញ្ចូលល្បែងនេះនៅក្នុងផែនការគម្រោងដោយប្រើតារាងផែនការ ។

៤. រៀបចំផែនការសកម្មភាព និងពេលវេលាដោយប្រើសកម្មភាព washing line ។

៥. ធ្វើការសាកល្បងផែនការដោយប្រើរឿងឈុតខ្លីៗ ។

៦. ធ្វើការរំលឹកពីតារាងផែនការផ្សេងៗឡើងវិញ ។

៧. ពិចារណារើសក្រុមដែលមានរចនាសម្ព័ន្ធល្អដាច់គេដើម្បីអោយដំណើរការគម្រោង ។



## ➢ ជំហានទី១ : ការសិក្សាព្រះគម្ពីរ



### ⇨ ការយាងលើទឹក

យូម៉ូចាគឺផ្តល់អោយសហគមន៍នូវការផ្លាស់ប្តូរវិជ្ជមាន និងធ្វើអោយក្រុមគ្រួសារ និងបុគ្គលមានភាពកាន់តែប្រសើរឡើង។ កិច្ចការនេះត្រូវជួបនិងភាពប្រថុយប្រថាន និងត្រូវការសេចក្តីក្លាហាន រួមទាំងជំនឿដើម្បីធ្វើអ្វីដែលថ្មី ឬជួបជាមួយមនុស្សដែលអ្នកមិនចូលចិត្ត ឬមានការរើសអើងចំពោះពួកគេ។

ការសិក្សាព្រះគម្ពីនេះលើកទឹកចិត្តយើងអោយហ៊ានផ្សងនឹងបញ្ហាលំបាកដោយជឿជាក់ថាព្រះជាម្ចាស់ស្មោះត្រង់ ទ្រង់នឹងនាំផ្លូវយើង ព្រមទាំងជួយយើងអោយឆ្លងផុតនូវបញ្ហាលំបាកទាំងឡាយដែលយើងជួបប្រទះ។

ប្រសិនបើអាច អ្នកអាចបំបែករឿងនេះជាផ្នែកធំៗដូចជា ការមើលឃើញខ្យល់ ការដើរលើទឹក និងការផ្តោតជាសំខាន់លើព្រះយេស៊ូគ្រីស្ទ។

**សូមអានម៉ាកុស ៦:៤៥-៥៦**



**ការមើលឃើញខ្យល់**

១. តើកិច្ចការអ្វីខ្លះដែលធ្វើអោយអ្នកភ័យខ្លាចបំផុតឬធ្វើអោយអ្នកមិនទុកចិត្តព្រះជាម្ចាស់?

២. តើកិច្ចការទាំងនេះអាចដោះស្រាយដោយវិធីណាតាមបែបជាក់ស្តែងនិងតាមព្រលឹងវិញ្ញាណ?

៣. តើអ្នកអាចប្រើជំហានអ្វីនៅថ្ងៃនេះដើម្បីដោះស្រាយការភ័យខ្លាចទាំងនេះ?

៤. តើបទពិសោធន៍អ្វីដែលអ្នកធ្លាប់ជួបប្រទះដែលបង្ហាញថាព្រះជាម្ចាស់អនុញ្ញាតអោយអ្នកឆ្លងកាត់?



**ការដើរលើទឹក**

១. តើការលំបាកនិងបញ្ហាដែលអ្នកជួបប្រទះនៅក្នុងអតីតកាលមានឥទ្ធិពលទៅលើការលូតលាស់ខាងព្រលឹង វិញ្ញាណរបស់អ្នករបៀបណា?

២.តើអ្នកគិតថាក្រុមសម្របសម្រួលគម្រោងអាចមានការរីកចំរើនតាមរយៈការឆ្លងកាត់បញ្ហាលំបាកទាំងឡាយនៅក្នុងការអនុវត្តន៍គម្រោងដោយវិធីណា?

៣.តើយើងអាចពង្រីកពេលវេលានិងឱកាសតាមរបៀបណាដើម្បីធ្វើការឆ្លុះបញ្ចាំងទៅលើការលំបាកទាំងនោះនិងធ្វើការអធិស្ឋាន?

**ការសំឡឹងទៅរកព្រះគ្រីស្ទ**

១.តើកិច្ចការអ្វីខ្លះដែលជួយយើងអោយចាប់ផ្ដើមបោះជំហានទៅមុខ និងឆ្លងកាត់ភាពប្រថុយប្រថាន?

២.តើយើងអាចលើកទឹកចិត្តគ្នាទៅវិញទៅមកតាមវិធីណា?

**សេចក្ដីអធិស្ឋាន**

សូមព្រះជាម្ចាស់ប្រទានកំលាំងដល់អ្នកដើម្បីឆ្លងកាត់គ្រប់បញ្ហាដែលកើតមានឡើងនៅលើផ្លូវដ៏វែងឆ្ងាយ មិនគ្រាន់តែកំលាំងដ៏ខ្លាំងក្លាក្នុងការឆ្លងកាត់កិច្ចការលំបាកនានាប៉ុណ្ណោះទេ តែជាកំលាំងនៃសិរីរុងរឿងដែលព្រះជាម្ចាស់ប្រទានមកអ្នក ។

នេះជាកំលាំងដ៏ពិសេសមួយដែលធ្វើអោយបញ្ហាលំបាកទាំងឡាយក្លាយទៅជាសេចក្ដីអំណរសម្រាប់យើង សូមអរព្រះគុណព្រះវរបិតាដែលប្រទានកំលាំងយ៉ាងគ្រប់គ្រាន់សម្រាប់ទូលបង្គំទាំងអស់គ្នា ដើម្បីចូលរួមចំណែកនៅក្នុងគ្រប់អ្វីៗទាំងអស់ដែលមានពន្លឺនិងភាពស្រស់ស្អាតដែលព្រះអង្គប្រទានដល់យើងគ្រប់គ្នា ។

**កូល៉ុស១:១១**

សូមសរសេរសារខាងក្រោមនេះនៅលើក្រដាសតូចៗរួចហើយបិទនៅលើជញ្ជាំងជុំវិញបន្ទប់ឬអាចសរសេរនៅលើក្ដារខៀន ។ ស្នើសុំអោយអ្នកចូលរួមដើរមើលរួចហើយជ្រើសរើសសារមួយដែលគាត់គិតថាមានប្រយោជន៍ ។

បន្ទាប់មកចែកចាយដល់ក្រុមទាំងមូលដោយបង្ហាញពីមូលហេតុដែលគាត់ចូលចិត្តសារនេះនិងថាតើសារនេះមានអត្ថន័យយ៉ាងសម្រាប់ពួកគាត់នៅក្នុងការអនុវត្តន៍ជាក់ស្ដែង ។ ម៉្យាងវិញទៀតបើអោយអ្នកចូលរួមអានសារទាំងនេះកាន់តែល្អ ស្នើអោយអ្នកណាអានអោយខ្លាំងៗបន្ទាប់មកអោយអ្នកចូលរួមរើសយកមួយម្នាក់ៗ ។

ប្រសិនបើអ្នកចង់ដើរនៅលើទឹក អ្នកត្រូវតែទទួលយកថាជើងអ្នកត្រូវទទឹកជាមុនសិន បន្ទាប់មកអ្នកអាចឃើញថាការប្រឈមនឹងគ្រោះថ្នាក់គឺមានតម្លៃ។

នៅពេលដែលយើងផ្តោតសំខាន់ទៅលើកំលាំងខ្យល់ព្យុះជាងវត្តមាននៃព្រះជាម្ចាស់នោះ យើងនឹងធ្លាក់ចូលទៅក្នុងបញ្ហា។

នៅពេលដែលអ្នកកំពុងឆ្លងកាត់ការលំបាកការ នោះនឹងបង្កើតនូវចំនុចស្នូលនៃជីវិតអ្នកថាតើ លោកអ្នក ជាអ្នកណា ទោះបីជាអ្នកធ្វើកិច្ចការ ទាំងនោះមិនបាន ល្អឥតខ្ចោះក៏ដោយ។

ជីវិតរបស់យើងគឺមិនមែនសម្រាប់ការពារឬបំពេញបំណងខ្លួនឯងឡើយប៉ុន្តែសម្រាប់ប្រឈមមុខនឹងបញ្ហានិងសំរាប់បំរើ។

ព្រះជាម្ចាស់ស្រឡាញ់អ្នកទាំងអស់គ្នាដែលនៅក្នុងទូក-ប៉ុន្តែតើមានអ្វីកើតឡើង ប្រសិនបើអ្នកទុកចិត្តលើព្រះអង្គបន្ថែមទៀត ?

ពេត្រុសដឹងថាសិរីរុងរឿងនៃព្រះជាម្ចាស់លើកគាត់ឡើងតាមរយៈព្រះយេស៊ូនៅពេលដែលចាំបាច់។ពេលអ្នកធ្លាក់ចុះ ព្រះយេស៊ូនឹងលើកអ្នកឡើង អ្នកមិននៅឯកោម្នាក់ឯងឡើយ។

ពេត្រុសមានឆន្ទៈក្នុងការឆ្លងកាត់បញ្ហា និងភាពបរាជ័យដែលធ្វើអោយគាត់មានការរីកចំរើន។

នៅពេលដែលអ្នកបាត់បង់ទីពំនាក់ ឬការគាំទ្រនៅក្នុង ជីវិតនោះធ្វើអោយអ្នករកឃើញ ថាមានតែព្រះជាម្ចាស់មួយអង្គគត់ដែលជួយអ្នកបាន  អ្នកស្វែងយល់ថា មានព្រះជាម្ចាស់គឺគ្រប់គ្រាន់ហើយ។

ជាការមួយមិនអាចទៅរួចទេ ដែលត្រូវចាក ចោលទូកនៅពេលដែលខ្យល់ស្ងប់ពុំមានទឹករលក។ តែករណីនេះកំរនឹងមានណាស់នៅ ក្នុងជីវិតជាក់ស្តែង។

សកម្មភាពនៃការប្រឈមមុខនឹងខ្យល់ព្យុះធ្វើអោយអ្នកស្វែងរកឃើញនូវអ្វីដែលមាននៅក្នុងអ្នក និងធ្វើ អោយសម្រេចចិត្តធ្វើអ្វីតទៅមុខទៀត។

យើងទាំងអស់គ្នាមានជំរើសពីរបៀបដែលយើង នឹងឆ្លើយតបទៅនឹងព្យុះទាំង ឡាយដែលបក់បោកនៅក្នុងជីវិតរបស់យើង-ថាតើត្រូវប្រឈមមុខនឹងវាឬក៏នៅស្ងៀមស្ងាត់-តើយើងនឹងបើកចិត្តទទួលយកឱកាសដែលមាននៅក្នុងខ្យល់ព្យុះឬមួយក៏យើងទប់ស្កាត់វា?

## ➢ ជំហានទី២ ៖ លំហាត់ឡានក្រុងតូច

លំហាត់នេះបានអនុវត្តន៍ម្ដងរួចមកហើយជាមួយក្រុមជំនុំនៅក្នុងផ្នែកនៃការបង្កើតទស្សនៈវិស័យ ហើយយើងអាចយកវាមកអនុវត្តន៍ម្ដងទៀតដើម្បីជួយអោយសហគមន៍ចាប់ផ្ដើមគិតអំពីជំហានគន្លឹះនានានៅក្នុងការរៀបចំផែនការគម្រោង។ ជាក់ស្ដែងក្រុមជំនុំបានធ្វើកិច្ចការនេះរួចហើយ ដូច្នេះក្រុមជំនុំនឹងមានទំនុកចិត្តធ្វើកិច្ចការនេះជាមួយសហគមន៍។

**ជាឧទាហរណ៍ ៖**

១. តើយើងចង់ធ្វើអ្វី ?

-គម្រោងបង្កើតប្រាក់ចំណូលសម្រាប់យុវជន

២. ហេតុអ្វីយើងចង់ធ្វើការនេះ ?

-យុវជនត្រូវការប្រាក់ចំណូលនិងការបំពេញខាងវិញ្ញាណ

៣. តើយើងនឹងធ្វើការនេះដោយរបៀបណា ?

-កំណត់ការងារដែលយុវជនត្រូវធ្វើដើម្បីអោយបានថវិកា

-រៀបចំគណកម្មាធិការតូចមួយក្រុម

-បណ្ដុះបណ្ដាលគណកម្មាធិការអោយមានជំនាញនិងចំណេះដឹង

៤. តើយើងមានធនធានអ្វីខ្លះហើយ ?

-មានក្រុមយុវជន

៥. តើនរណាខ្លះដែលត្រូវដើរជាមួយយើង ?

-ក្រុមយុវជន

-អ្នកធ្វើការជាមួយយុវជន

-អ្នកដឹកនាំសហគមន៍មូលដ្ឋាន

-អ្នកដឹកនាំព្រះវិហារមូលដ្ឋាន

៦. តើអ្វីខ្លះដែលអាចធ្វើអោយយើងមិនអាចទៅមុខបាន ?

-ខ្វះការជំរុញចិត្តទៅលើយុវជន

-ខ្វះការគាំទ្រពីអ្នកដឹកនាំក្រុមជំនុំ

-ខ្វះការសហការពីថ្នាក់ដឹកនាំមូលដ្ឋាន

៧. តើអាចមានអ្វីជាឧបសគ្គនៅលើផ្លូវរបស់យើង ?

-អតិផរណាតម្លៃទំនិញទីផ្សារ

-ខ្វះការតាំងចិត្តពីសមាជិកក្រុម

-គ្រប់គ្រងបញ្ជីគណនីមិនបានល្អ



## ⇨ ការរៀបចំរចនាសម្ព័ន្ធផែនការរបស់អ្នក

វិធីមួយដើម្បីរៀបចំរចនាសម្ព័ន្ធផែនការរបស់អ្នកគឺត្រូវធ្វើតាមចំនុចសំខាន់ៗដូចខាងក្រោម :

១. តើយើងនឹងធ្វើអ្វីខ្លះ? (ទិសដៅ)

នេះគឺបង្ហាញពីកិច្ចការនានាដែលយើងត្រូវអនុវត្តន៍ជាក់ស្ដែងដើម្បីសម្រេចបាននូវគោលបំណង។ ឧទាហរណ៍ដូចជា :ការបង្កើតសិក្ខាសាលាសម្រាប់ស្ត្រី និងកុមារងាយរងគ្រោះស្ដីពីការបង្កើនប្រាក់ចំណូលតាមរយៈការលក់វត្ថុធ្វើពីដៃផ្ទាល់ ឬក៏អភិវឌ្ឍន៍វិធីសាស្ត្រធ្វើ កសិកម្មជាដើម។

២. ហេតុអ្វីយើងត្រូវធ្វើកិច្ចការនេះ? (គោលបំណង)

នេះគឺជាទិសដៅទូទៅមួយនៃអ្វីដែលគម្រោងចង់សម្រេចបានហើយមានទំនាក់ទំនងទៅនឹងទស្សនៈវិស័យនៃគម្រោង គឺដូចជាឡានដែលត្រូវការមានទិសដៅមួយជាក់លាក់ដើម្បីអាចទៅដល់គោលដៅនៃការធ្វើដំណើរ ដូច្នេះគម្រោងរបស់យើងក៏ដូច្នោះដែរគឺត្រូវការគោលបំណងជាក់លាក់។ ជាក់ស្ដែងគោលបំណងនេះដូចជា ចង់ជួយអោយស្ត្រី និងកុមារកំព្រាដែលងាយរងគ្រោះបង្កើនប្រាក់ចំណូលរបស់ខ្លួន ឬចង់ជួយធ្វើអោយប្រសើរឡើងនូវសុខភាព និងអនាម័យទឹកនៅក្នុងសហគមន៍។

៣. តើយើងនឹងត្រូវធ្វើកិច្ចការតាមរបៀបណា? (សកម្មភាព)

នេះគឺជាកិច្ចការដែលពាក់ព័ន្ធនឹងគម្រោងត្រូវអនុវត្តន៍ដើម្បីសម្រេចបាននូវទិសដៅ។ ឧទាហរណ៍ដូចជា : ស្វែងរកអ្នកជំនាញដើម្បីហ្វឹកហ្វឺនដល់ស្ត្រីមេម៉ាយ និងក្មេងកំព្រាអំពីជំនាញបង្កើតមុខរបរខ្នាតតូច រៀបចំទីកន្លែងសម្រាប់រៀបចំសិក្ខាសាលាជាដើម។

៤. តើយើងមានធនធានអ្វីខ្លះ?

ការកំណត់នូវធនធានដែលយើងមាន និងត្រូវការសម្រាប់ប្រើប្រាស់នៅក្នុងគម្រោងគឺជាកត្តាមួយដ៏មានសារៈសំខាន់ ធនធានទាំងនេះរួមមាន : កំលាំងពលកម្មមនុស្ស ពេលវេលា បទពិសោធន៍ ជំនាញ និងធនធានធម្មជាតិ ទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗ ថវិកា និងការអធិស្ឋានជាដើម។

៥. តើអ្នកណាខ្លះចូលរួម?

ចំនុចនេះគឺជាកំណត់នូវគ្រប់មនុស្សទាំងអស់ដែលពាក់ព័ន្ធនឹងការរៀបចំ ការអនុវត្តន៍ និងការវាយតម្លៃគម្រោង។ អ្នកទាំងនោះមានដូចជា អ្នកទទួលផល បុគ្គលិកគម្រោង អ្នកដឹកនាំក្រុមជំនុំ និងសមាជិកនៃអង្គការមូលដ្ឋាន។

៦. តើកិច្ចការអ្វីខ្លះដែលអាចធ្វើអោយដំណើរការគម្រោងរបស់យើងថយក្រោយ?

ករណីនេះគឺយើងពិនិត្យទៅលើបញ្ហានានាដែលអាចធ្វើអោយគាំងដំណើរនៃគម្រោងរបស់យើង ដែលមានដូចជា ការប្រឆាំងពីសំណាក់ប្រជាជនដទៃទៀតនៅក្នុងសហគមន៍ ខ្វះថវិកា ខ្វះជំនាញ និងបទពិសោធន៍។

៧. តើកិច្ចការអ្វីខ្លះដែលជាឧបសគ្គរាំងស្ទះដល់គម្រោង?

ក្នុងនេះគឺសំដៅទៅលើកិច្ចការនានា ដែលធ្វើអោយគម្រោងរបស់យើងគាំងដំណើរពេលកំពុងអនុវត្តន៍ ដែលអាចមានដូចជា ជម្លោះ អាកាសធាតុប្រែប្រួល សមាជិកមានជំងឺ និងគោលនយោបាយរបស់ប្រទេសជាដើម។

៨. គម្រោងថវិកា

ក្រោយពេលដែលអ្នករៀបចំសកម្មភាពទាំងឡាយសម្រាប់អនុវត្តន៍គម្រោងរួចហើយ យើងត្រូវគិតទៅដល់ថវិកាដែលត្រូវការសម្រាប់សកម្មភាពទាំងនោះ។

## ➢ ជំហានទី៣ : តារាងផែនការគម្រោង

ប្រើតារាងខាងក្រោមដើម្បីផ្លាស់ប្តូរពត៌មានពីលំហាត់ឡានក្រុងតូចទៅជាផែនការមួយដែលអាចរក្សាទុកជាឯកសារគម្រោង និងសម្រាប់ស្នើសុំថវិកាពីម្ចាស់ជំនួយ ។

| ឈ្មោះគម្រោង | |
|---|---|
| តើយើងនឹងធ្វើអ្វីខ្លះ ? | |
| ហេតុអ្វីយើងត្រូវធ្វើកិច្ចការនេះ ? | |
| តើយើងនឹងត្រូវធ្វើកិច្ចការតាមរបៀបណា?<br><br>១.តើអ្នកណាខ្លះនឹងទទួលខុសត្រូវអ្វីខ្លះ?<br><br>២.តើយើងចាប់ផ្ដើមនៅពេលណា?<br><br>៣.តើយើងត្រូវការរៀបចំអ្វីខ្លះ?<br><br>៤.តើយើងចាប់ផ្ដើមរៀបចំនៅពេលណា?<br><br>៥.តើចំណាយធនធានប៉ុន្មាន?<br>-តើត្រូវចំណាយពេលប៉ុន្មាន?<br>-តើត្រូវចំណាយថវិកាចំនួនប៉ុន្មាន? | |



## ➢ ជំហានទី៤ ៖ តួនាទី និងការកិច្ចនៃការរៀបចំផែនការ

⇨ **សេចក្ដីផ្ដើម ៖**

ដើម្បីជួយអ្នកចូលរួមអោយគិតទៅលើមុខងារ និងតួនាទីផ្សេងៗនៅក្នុងការរៀបចំ និងអនុវត្តន៍គម្រោងជាមួយសហគមន៍ ព្រមទាំងសាកល្បងមើលថាតើនេះពិតជាគម្រោងដែលពួកគេចង់ចូលរួមជាក្រុមមែនឬទេ ។

⇨ **សកម្មភាពអទិភាព ៖**

ដើម្បីនាំគេអោយស្គាល់នូវសកម្មភាពដែលសំខាន់ជាអទិភាព ចូរអោយអ្នកចូលរួមទាំងអស់ចូលរួមពិភាក្សាជាក្រុមនូវពាក្យប្រដៅដូចតទៅ តាមរយះសកម្មភាពនេះដោយប្រើ សកម្មភាពបន្ទាត់លុប ។

" បុរសម្នាក់មានវត្ថុ បី ប្រភេទ គឺសត្វស្វានមួយក្បាល ស្លឹកដំឡូងមួយចំនួន និងពពែមួយក្បាល ។ទាំងបីនេះមានតំលៃចំពោះគាត់ស្មើៗគ្នា ។គាត់ត្រូវឆ្លងទន្លេទៅត្រើយម្ខាង ប៉ុន្តែទូកអាចដាក់បានគាត់ម្នាក់និងវត្ថុតែមួយប៉ុណ្ណោះ ។ ប្រសិនបើគាត់ទុកស្វានអោយនៅជាមួយពពែ នោះសត្វស្វានពិតជាស៊ីពពែ ។តែបើគាត់ទុកពពែអោយនៅជាមួយស្លឹកដំឡូង នោះពពែនឹងស៊ីអស់ ។តើបុរសម្នាក់នេះ ត្រូវធ្វើបែបណា? ដើម្បីចំលងរបស់ទាំងបីទៅត្រើយម្ខាងដោយមិនអោយបាត់បង់របស់មួយណានោះ " ។

អ្នកអាចអោយសហគមន៍សំដែងរឿងប្រស្នានេះ ហើយអោយពួកគាត់ព្យាយាមស្វែងរកដំណោះស្រាយ ។



( ដំណោះស្រាយគឺ ៖ ជើងទី១ យកពពែទៅមុន រួចត្រឡប់មកវិញ ។ ជើងទី២ យកស្វានទៅ រួចយកពពែត្រឡប់មកវិញ ។ ជើងទី៣ យកស្លឹកដំឡូងទៅ រួចត្រឡប់មកវិញទទេ ។ ជើងទី៤ យកពពែទៅ ) ។

លំហាត់នេះ អាជួយសហគមន៍អោយចេះឆ្លុះបញ្ចាំងលើកិច្ចការជាអទិភាពនានា ។ធនធានរបស់សហគមន៍ប្រៀបបានដូចជា ទូក ក្នុងរឿងនេះ វាតូច មិនអាចធ្វើគ្រប់ការទាំងអស់ក្នុងពេលតែម្ដងបានទេ ។ ដូចនេះត្រូវចាប់យកសកម្មភាពមួយជាអទិភាព ។សកម្មភាពនេះ ត្រូវតែជាសកម្មភាពដែលធ្វើដោយមានរបៀបរៀបរយបំផុត ។ការធ្វើសកម្មភាពខ្លះជាដំបូង វាអាចមានផលអវិជ្ជមានដល់ទ្រង់ទ្រាយដទៃទៀតរបស់ជីវិតសហគមន៍ ។ ឧទាហរណ៍ ៖ ការកាប់ដើមឈើទាំងអស់ដែលនៅជិតៗ ដើម្បីសាងសង់ផ្ទះ និងបង្កេននូវការដាំដំណាំកសិផលក្នុងគោលបំណងធ្វើអោយប្រសើរឡើងនូវសកម្មភាពខ្លះទៀត ។ប៉ុន្តែវានឹងនាំអោយទឹកភ្លៀងថយចុះ និងដំណាំកសិផលមិនសូវបានផលល្អក្នុងរយះពេលវែង ។

## ⇨ សកម្មភាពប្រើខ្សែហាលសំលៀកបំពាក់ ៖

**សេចក្តីផ្តើម៖**

សកម្មភាពនេះព្យាយាមជួយអោយអ្នកចូលរួមទាំងអស់អោយមើលឃើញគ្រប់ទាំងកិច្ចការដែលខុសៗគ្នាទាំងអស់ដែលពួកគេត្រូវការធ្វើដើម្បីបំពេញបញ្ចប់គម្រោង ។តាមរយៈការមើលឃើញសកម្មភាពខុសៗគ្នានៅលើកាតតូចៗទាំងអស់នោះ យើងអាចអោយពួកគេពិភាក្សាជាក្រុមតាមលំដាប់នៃសកម្មភាពមួយៗនៅកាតរហូតដល់អស់កាតនោះ ។

**ការណែនាំជាជំហាន៖**

១. សរសេរគោលបំណង ទិសដៅ និងសកម្មភាពនានាដែលត្រូវធ្វើក្នុងគម្រោងនៅលើកាតតូចៗនិងរៀបកាតទាំងនេះនៅលើខ្សែសម្រាប់ហាលសម្លៀកបំពាក់ ។
២. រៀបចំសកម្មភាពទាំងអស់ឡើងវិញ លើខ្សែហាលសំលៀកបំពាក់ទៅតាមលំដាប់លំដោយរហូតអស់ ។
៣. ពិភាក្សាពីមធ្យោបាយក្នុងការអនុវត្តន៍សកម្មភាពនីមួយៗ ព្រមទាំងជំនាញ និងបទពិសោធន៍ ដែលត្រូវការក្នុងកិច្ចការនេះ ។
៤. ពិភាក្សាពីអ្នកដែលសក្តិសមទទួលខុសត្រូវលើសកម្មភាពនីមួយៗ និងពិភាក្សាពីពេលវេលាដែលត្រូវធ្វើ ។
៥. ប្រើសេចក្តីណែនាំឈុតខ្លីៗដូចការណែនាំនៅក្នុងទំព័រ ១២៥ ដើម្បីស្វែងយល់បន្ថែមពីកត្តាផ្សេងៗទៀតដែលត្រូវការសម្រាប់រៀបចំផែនការគម្រោង ។

## ការរៀបចំផែនការសកម្មភាព

ក្រោយពេលអ្នកបានសម្រេចពីអ្វីដែលអ្នកនឹងត្រូវធ្វើ និងពីវិធីដែលត្រូវធ្វើរួចហើយ ចូរប្រើតារាងខាងក្រោមនេះសម្រាប់រៀបចំអ្វីដែលអ្នកត្រូវធ្វើនិងពេលវេលាដែលត្រូវធ្វើ។

## តារាងផែនការសាកល្បង

| | | ខែ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នរណា | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
| ពួក/ក្រុមប្រជុំ | | | × | | × | | × | | × | × | |
| ការសាកល្បងទី១ | | ផ្តើម | | បញ្ចប់ | | | | | | | |
| ការសាកល្បងទី២ | | ផ្តើម | | បញ្ចប់ | | | | | | | |
| ការសាកល្បងទី៣ | | | | ផ្តើម | | បញ្ចប់ | | | | | |
| ការសាកល្បងទី៤ | | | | | | ផ្តើម | | បញ្ចប់ | | | |
| ការសាកល្បងទី៥ | | | | | | ផ្តើម | | បញ្ចប់ | | | |
| ការសាកល្បងទី៦ | | | | | | | | ផ្តើម | | បញ្ចប់ | |
| ការសាកល្បងទី៧ | | | | | | | | | ផ្តើម | | បញ្ចប់ |

## ➢ ជំហានទី៩ : ឈុតរឿងខ្លី

លំហាត់មួយទៀតដែលមានប្រយោជន៏គឺត្រូវស្រមៃថា គម្រោងមួយត្រូវបានដំណើរការរយះពេល ប្រាំមួយខែនិងមនុស្សដែលនៅខាងក្រោមនេះជាអ្នកដែលមានតួនាទីក្នុងដំណើរការគម្រោង ចូរអោយពួកគេមើលទៅខាងក្រោយនិងបរិយាយពីអារម្មណ៏របស់ពួកគេស្តីពីរបៀបដែលពួកគេបានធ្វើអោយមានដំណើរការក្នុងគម្រោង ។



**១.សមាជិកសហគមន៏**

អ្នកត្រូវចូលរួមក្នុងគម្រោងនេះរយៈពេល៦ខែ បន្ទាប់មកអ្នកត្រូវពណ៌នាពីកិច្ចការទាំងឡាយដែលអ្នកគិតថាពិតជាល្អក៏ដូចជាការព្រួយបារម្ភ និងការលំបាកផ្សេងៗផងដែរ ។

**២.អ្នកដឹកនាំក្រុមជំនុំ**



អ្នកបានចូលរួមឧបត្ថម្ភគាំទ្រគម្រោងនេះចាប់តាំងពីចាប់ផ្តើមមកម្ល៉េះហើយ អ្នកក៏ឃើញពីការលំបាកដែលក្រុមការងារ ជួបប្រទះក្នុងការរៀបចំគម្រោង និងអនុវត្តន៏សម្រាប់រយៈពេល៦ខែ ។ អ្នកនឹងចែកចាយពីគំនិតរបស់អ្នកចំ-ពោះសកម្មភាព គម្រោងទៅលើក្រុមជំនុំ និងទំនាក់ទំនងរវាងក្រុមជំនុំ និងសហគមន៏ ព្រមទាំងឥទ្ធិពលរបស់វាទៅលើក្រុមការងារ ។

**៣.សមាជិកសហគមន៏ដែលបានចូលរួមក្នុងគម្រោង**



អ្នកបានចូលរួមជួយដល់គម្រោងក្នុងរយៈពេល៣ខែចុងក្រោយ ។ បន្ទាប់មកអ្នកត្រូវចែកចាយជាមួយក្រុមការងារអំពីដំណើរការនៃគម្រោងក្នុងរយៈពេលដែលអ្នកបានចូលរួមជាពិសេសទៅលើរបៀបដែលអ្នកទទួលបានចំណេះដឹង បទពិសោធន៏ និងរបៀបធ្វើការងារពីអ្នកដទៃដែលចូលរួមនៅក្នុងគម្រោងនេះនិងការប្រើប្រាស់ជំនាញ និង បទពិសោធន៏របស់អ្នកនៅក្នុងគម្រោងនេះ ។

**៤.សមាជិកក្រុមសម្របសម្រួលក្នុងមូលដ្ឋាន**



អ្នកបានចូលរួមជាមួយគម្រោងនេះអស់រយៈពេលជាច្រើនខែដោយក្នុងនោះអ្នកចូលរួមរៀបចំ និងធ្វើផែនការគម្រោង អស់រយៈពេល១២ខែ និងរយៈពេល៦ខែចុងក្រោយអ្នកចូលរួមអនុវត្តន៏គម្រោងនេះ ។ ចូរអ្នកចែកចាយពីភាពរីករាយ និង ការ លំបាកទាំងឡាយដែលមាន និងជួបប្រទះក្នុងរយៈពេល១៨ខែចុងក្រោយនេះ ។

## ➢ ជំហានទី៦ : រំលឹកពីផែនការឡើងវិញ

ការបញ្ចូលគំនិតថ្មីៗទៅក្នុងផែនការតាមរយៈការពិភាក្សាទៅលើឈុតខ្លីៗខាងលើ នេះជាជំហានចុងក្រោយនៃការ រៀបចំផែនការគម្រោង ។ បន្ទាប់មកធ្វើការរំលឹកឡើងវិញនូវផែនការទាំងនេះដើម្បីធានាអោយផែនការនេះមានភាពពេញលេញ និងអ្នកចូលរួមទាំងអស់យល់ច្បាស់ពីអ្វីដែលត្រូវធ្វើ ។

## ➢ ជំហានទី៧ : រចនាសម្ព័ន្ធសម្រាប់អនុវត្តន៍គម្រោង

នៅពេលដែលយើងគិតអំពីការអនុវត្តន៍គម្រោងជាការចាំបាច់យើងត្រូវគិតអំពីវិធីសាស្រ្តដែលអ្នកចូលរួមត្រូវអនុវត្តន៍ និងគាំទ្រគម្រោង ។ ខាងក្រោមនេះគឺជារចនាសម្ព័ន្ធមួយចំនួនដែលមានលក្ខណៈសមស្របអាចយកមកប្រើប្រាស់បាន ។ ក្រុមសម្របសម្រួលមូលដ្ឋានអាចដាក់វិធីសាស្រ្តទាំងនោះអោយត្រូវនឹងរចនាសម្ព័ន្ធដូចខាងក្រោយ ឬអាចដាក់តាមឈ្មោះក្រុមតូចដើម្បីអោយគេក្លាយជាក្រុមមួយដែលសមនឹងភារះរបស់គេ ។



**ក-ក្រុមការងារនៃគម្រោង**

គេបង្កើតក្រុមនេះឡើងក្នុងរយៈពេលតាំងពីចាប់ផ្តើមរហូតដល់បញ្ចប់គម្រោងនៅក្នុងក្រុមនេះត្រូវជ្រើសរើសប្រធាន ឬអ្នកសម្របសម្រួលក្រុមម្នាក់ដែលជា អ្នកធានា និងទទួលខុសត្រូវអោយការងារក្រុមមានដំណើរការរលូន ។ សមាជិក ក្រុមទទួលខុសត្រូវរៀបចំការប្រជុំផ្តល់ និងចាត់ចែងការងារ និងធ្វើការត្រួតពិ និត្យមើលទៅលើដំណើរការអនុវត្តន៏គម្រោង ។

**ខ-គណៈកម្មាធិការនៃគម្រោង**



ក្រុមនេះបង្កើតមានលក្ខណៈជាផ្លូវការជាងក្រុមខាងលើដោយមានតួនាទី និងមុខ ងារជាក់លាក់ព្រមទាំងមានសមត្ថភាពគ្រប់គ្រងនិងត្រួតពិនិត្យទៅលើគម្រោងនា នាតាមរយៈពេលសមស្រប ។

តួនាទីរបស់គណៈកម្មាធិការនេះមានដូចជា ប្រធាន លេខាធិការ គណនេយ្យករ និងសមាជិក ។ ក្រុមនេះមានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកថ្មីនិងបង្កើត គោលការណ៏ ឬច្បាប់ សម្រាប់ការងារ ។ នៅក្នុងករណីខ្លះ គណៈកម្មាធិការគម្រោងអាចត្រួតពិនិត្យទៅលើអនុគណៈកម្មាធិការនានាដែលទទួលខុសត្រូវ ទៅលើគម្រោងជាក់លាក់នានាដូចជា : គម្រោងទឹក និងសុខ ភាពអនាម័យ សាលារៀន ការចិញ្ចឹមសត្វ និងសុខភាពជាដើម ។

**គ-អង្គការមានមូលដ្ឋាននៅសហគមន៏**




នេះគឺជាក្រុមមួយដែលមានសិទ្ធិស្របច្បាប់ និងមានសមាជិកត្រូវបានជ្រើសរើសឡើងដោយការបោះឆ្នោត និងមាន រចនាសម្ព័ន្ធមុខដំណែងផ្សេងៗ ។

ដោយសារក្រុមនេះមានសិទ្ធិស្របច្បាប់ ដូច្នេះអាចស្នើសុំថវិកា ឬជំនួយពីស្ថាប័នស្របច្បាប់ ឬភ្នាក់ងារអន្តរជាតិនានា ។ កិច្ចការនេះអាចកើតឡើងបានតាមរយៈលទ្ធផលជោគជ័យនៃគណៈកម្មធិការគម្រោងឆ្លងកាត់អស់ រយៈពេលជាច្រើនឆ្នាំ ។

**ការឆ្លុះបញ្ចាំង**

តើអ្នកគិតថារចនាសម្ព័ន្ធណាមួយដែលសមស្របបំផុតសម្រាប់សហគមន៏របស់អ្នកនៅក្នុងពេលនេះ? តើអ្នកត្រូវការបង្កើតរចនាសម្ព័ន្ធថ្មី ឬធ្វើតាមរចនាសម្ព័ន្ធដែលមានរួចហើយ?

❖ **ផ្នែកទី៤ : ការរៀននិងការឆ្លុះបញ្ចាំង**

ផ្នែកនេះ គឺមានសារសំខាន់ណាស់ដែលព្រះវិហារនិងសហគមន៍ត្រូវតែរំលឹកនិងធ្វើការឆ្លុះបញ្ចាំងទៅក្រោយវិញនូវការងារដែលខ្លួនបានធ្វើថាតើវាបានល្អដែរឬទេ និងពីវិធីសាស្ត្រដែលគេត្រូវធ្វើអោយកិច្ចការនេះបានប្រសើរជាងមុនដែលពួកគេត្រូវរៀននិងធ្វើជាមួយគ្នាបន្តទៀត ។

**⇨ ការឆ្លុះបញ្ចាំងលើផ្នែកទី១: ការសុបិន្តនិម្មិត**

១. តើយើងបានរៀបចំ នូវ សុបិន្តនិម្មិត បានល្អយ៉ាងណា ជាមួយសហគមន៏ ?

២. តើការងារអ្វីដែលយើងបានធ្វើល្អជាងគេបំផុត ហើយការងារណាដែលយើងត្រូវកែលំអនាពេលក្រោយ ?




**⇨ ការឆ្លុះបញ្ចាំងលើផ្នែកទី២: ការបញ្ជាក់អោយច្បាស់ពីអ្វីដែលត្រូវធ្វើបន្ទាប់**

១. តើសហគមន៏អាចយល់បាននូវបញ្ហាចំបងៗដែលគេត្រូវប្រឈមមុខដែរឬទេ ?

២. តើយើងអាចដោះស្រាយបាននូវគ្រប់ទាំងតំរូវការចំបងៗរបស់សហគមន៏អោយបានល្អប្រសើរយ៉ាងណា ?



## ⇨ ការឆ្លុះបញ្ចាំងលើផ្នែកទី៣: ការធ្វើផែនការសកម្មភាព

១. តើយើងបានធ្វើផែនការជាមួយគ្នាយ៉ាងល្អយ៉ាងណាដែរ ?

២. តើគ្រប់ទាំងផែនការដែលយើងបានធ្វើជាមួយគ្នានោះ យើងមានគំរោងជាក់លាក់និងអាចសំរេចបានដែរឬទេ ?

៣. តើយើងអាចវាស់វែងនូវដំណើរការការងារដែលយើងសំរេចចិត្តធ្វើទាំងនោះបានដោយរបៀបណា ?



# ដំណាក់កាលទី៤: ការអនុវត្តន៍សកម្មភាព



### ❖ ទិដ្ឋភាពទូទៅនៃដំណាក់កាលទី៤ : ការអនុវត្តន៍សកម្មភាព

### ➢ គោលបំណងនៃដំណាក់កាលនេះ :

ដើម្បីជួយក្រុមកសាងគំរោង អោយពិចារណាលើទិដ្ឋភាពសំខាន់ៗនៃការរៀបចំគំរោងពីមួយថ្ងៃទៅមួយថ្ងៃ។

### ➢ មាតិការនៃដំណាក់កាលនេះ :

ដំណាក់កាលនេះមានសកម្មភាពផ្សេងៗនិងឧបករណ៏សំរាប់ជួយក្រុមមួយៗអោយរៀបចំនិងគ្រប់គ្រងគំរោងសហគមន៏។សកម្មភាពនិងឧបករណ៏មិនគួរគាប្បីធ្វើទាំងអស់ទេ ប៉ុន្តែត្រូវជ្រើសរើសអោយសមស្របតាមស្ថានភាពរបស់អ្នក។ វាគឺជាការសំខាន់ក្នុងការនៅតែមើលសំនួរការរៀនសូត្រនិងការឆ្លុះបញ្ចាំងក្នុងផ្នែកទាំង ១២ នៅពេលអ្នកប្រើឧបករណ៏និងសកម្មភាពនានា។

១. ការសិក្សាព្រះគម្ពីរក្នុងកណ្ឌនេហេមា
២. ការបញ្ជាក់គោលបំណងនៃគំរោងនិងភារកិច្ចជាអាទិភាព
៣. របៀបក្នុងការត្រួតពិនិត្យគំរោង
៤. ការបែងចែកការងារ
៥. ការគ្រប់គ្រងនិងអោយតំលៃមនុស្ស
៦. របៀបជំរុញទឹកចិត្តខ្លួនយើង
៧. ការបង្កើតក្រុម
៨. របៀបរៀបចំការប្រជុំអោយមានប្រសិទ្ធភាព
៩. របៀបផ្តល់ពតិមានដល់អ្នកដទៃ
១០. ការរក្សារបាយការណ៏គំរោង
១១. ការផ្តល់ពតិមានរបស់អ្នកជំនាញ
១២. ការរៀនសូត្រនិងឆ្លុះបញ្ចាំង



### ១.ការសិក្សាព្រះគម្ពីរ- ការអនុវត្តន៏និងត្រួតពិនិត្យ



## លោកនេហេមាសាងសង់កំផែង

### *ផ្នែក ក: ការធ្វើការជាមួយគ្នា*

*ចូរអាន នេហេមា ២:១៧-៣:៣២*



នៅក្នុងការសិក្សាព្រះគម្ពីរនៅទំព័រ ៦៣ យើងបានឃើញពីរបៀប ដែលនេហេមាប៉ាន់ស្មានតំរូវការមើលជួសជុលកំផែងយេរូសឡឹម។ នៅក្នុងសារនេះយើងឃើញគាត់ជួយរៀបចំការងារសាងសង់ឡើងវិញ។

១. តើមានអ្វីកើតឡើងក្នុងសារនេះ?

២. តើមានតែនេហេមានិងអ្នកបំរើរបស់គាត់ដែលបានធ្វើការនេះ?តើមានអ្នកផ្សេងទៀតបានចូលរួមដែរឬ?
មនុស្សមួយចំនួនដែលបានចូលរួមមានពួកសង្ឃ ជាងទង អ្នកលាយគ្រឿងក្រអូប នាយតម្រួតនិងមន្ត្រី ស្ត្រី ប្រជាពលរដ្ឋ និង ឆ្មាំទ្វារ។

៣. តើអ្នកគិតថាចំនួនប្រជាជនដែលបានចូលរួម នឹងជួយសាងសង់កំផែងបានលឿនឬក៏យឺត?

៤. តើអ្នកណាដែលបានចូលរួមក្នុងគំរោងអូម៉ូចារួចហើយ?តើមានរូបអ្នកដែរឬ?តើអ្នកណាផ្សេងទៀតដែលគួរលើកទឹកចិត្តអោយចូលរួមបន្ថែមទៀត?

៥. នេហេមាបានចូលរួមជាមួយមនុស្សជាច្រើនប្រភេទ-អ្នកក្រនិងអ្នកមាន ប្រុសនិងស្រី ប្រជាជនក្នុងមូលដ្ឋាន និងអ្នកដែលនៅឆ្ងាយ ។តើអ្នកជួយមនុស្សគ្រប់រូបដែលចង់រួមក្នុងគំរោងដោយរបៀបណា?

### *ផ្នែក ខ: ការជំនះលើឧបសគ្គ*

*ចូរអាន នេហេមា ៤:១-២៣*

១. តើមានអ្វីខ្លះដែលបានកើតឡើងនៅក្នុងព្រះបន្ទូលនេះ?

២. តើអ្វីជាការលំបាកដែលនេហេមាបានជួបប្រទះនិងអ្នកដែលបានចូលរួមក្នុងការកសាងកំផែងឡើងវិញ?

៣. តើអ្នកបានជួបការលំបាកអ្វីខ្លះនៅក្នុងគំរោងអូមិយារបស់អ្នក?

៤. តើនេហេមាបានប្រើប្រមធ្យោបាយអ្វីខ្លះក្នុងការឆ្លើយតបទៅនឹងការលំបាកទាំងនេះ?
គាត់អធិស្ឋានសុំជំនួយ *ខ៤* គាត់លើកទឹកចិត្តប្រជាជន *ខ១៤* គាត់ធ្វើសកម្មភាព *ខ២១-២៣*។

៥. តើអ្វីជាមធ្យោបាយរបស់អ្នកក្នុងការឆ្លើយតបទៅនឹងការលំបាកទាំងនេះ?

### ២. ការបញ្ជាក់ពីគោលបំណងនៃគំរោង និងសកម្មភាពចំបងនានា

នៅពេលដែលអ្នកបើកអនុវត្តន៍គំរោង វាគឺជាការល្អដែលអ្នកមានការពិភាក្សាទូទៅអំពីគោលបំណង ។ ចូរអ្នកដឹកនាំក្នុងការពិភាក្សាដោយរួមបញ្ចូលចំនុចនានាដូចខាងនេះ :

១. រំលឹកក្រុមអំពីគោលបំណងគំរោង ។

២. ធ្វើការព្រមព្រៀងគ្នាពីកាលបរិច្ឆេទនិងទីកន្លែងនៃការប្រជុំ ។

៣. រំលឹកឡើងវិញពីតួនាទីនិងការទទួលខុសត្រូវរបស់អ្នកចូលរួមធ្វើគំរោងទាំងអស់ ។

៤. ពិភាក្សាពីក្ដីសង្ឃឹមនិងភាពភ័យខ្លាចរបស់គំរោង ។

៥. កំនត់ពីឧបសគ្គដែលអាចកើតមាននិងវិធីសាស្ត្រសំរាប់ដោះស្រាយ ។វាជាការល្អក្នុងការរំលឹកលំហាត់ឡានតូចនៅទំព័រ ១១៨ ដោយយកចិត្តទុកដាក់ចំពោះអ្វីដែលអាចធ្វើទៅបាននិងអ្វីដែលមិនអាច ។



## ៣. របៀបត្រួតពិនិត្យគំរោង

ផ្នែកសំខាន់នៃដំណើរការគំរោងគឺការវាស់វែងភាពវិវត្តន៍ទាំងមធ្យោបាយដែលកំពុងធ្វើនិងរបៀបដែលជីវិតរស់នៅបានផ្លាស់ប្តូរដែលមានន័យថាការត្រួតពិនិត្យ ។ការត្រួតពិនិត្យមានន័យថាការប្រមូលពិតមានដែលជួយយើងអោយដឹងពីដំណើរការគំរោង ។ជាទូទៅការប្រមូលពតិមានទៀងទាត់ពីកំនត់ត្រាអ្នកចូលរួមចំលើយតបពីសមាជិក សហគមន៏ដែលជាការមានប្រយោជន៏សំរាប់គំរោង និង សំរាប់រំលឹកឡើងវិញពីគំរោងថវិការនិង ការចំនាយ ។ការត្រួតពិនិត្យពិតជាមានប្រយោជន៏ដោយសារបានផ្តល់ពិតមានជាច្រើននៅពេលវាយតំលៃបញ្ចប់គំរោង ។

មានសំនួរសំខាន់បីដែលត្រូវការសួរនៅពេលត្រួតពិនិត្យគំរោង :

តើយើងបានធ្វើអ្វីដូចដែលយើងបាននិយាយដែរឬទេ ?



តើយើងធ្វើអោយមានការខុសប្លែកអ្វីខ្លះ ?

តើយើងបានប្រើជំនាញនិងធនធានប្រកបដោយប្រសិទ្ធភាពដែរឬទេ ?

ប្រសិនបើអ្នកមិនសួរសំនួរទាំងនេះអោយបានទៀងទាត់ទេ អ្នកអាចមើលឃើញខ្លួនអ្នកថា អ្នកកំពុងធ្វើដំណើរក្នុងទិសដៅដែលអ្នកមិនចង់ទៅ ។



ឧទាហរណ៍ :

ប្រសិនបើអ្នកចង់ត្រួតពិនិត្យការសាងសង់សាលារៀនមួយក្នុងមូលដ្ឋាន ។ សំនួរខាងក្រោមនេះជាសំនួរដែលមានប្រយោជន៍ :

-តើយើងមានធនធានគ្រប់គ្រាន់ដើម្បីសាងសង់សាលារៀនដែរឬទេ ?

-តើសាលារៀនបានសាងសង់តាមបទដ្ឋានត្រឹមត្រូវដែរឬទេ ?

-តើមនុស្សគ្រប់រូបធ្វើការជាមួយគ្នាជាក្រុមដែរឬទេ ?

-តើយើងបានប្រើជំនាញប្រកបដោយប្រសិទ្ធិភាពដែរឬទេ ?

-តើគំរោងធ្វើទៅតាមថវិការដែរឬទេ?

**ការត្រួតពិនិត្យគម្រោងថវិការ :**

មធ្យោបាយល្អបំផុតសំរាប់ត្រួតពិនិត្យគំរោងថវិការគឺការប្រៀបធៀបថវិការទៅនឹងអ្វីដែលបានចំនាយ ។តំរូវការនេះត្រូវធ្វើទៀងទាត់ ដូចនេះហើយការផ្លាស់ប្ដូរត្រូវធ្វើ ប្រសិនបើចាំបាច់ ។

| រាយមុខចំនាយ | គំរោងថវិការ | ការចំនាយ |
|---|---|---|
| ទិញឈើ | ៦០០ដុល្លារ | ៤៥០ដុល្លារ |
| ទិញស៊ីម៉ង់ត៍ | ២០០ដុល្លារ | ២២៥ដុល្លារ |
| ទិញខ្សាច់ | ៩៥ដុល្លារ | ១០០ដុល្លារ |
| ទិញឥដ្ឋ | ៣៥០ដុល្លារ | ៣២០ដុល្លារ |
| ឈ្នួលជាង | ២៥០ដុល្លារ | ៣០០ដុល្លារ |
| ដីបូល | ១២០០ដុល្លារ | ៩៥០ដុល្លារ |
| **សរុប** | **២៦៩៥ដុល្លារ** | **២៣៤៥ដុល្លារ** |



| តារាងត្រួតពិនិត្យ | | | | |
|---|---|---|---|---|
| **បញ្ជីសកម្មភាពគំរោង** | **សកម្មភាពបានអនុវត្តន៏នៅពេលណា?** | **តើសកម្មភាពទាំងនេះបានមសនដំណើរការយ៉ាងដូចម្ដេច? ហើយគួរកែលំអអ្វីខ្លះ?** | **តើអ្នកណាគួរប្រមូលពតិមានអំពីសកម្មភាពនេះ?** | **តើមានការផ្លាស់ប្ដូរវិជ្ជមានអ្វីបានកើតឡើងទាក់ទងនឹងសកម្មភាពនេះ?** |
| ១. | | | | |
| ២. | | | | |
| ៣. | | | | |
| ៤. | | | | |
| ៥. | | | | |
| ៦. | | | | |
| ៧. | | | | |
| ៨. | | | | |

តារាងនេះមានប្រយោជន៏សំរាប់ធ្វើផែនការត្រួតពិនិត្យសកម្មភាពដែលអ្នកកំពុងធ្វើ ។ប្រសិនបើអាចទៅបានចូរព្យាយាមគូរលើក្រដាស់ធំសំរាប់ងាយស្រួលក្នុងការប្រជុំជាសាធារណៈ ។គឺជាការមានសារះប្រយោជន៏ក្នុងការប្រើប្រាស់តារាងប្រមូលពតិមាននៅទំព័រ ៨២-៩២ ដោយសារវាបង្ហាញពីភាពខុសគ្នាពីការចាប់ផ្ដើមគំរោង និងគំរោងនៅពេលឥឡូវនេះ ។

ចូរធ្វើអោយច្បាស់ថាការកត់ត្រានូវចំនុចមានប្រយោជន៏ រក្សាទុកអោយល្អ ត្រឹមត្រូវ និង ងាយស្រួល ។



## ៤.តើយើងគួរធ្វើការងារផ្ទេរសិទ្ធដោយរបៀបណា?




តួនាទីរបស់អ្នកសម្របសម្រួលគឺគិតអំពីការបែងចែកភារកិច្ច ។ ការផ្ទេរសិទ្ធការងារគឺមានន័យថាការផ្ដល់ការទទួលខុសត្រូវនូវភារកិច្ចជាក់លាក់ទៅអោយអ្នកដទៃ ។

ការផ្ទេរសិទ្ធការងារវាគឺមានសារៈសំខាន់ដែលអាចជួយអោយយើងមានពេលសំរាប់ធ្វើការងារផ្សេងៗ ។ហើយក៏ជួយអោយការងារបញ្ចប់មានប្រសិទ្ធភាពនិងជួយអោយមនុស្សគ្រប់រូបមានការលើកទឹកចិត្ត ការទុកចិត្ត និងមានជំនាញ ។វាក៏ជួយកាត់បន្ថយការងារហួសកំនត់របស់អ្នកកាន់តំរោង ។

នេះគឺជាសកម្មភាពទាំង ០៨ សំរាប់ផ្ទេរសិទ្ធិអោយបានជោគជ័យ ។

សកម្មភាពទី ១: ការសំរេចថាតើអ្នកណាដែលគួរផ្ទេសិទ្ធិទៅអោយ ។

សកម្មភាពទី ២: បង្ហាញពីសារៈសំខាន់និងផលប្រយោជន៍នៃការផ្ទេរសិទ្ធិ ។

សកម្មភាពទី ៣: បំបែកភារកិច្ចអោយតូចៗហើយសំរេចចិត្តអំពីកំរិតដែលត្រូវជួយជ្រោមជ្រែង ។

សកម្មភាពទី ៤: ចំនាយពេលក្នុងការបណ្ដុះបណ្ដាលមនុស្សនេះទៅតាមភារកិច្ចរបស់ពួកគេ ។

សកម្មភាពទី ៥: ផ្ដល់ពេលអោយគាត់ហាត់អនុវត្តការងារ ។

សកម្មភាពទី ៦: អោយទទួលភារកិច្ចប្រសិនបើសមស្រប ។





សកម្មភាពទី ៧: ជួបគាត់និងផ្ដល់ការកែលំអរ ។

សកម្មភាពទី ៨: អបអរសាទរនូវអ្វីដែលគាត់បានធ្វើល្អ ។

## ៥. ការគ្រប់គ្រងនិងអោយតំលៃមនុស្ស

នៅពេលរៀបចំគំរោងយើងត្រូវការទាំងអ្នកចូលរួមផ្ទាល់ទាំងអ្នកគ្រប់គ្រង ។មធ្យោបាយនេះនឹងជំរុញទឹកចិត្ត ប្រជាជនក្នុងការប្តេជ្ញាចិត្តចំពោះគំរោង ថែមទាំងអោយតំលៃពួកគាត់មានតំលៃវិជ្ជមាន ។

**ខាងក្រោមនេះជាមធ្យោបាយមួយចំនួនក្នុងការអោយតំលៃពួកគាត់៖**

១. ស្វាគមន៍ពួកគេនៅថ្ងៃចាប់ផ្តើម ។

២. ចំនាយពេលអរគុណពួកគាត់ចំពោះអ្វីដែលគេបានធ្វើបើទោះបីតូចក៏ដោយ ។

៣. សុំយោបល់របស់ពួកគាត់ ។

៤. បង្ហាញចំណាប់អារម្មណ៏របស់ពួកគាត់ ។

៥. អបអរសាទរពួកគេនៅពេលការងារបានសំរេច ។

៦. ផ្តល់ឱកាសអោយពួកគាត់បានទទួលវគ្គបណ្តុះបណ្តាល ។

៧. លើកទឹកចិត្តអោយពួកគាត់ចែកចាយបទពិសោធន៏គ្នានៅក្នុងក្រុមជំនុំឬនៅក្នុងសហគមន៏

៨. ផ្តល់អោយពួកគាត់នូវសំភារះរដ្ឋបាលឬសៀវភៅពតិមានផ្សេងៗ ។




**គោលការណ៏នៃការផ្តល់ពតិមានត្រឡប់ជាលក្ខណៈវិជ្ជមាន ៖**

- ផ្តល់ជាញឹកញាប់
- គួរតែមានការផ្លាស់ប្តូរ
- ត្រូវតែមានការស្មោះត្រង់
- គួរតែសមស្របទៅនឹងសមិទ្ធិផល
- គួរតែត្រឹមត្រូវ
- ត្រូវតែទាន់ពេលវេលា
- គួរតែសមស្របទៅនឹងបុគ្គលបើអាចបាន

**កិច្ចការដែលគួរតែធ្វើ**

ចូរធ្វើបញ្ជីអំពីមធ្យោបាយដែលអ្នកកំពុងតែអនុវត្តបច្ចុប្បន្ននេះក្នុងការអោយតំលៃមនុស្សនិងគិតអំពីអ្វីដែលអ្នកគួរ ធ្វើដើម្បីធ្វើអោយវាកាន់តែប្រសើរឡើង ។

### ៦. របៀបរក្សាការជំរុញទឹកចិត្តខ្លួនយើង



ការសំខាន់នៃជីវិតរបស់គម្រោងគឺ ការបន្តជំរុញទឹកចិត្តអ្នកចូលរួមអោយមានចិត្តចង់ធ្វើនិងរក្សាវាបន្តទៀត។ ខាងក្រោមនេះគឺជាមធ្យោបាយក្នុងការធ្វើវាៈ

១. សិក្សាខគម្ពីរដែលមាននៅក្នុងសៀវភៅនេះឬនៅក្នុងព្រះគម្ពីរដែលអ្នកគិតថាមានប្រយោជន៍។

២. អបអរសាទរនូវចំនុចជោគជ័យនៃគំរោង។

៣. បើអាចធ្វើទៅបាន ចូរផ្សព្វផ្សាយភាពជោគជ័យនៅក្នុងកាសែត ឬ វិទ្យុ។

៤. គំរោងខ្លះគួរតែតាំងពិពណ៌ ដូចជាផលិតផលដែលផលិតដោយសហគមន៍។

៥. ប្រសិនបើមានថវិកា គួរតែផ្តល់អោយក្រុមគំរោងនូវអាវយឺតឬក៏បាល់ដែលមានសញ្ញាគំរោង ជាការលើកទឹកចិត្ត។

៦. ការអនុវត្តន៍សកម្មភាពកង់។

## សកម្មភាពកង់

នៅពេលរៀបចំនិងបង្កើតគំរោង ការសំខាន់គឺការធ្វើការជាមួយគ្នាជាក្រុមនិងបែងចែកការងារ និងទទួលខុសត្រូវ ។វាគឺជាការប្រសើរក្នុងការរក្សាតុល្យភាពរវាងការងារ និងធ្វើអោយប្រាកដថា ក្រុម ឬ គណកម្មាធិការធ្វើការជាមួយគ្នានិងជួយ គ្នាទៅវិញទៅមក ។

មធ្យោបាយមួយក្នុងការធ្វើការនេះគឺយើងប្រើសកម្មភាពកង់ ដែលកង់ក្រោយតំណាងអោយបញ្ជីសកម្មភាពការងារនិងកង់មុខតំណាងអោយសកម្មភាពដើម្បីរក្សាការរួមរួមនិងស្មារតីរបស់ក្រុម ។



### សកម្មភាពជួយការងារ

១. *ការផ្តួចផ្តើម:* ការចាប់ផ្តើមអោយក្រុមអនុវត្តការងារដោយផ្តល់សំណើរថ្មី ប្រធានបទសំរាប់ពិភាក្សា ឬផែនការ ។

២. *ស្វែងរកពត៌មាន:* រកធនធានក្នុងក្រុមនិងកំនត់ពត៌មានដែលចាំបាច់ដែលត្រូវរកនៅកន្លែងផ្សេង ។

៣. *ផ្តល់ពត៌មានឬហេតុការណ៍នានាឬចែករំលែកបទពិសោធន៍ដែលពាក់ព័ន្ធ ។*

៤. *ការសុំមតិយោបល់:* វាជាការសំរេចចិត្តដ៏ល្អក្នុងការធ្វើការសំរេចចិត្តដោយពឹងផ្អែកលើការយល់ដឹងនូវអ្វីដែលសមាជិកទាំងអស់គិតនិងមានអារម្មណ៏អំពីវា ។

៥. *ការសុំមតិយោបល់:*មនុស្សមួយចំនួនដឹងច្រើននិងមួយចំនួនទៀតដឹងតិចដូច្នោះហើយគឺជាការល្អក្នុងការប្រមូលមតិទាំងអស់ ។

៦. *ការពន្យល់:* ផ្តល់ឧទាហរណ៏ជាក់ស្តែងនូវចំនុចនីមួយៗអោយបានច្បាស់ ។

៧. *ការបញ្ជាក់:* សួរសំនួរឬបញ្ជាក់ឡើងវិញនូវចំនុចឬពាក្យផ្សេងៗដើម្បីធ្វើអោយច្បាស់ទាំងអស់គ្នា ។

៨. *ការសង្ខេបឡើងវិញ:* ការបញ្ជាក់ឡើងវិញនូវចំនុចសំខាន់ៗដែលបានធ្វើ ។

### សកម្មភាពក្នុងការជួយថែទាំស្មារតីរបស់ក្រុម

១.
២.

១.*ការលើកទឹកចិត្ត:*បង្កើតមិត្តភាពនិងបង្ហាញការសរសើរនូវគំនិតរបស់អ្នកដទៃ ។

២.*ការផ្តល់ឱកាស:*ចូរផ្តល់អោយមនុស្សស្ងាត់ស្ងៀមបានមានឱកាសក្នុងការផ្តល់គំនិតក្នុងការពិភាក្សា ។

៣.*ការកំនត់ស្តង់ដា:* ឧ. ដូចជា អនុញ្ញាតិអោយក្រុមផ្តោតលើចំនុចមានប្រយោជន៏និងជៀសវាងការពិភាក្សាលើបញ្ហា ។

៤.*ការចេញសញ្ញាលំបាក:* ឧ. ដូចជាខ្ញុំគិតថាយើងមិនអាចសំរេចចិត្តធ្វើកិច្ចការនេះបានទេរហូតទាល់តែយើងបានទទួលពត៌មានគ្រប់គ្រាន់ ។

៥.*ការសំដែងចេញនូវអារម្មណ៏ផ្ទាល់ខ្លួននិងក្រុម:* ឧ. ដូចជាខ្ញុំមានអារម្មណ៏ធុញទ្រាន់ណាស់ព្រោះវាគ្រាន់តែជាចំនុចតូចសោះតែវាត្រូវចំនាយពេលស្ទើរតែកន្លះម៉ោងទៅហើយ

៦.*ការផ្សះផ្សា:* ជួយមនុស្សដែលមានគំនិតផ្សេងគ្នាអោយមានការគោរពមតិគ្នាទៅវិញទៅមក ។

៧.*ការធ្វើការវាយតំលៃ:* ចូរបង្កើតឱកាសសំរាប់អ្នកចូលរួមទាំងអស់ក្នុងក្រុមអោយបានសំដែងអារម្មណ៏និងប្រតិកម្មឆ្លោះទៅរកការងាររបស់ក្រុម ។

៨.*ការបន្ធូរភាពតានតឹង:* ដាក់បញ្ហានៅក្នុងបរិបទទូលាយ ឬបង្កើតអោយមានពេលកំសាន្តសប្បាយ ។

*ឥឡូវនេះ ចូរធ្វើកត់ចុះនូវលំហាត់របស់ក្រុមអ្នកនិងតំរូវការតំហែទាំនានាព្រមទាំងរបៀបដែលអ្នកអាចដោះស្រាយវាបាន ។*

**៧.ការកសាងក្រុម :**

ក្នុងអំឡុងវគ្គជីវិតនៃគំរោង ការសំខាន់គឺការស្វែងរកឱកាសដើម្បីជួយក្រុមអោយការធ្វើការជាមួយគ្នាបានល្អ ។ សកម្មភាពខាងក្រោមជួយអោយក្រុមគិតថាក្រុមរបស់ពួកគេជាអ្វី និងអ្វីខ្លះដែលគេអាចធ្វើដើម្បីកែលំអរអោយពួកគេធ្វើការជាមួយគ្នា ។

**ក.ល្បែងគូរគំនូរ**

*គោលបំនង :*

ដើម្បីគិតពីអ្វីដែលជាប្រភេទក្រុមរបស់យើងនិងអ្វីដែលយើងត្រូវធ្វើអោយបានល្អប្រសើរ ។



**ការណែនាំពីជំហានដែលត្រូវធ្វើ**

១. ចូរពន្យល់ទៅក្រុមថា យើងនឹងគិតអំពីលក្ខណ:ដែលយើងនឹងគិតអំពីលក្ខណ:និងធម្មជាតិរបស់ក្រុមរឺអង្គការឬក្រុមជំនុំរបស់យើង ។



២. អោយក្រុមនីមួយៗគូររូបសត្វដែលតំណាងអោយលក្ខណ:និងប្រភេទរបស់ក្រុម ។



៣. បិទរូបភាពទាំងនោះនៅលើជញ្ជាំងនិងអោយអ្នកចូលរួមម្នាក់តាមក្រុមមួយៗបង្ហាញរូបភាពរបស់គេនិងពន្យល់ថាហេតុអ្វីបានជាគេគូររូបនេះ ។

៤. ប្រើក្រដាស់ធំកត់ត្រានូវគំនិតដូចគ្នានិងខុសគ្នា ។

៥. ចូរពិភាក្សាអំពីមធ្យោបាយនិងរបៀបដែលក្រុមអាចធ្វើការជាមួយគ្នាទៅអនាគត ។

**វិធីសាស្ត្រ**

ធ្វើយ៉ាងណាអោយរូបភាពទាំងនោះធំហើយអាចមើលឃើញទាំងអស់គ្នា ។ ប្រសិនបើអ្នកចូលរួមមិនសប្បាយចិត្តក្នុងការគូររឺមិនទុកចិត្ត មានវិធីសាស្ត្រមួយទៀតគឺផ្តល់រូបភាពសត្វមួយចំនួនដល់ពួកគាត់ដើម្បីជ្រើសរើសនិងពិភាក្សាអំពីរូបសត្វទាំងនោះ ។

**ខ.លំហាត់នៅលើក្រដាស់ធំ**

គូរបន្ទាត់ពុះក្រដាស់ធំជាពីរដែលមួយចំហៀងសរសេរថា អ្វីដែលយើងគួររក្សាទុកនៅក្នុងក្រុមរបស់យើង ហើយមួយទៀតសរសេរថា អ្វីដែលយើងគួរផ្លាស់ប្ដូរនៅក្នុងក្រុមរបស់យើង។

អោយក្រុមនីមួយៗសរសេរលើក្រដាស់តូចល្មមហើយបិទលើផ្នែកណាដែលគេចង់បិទហើយដាក់គំនិតរួមជាក្រុម និងពិភាក្សាវា។

| អ្វីដែលយើងគួររក្សាទុកនៅក្នុងក្រុមរបស់យើង | អ្វីដែលយើងគួរផ្លាស់ប្ដូរនៅក្នុងក្រុមរបស់យើង |
|---|---|
| | |

## ត.ការរំលឹកដំណើរការរបស់ក្រុម

មធ្យោបាយមួយក្នុងការកសាងក្រុមគឺត្រូវលើកទឹកចិត្តអោយពួកគេឆ្លុះបញ្ចាំងអំពីរបៀបដែលពួកគេធ្វើការជាមួយគ្នា។ការនេះជាការល្អមួយដែលត្រូវធ្វើបន្ទាប់ពីព្រឹត្តិការណ៍ឬការងារពិសេសដែលត្រូវធ្វើអោយសំរេចហើយ សួរពួកគេនូវសំនួរខាងក្រោម បន្ទាប់មកពិភាក្សាជាក្រុមពីចំលើយនៃសំនួរទាំងនោះ។

១. តើក្រុមរបស់អ្នកត្រូវធ្វើអ្វី ដើម្បីសំរេចកិច្ចការទាំងនេះ?

២. ហើយអ្វីខ្លះដែលរារាំងអ្នកមិនអោយសំរេចកិច្ចការទាំងនេះ?

៣. តើអ្វីដែលអ្នកត្រូវធ្វើខុសប្លែកពីនេះ?

៤. តើអ្នកបានរៀនអ្វីខ្លះ ដើម្បីធ្វើអោយក្រុមមានប្រសិទ្ធភាព?

## ៨.ការរៀបចំការប្រជុំអោយមានប្រសិទ្ធិភាព ៖

ជួនកាលការប្រជុំអាចបង្កអោយមានការធុញទ្រាន់ដោយសារប្រើពេលយូរ ។ផ្នែកនេះនឹងជួយអ្នកអោយគិតអំពីគុណភាពនៃការប្រជុំនិងអ្វីដែលអ្នកអាចធ្វើដើម្បីអោយការប្រជុំមានប្រសិទ្ធភាពរួមទាំងរបៀបធ្វើការសំរេចចិត្តនិងរបៀបអង្កេតភាពស្វាហាប់របស់ក្រុម ។



ខាងក្រោមនេះគឺការពិនិត្យមើលនិងសំនួមពរដែលរៀបចំដើម្បីជួយអ្នកក្នុងការប្រជុំ ។

***ក.ចូរគូរការប្រជុំរបស់អ្នកជាទំរង់នៃមធ្យោបាយធ្វើដំណើរ***

គិតអំពីការប្រជុំរបស់អ្នកក្នុងទំរង់នៃមធ្យោបាយធ្វើដំណើរ តើវាអាចជាអ្វី?

ចូរគូរវានិងចែកចាយវានៅក្នុងក្រុមផ្សេង ។

តើអ្វីជាគំនូររួម?

តើមានអ្វីដែលចាំបាច់ត្រូវដោះស្រាយ?



## ខ.តារាងត្រួតពិនិត្យសំរាប់រៀបចំការប្រជុំអោយមានប្រសិទ្ធិភាព

### ➡ មុនការប្រជុំ



-តើអ្នកទាំងអស់គ្នាច្បាស់ថាតើហេតុអ្វីបានជាយើងត្រូវការការប្រជុំទេ ?

-តើអ្នកទាំងអស់គ្នាមានកត់ចំណាំថា តើការប្រជុំកើតឡើងនៅពេលណាទេ ?

-តើអ្នកចូលរួមមានរបៀបវារៈជាមុននិងមានឯកសារបន្ថែមទេ ?

-តើមានបទបង្ហាញដែរឬទេ ហើយអ្នកបង្ហាញមានពេលគ្រប់គ្រាន់ដែរឬទេ ?

-តើយើងត្រូវការអាហារសំរន់នៅពេលសំរាកដែរឬទេ ?

-តើទីកន្លែងត្រូវការអ្វីដែលត្រូវបំពាក់មុនពេលអ្នកចូលរួមមកដល់ដែរឬទេ ?

### ➡ ក្នុងអំឡុងពេលប្រជុំ



-តើមានសមាជិកថ្មីឬអ្នកទស្សនៈកិច្ចដែលត្រូវស្វាគមន៏និងណែនាំអោយស្គាល់ដែរឬទេ ?

-តើអ្នកចូលរួមស្តាប់គ្នាដែរឬទេ ?

-តើការពិភាក្សាតាមបែបស្ថាបនាដែរឬទេ ?

-តើបានធ្វើការសំរេចចិត្តដែរឬទេ ?

-តើមានអ្នកចូលរួមគ្រប់គ្នាដែរឬទេ ?

-តើប្រធានបានដឹកនាំតាមរបៀបវារៈដែរឬទេ ?

-តើការប្រជុំគោរពតាមពេលវេលាដែរឬទេ ?

-តើប្រធានមានធ្វើការសង្ខេបចំនុចមុនធ្វើការសំរេចចិត្តដែរឬទេ ?

-តើអ្នកកត់ត្រាមានកត់នូវការសំរេចចិត្តដែលបានធ្វើដែរឬទេ ?
 ហើយអ្នកណាទទួលខុសត្រូវលើសកម្មភាពនោះ ?

### ➡ បន្ទាប់ពីប្រជុំ

-តើមានរបាយការណ៏ដែលត្រូវបញ្ជាក់ដោយសមាជិកអង្គប្រជុំដែរឬទេ មុនពេលបញ្ជូនទៅអោយអ្នកចូលរួម ?

-តើមានអ្នករំលឹកទៅសមាជិកទាំងអស់អំពីការប្រជុំលើកក្រោយដែរឬទេ ?

-តើរបាយការណ៏បានបញ្ជូនទៅមុនពេលការប្រជុំលើកក្រោយដែរឬទេ ?

-តើមានពេលសំរាប់រៀបចំរបៀបវារៈប្រជុំលើកក្រោយដែរឬទេ ?



### *គ.ការណែនាំបែបសាមញ្ញមួយក្នុងការធ្វើការសំរេចចិត្ត*

ឧបសគ្គមួយក្នុងការរៀបចំការប្រជុំក្រុមគំរោងតូចមួយគឺការសំរេចចិត្តអោយបានល្អ។ ផ្នែកនៃការធ្វើសំរេចចិត្តល្អគឺការរៀបចំជាមុននិងផ្តល់អោយអ្នកចូលរួមនូវពត៌មានពេញលេញដែលជាមូលដ្ឋាននៃការធ្វើការសំរេចចិត្ត។ខាងក្រោមនេះគឺជាសំនួរសំខាន់ៗក្នុងការជួយអ្នកសំរបសំរួលអោយមានដំណើរការនៃការធ្វើការសំរេចចិត្តអោយបានល្អ។

១. តើអ្វីដែលយើងកំពុងព្យាយាមធ្វើការសំរេចចិត្ត? ត្រូវអោយគ្រប់គ្នាមានការប្រាជកច្បាស់ក្នុងចិត្ត។
២. តើមានលទ្ធភាពផ្សេងឬទេ?ចូរពិចារណាពីជំរើសផ្សេង។ការប្រមូលគំនិតពីអ្នកចូលរួមពិតជាមានប្រយោជន៍។
៣. តើលទ្ធភាពនីមួយៗអាចមានដំណើរការយ៉ាងដូចម្តេច? ចូរពិចារណាអំពីភាពវិជ្ជមាននិងអវិជ្ជមាន?
៤. តើមានសំណូមពរប៉ុន្មានដែលយើងគួរជ្រើសរើស?
៥. តើយើងត្រូវការអ្វីខ្លះដើម្បីអនុវត្តន៏ការធ្វើការសំរេចចិត្តនោះ?
៦. តើអ្នកណានឹងធ្វើ ?ធ្វើអ្វីខ្លះ?ធ្វើពេលណា?ធ្វើនៅកន្លែងណា?និងធ្វើយ៉ាងម៉េច?



***ក្រុមមួយមិនអាចក្លាយជាសហគមន៍មួយបានទេ ប្រសិនបើក្រុមនោះមិនបង្កើតទំលាប់នៃការស្តាប់បែបស៊ីជំរៅនិងគោរពគ្នាទៅវិញទៅមកទេនោះ។***

***( អាយវ៉ែន ប៉ូបរស្តី )***

### ឃ.អ្វីដែលត្រូវអង្កេតក្នុងក្រុម

ការងារមួយដែលសំខាន់សំរាប់អ្នកដែលសម្របសម្រួលឬអ្នកដឹកនាំការប្រជុំគឺត្រូវអង្កេតអំពីដំណើរការប្រជុំក្នុងក្រុម ។ ធ្វើដូច្នេះ ដើម្បីអោយពួកគេធ្វើការពិភាក្សាទៅរកសេចក្ដីបញ្ចប់ប្រកបដោយជោគជ័យ ។

យើងត្រូវអង្កេតក្នុងកំរិត ០៣ កំរិតផ្សេងៗគ្នា :

១. *មាតិការ:* តើក្រុមកំពុងពិភាក្សាអំពីអ្វី ? ហើយម្នាក់ៗកំពុងនិយាយអំពីអ្វី ?

២. *ការសំដែងចេញភាសាកាយវិការ:* ក្រៅពីអ្វីដែលគេនិយាយ តើមានសញ្ញាអ្វីដែលអ្នកចូលរួមបានបញ្ចេញនូវអារម្មណ៏និងប្រតិកម្មរបស់ពួកគេ ។ ឧ. អាកប្បកិរិយា សំលេង ភាសាកាយវិការ ការសំដែងទឹកមុខ ។

៣. *អារម្មណ៏ ឥរិយាបទ កង្វល់និងរបៀបវារៈដែលលាក់កំបាំង :* កត្តាទាំងនេះមានផលប៉ះពាល់សំខាន់ទៅនឹងការងារនិងជីវិតរបស់ក្រុម ។ ដូច្នេះហើយ យើងត្រូវគិតគូរពិចារណា ។ការអង្កេតពាក្យការសំដែងចេញនូវពាក្យសំដីនិងកាយវិការផ្ដល់អោយយើងនូវសញ្ញាអំពីអារម្មណ៏របស់អ្នកចូលរួម ។ ប៉ុន្តែវាក៏អាចមានការបកស្រាយច្រឡំដែរ ។ ហេតុនេះ វាសំខាន់ត្រូវពិភាក្សាជាមួយអ្នកពាក់ពន្ធ័ ។



## ៩.របៀបរក្សាការផ្ដល់ពត៌មានដល់អ្នកដទៃ



ដោយសារគំរោងមានការវិវត្តន៍ វាគឺសំខាន់ក្នុងការចែករំលែកភាពរីកចំរើនជាមួយក្រុមឬបុគ្គលសំខាន់ៗ។ អ្នកទាំងនោះមានដូចជា:

- អ្នកដឹកនាំសហគមនិ និង ក្រុមជំនុំ
- អាជ្ញាធរមូលដ្ឋាន
- ក្រុមជំនុំផ្សេងៗនៅក្នុងតំបន់
- នាយកដ្ឋានជំនាញរបស់រដ្ឋាភិបាលដូចជា រុក្ខាប្រមាញ់ ទឹកស្អាតនិងអនាម័យឬនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
- សមាជិកសហគមនិនិងក្រុមមនុស្សដែលចាប់អារម្មណ៍

ការងារនេះអាចធ្វើទៅតាមមធ្យោបាយដូចខាងក្រោម :

- ប្រើក្រដាស់ធំបង្ហាញជាផ្លូវការនូវចំនុចគន្លឹះសំខាន់ៗ។
- បញ្ចូលនូវរបៀបវារៈទាំងនេះទៅក្នុងកិច្ចប្រជុំរបស់រដ្ឋាភិបាលឬអាជ្ញាធរមូលដ្ឋាន។
- ផ្ដល់ឯកសារទៅក្នុងប្រពន្ធ័ផ្សព្វផ្សាយផ្សេងៗ ដូចជាវិទ្យុឬកាសែតជាដើម។
- ប្រើល្ខោន ឬ ចម្រៀងនៅក្នុងការប្រជុំសហគមនិនៅពេលសមស្របណាមួយ។



## ១០.ការរក្សាទុករបាយការណ៍ផ្សេងៗ




គឺជាការសំខាន់ក្នុងការរក្សារបាយការណ៍ផ្សេងៗរបស់គម្រោងដូចជា :

- ការប៉ាន់ស្មានតំរូវការដំបូងរបស់សហគមន៍ ( វាជាបញ្ជីនៃតំរូវការផ្សេងដែលកំណត់ដោយសហគមន៍ )
- ផែនការរបស់គម្រោង ( នេះជាបញ្ជីនៃសកម្មភាពទាំងឡាយដែលបានមកពីការធ្វើលំហាត់ឡានក្រុងតូច )
- គំរោងថវិការនិងការចំនាយផ្សេងៗ
- បញ្ជីអ្នកទទួលខុសត្រូវនិងតួនាទី ( តួនាទី និង ការទទួលខុសត្រូវផ្សេងៗ )
- របាយការណ៍រីកចំរើនរបស់គំរោង ( នេះជាបញ្ជីពតិមានដែលបានប្រមូលនាពេលចុះត្រួតពិនិត្យគំរោង )
- អ្នកធ្វើផែនការគំរោង ( បញ្ជីនេះជាទូទៅគេដាក់ព្យួរលើជញ្ជាំងដែលបង្ហាញពីពេលដែលគំរោងកើតឡើង )

*របាយការណ៍គំរោងត្រូវការរក្សាទុកដោយអ្នកចេះដឹងខាងរដ្ឋបាលហើយធ្វើការកត់ត្រាចុះនូវចំនុចថ្មីៗរហូត ។*

## ១១.ការទទួលយកដំបូន្មានរបស់អ្នកជំនាញ

គឺជាការសំខាន់ណាស់ក្នុងការស្វែងរកដំបូន្មានរបស់អ្នកជំនាញអំពីវិស័យផ្សេងៗដែលសហគមន៍បានកំនត់ខ្លួនឯងថាគ្មានជំនាញនិងបទពិសោធន៍ ។អ្នកទាំងនោះមានដូចជា ទីភ្នាក់ងាររដ្ឋាភិបាល រឺអង្គការក្រៅរដ្ឋាភិបាល ដែលមានជំនាញដែលអាចផ្ដល់អោយបាន ។

ចូរធ្វើតារាងអំពីភ្នាក់ងាររដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលដែលអាចផ្ដល់ដំបូន្មាននិងអស់អ្នកដែលអាចជួយក្នុងគំរោងបាន ។



## ១២.ការរៀននិងការឆ្លុះបញ្ចាំង

ដោយសារអ្នកប្រើឧបករណ៏និងសកម្មភាពនៅក្នុងដំណាក់កាលទី៤ គឺជាសំខាន់ដែលនៅតែសួរសំនួរខាងក្រោមដើម្បីជួយអ្នកក្នុងការបន្តការរៀននិងការកែលំអរដល់សហគមន៏របស់អ្នក។

ក. តើអ្នកបានរៀនអ្វីខ្លះពីឧបករណ៏និងសកម្មភាពដែលអ្នកបានប្រើ ?

ខ. តើអ្នកធ្វើយ៉ាងដូចម្ដេចដើម្បីប្រើវាអោយប្រសើរជាងនេះ ?

គ. តើអ្នកត្រូវការធ្វើអោយសមស្របជាមួយប្រជាជនដែលអ្នកកំពុងធ្វើការនេះដែរឬទេ ?
ប្រសិនបើធ្វើ តើត្រូវធ្វើយ៉ាងដូចម្ដេច ?

ឆ. តើឧបករណ៏ ឬ សកម្មភាពអ្វីខ្លះដែលអ្នកមិនបានប្រើ? តើមានឧបសគ្គអ្វីខ្លះដែលរារាំងមិនអោយប្រើវាបាន ?
ប្រសិនបើមាន តើត្រូវដោះស្រាយដោយរបៀបណា ?



# ដំណាក់កាលទី៥:
# ការវាយតំលៃ



### ❖ គោលបំណងនៃការវាយតំលៃ :

ការវាយតំលៃគឺជាការសួរនូវសំនួរសំខាន់ ០៣ សំនួរនៅពេលគំរោងមួយបានបញ្ចប់ ឬ ចំនុចសំខាន់មួយនៅក្នុងដំណើរការ អូម៉ូចាបានសំរេច។




- តើយើងបានធ្វើអ្វីដូចដែលយើងបាននិយាយថាធ្វើវាដែរឬទេ ?
- តើយើងបានធ្វើអ្វីផ្សេងដែរឬទេ ?
- តើយើងបានប្រើជំនាញនិងធនធានរបស់យើងអោយមានប្រសិទ្ធភាពដែរឬទេ ?

ការវាយតំលៃមានគោលបំណងសំខាន់ ពីរ គឺ :

- ការទទួលខុសត្រូវចំពោះសមាជិកសហគមន៏ដែលទទួលប្រយោជន៏និងអ្នកផ្គត់ផ្គង់គំរោងដែលផ្តល់ថវិការនិងធនធានផ្សេងៗ។
- រៀនពីរបៀបដែលយើងអាចធ្វើអោយប្រសើរឡើងនូវអ្វីដែលយើងកំពុងធ្វើ ។

**១.ការទទួលខុសត្រូវ**

គឺជាការសំខាន់ដែលសមាជិកសហគមន៏ទាំងឡាយតាំងចិត្តជួយនិងចូលរួមទទួលខុសត្រូវក្នុងការគ្រប់គ្រងគំរោង។

- ពួកគេអាចមានសំលេងពីរបៀបដែលគំរោងកំពុងដំណើរការ
- ពួកគេអាចមានមតិយោបល់ ថាតើគំរោងកំពុងដំណើរការនៅក្នុងផ្លូវផ្សេងឬយ៉ាងណា។
- ពួកគេនឹងត្រូវបានលើកកំពស់ដោយពួកគេមិនគ្រាន់តែជាអ្នកទទួលប៉ុណ្ណោះទេ ប៉ុន្តែជាអ្នកជំនួយផងដែរ។

  គឺជាការសំខាន់ផងដែរ ដែលគំរោងមានការទទួលខុសត្រូវពីអ្នកផ្គត់ផ្គង់តាមរយ:ថវិការ ធនធាន ជំនាញពេលវេលា ។ ដើម្បី :

- បង្ហាញពីថវិការថា បាប្រើត្រឹមត្រូវហើយ។
- ផ្តល់ភស្តុតាងនៃការផ្លាស់ប្តូរនិងឥទ្ធិពលជាវិជ្ជមាន។
- ផ្តល់កិត្តិយសរវាងអ្នកផ្គត់ផ្គង់និងម្ចាស់គំរោង។

## ២.ការរៀនសូត្រ

អ្នកចូលរួមក្នុងគំរោង



អ្នកផ្ដត់ផ្គង់គំរោង

គឺជាការសំខាន់ក្នុងការរៀនចេញពីបទពិសោធន៍របស់យើងនិងប្រមូលមេរៀនពីរបៀបដែលយើងអាចធ្វើអោយប្រសើរឡើងនូវមធ្យោបាយដែលយើងធ្វើការនៅពេលអនាគត ។

## សំនួរនិងឧបករណ៏សំរាប់ធ្វើការវាយតំលៃ

សំនួរសំខាន់គន្លឹះបីសំរាប់ធ្វើការវាយតំលៃ

នៅពេលយើងធ្វើការវាយតំលៃគំរោងមួយយើងគួរតែសួរសំនួរបីដែលយើងប្រើដើម្បីត្រួតពិនិត្យគំរោង ។



**១.តើយើងបានធ្វើអ្វីដែលយើងបាននិយាយថាធ្វើដែររឺទេ?**

ដើម្បីឆ្លើយសំនួរនេះ ក្រុមសម្របសម្រួលមូលដ្ឋាន ចាំបាច់ត្រូវពិនិត្យមើលផែនការដំបូងរបស់គំរោង។ បន្ថែមពីនេះ ពួកគេគួរតែពិនិត្យមើលទៅលើពត៌មានដែលបានប្រមូលមកពីជុំវិញបញ្ហាដើម្បីស្វែងរកដំណោះស្រាយ ។គឺជាការសំខាន់ ដែលក្រុមនេះចំនាយពេលផ្ទុរផ្ទងរវាងផែនការនិងពត៌មានដែលបានប្រមូល ដើម្បីប្រៀបធៀបពីការផ្លាស់ប្តូរដែលកើតមានឡើងតាំងពីបញ្ហាដែលបានកំនត់ដោយសហមន៍។



*ឧបករណ៍សំខាន់មួយ ដើម្បីឆ្លើយសំនួរនេះគឺតារាងពេលវេលា ។*

ចូរយកក្រដាស់ធំមួយសន្លឹក ហើយសុំអោយក្រុមគូរបន្ទាត់ត្រង់ចំពាក់កណ្តាល ។សរសេរកាលបរិច្ឆេទនៃការចាប់ផ្តើមគំរោងនៅខាងដើមបន្ទាត់ព្រមទាំងកាលបរិច្ឆេទបច្ចុប្បន្ននៅបន្ទាត់បន្ទាប់រហូតដល់ចុងបន្ទាត់ ។ហើយអោយក្រុមគូរបន្ទាត់ភ្ជាប់ពីការបរិច្ឆេទមួយនៃជ្រុងម្ខាងទៅកាលបរិច្ឆេទម្ខាងទៀតពីខ្ពស់មកទាបតាមតារាងពេលវេលា ហើយពិភាក្សានូវសំនួរនេះ **តើយើងបានធ្វើអ្វីដូចអ្វីដែលយើងបាននិយាយថាធ្វើដែររឺទេ? ។** អ្នកគួររុករកការប្រែប្រួលដែលសំខាន់ដែលគំរោងបានដំណើរការនិងសួរថាហេតុអ្វីបានជាវាដូច្នេះ ។គឺជាការសំខាន់ក្នុងការរក្សាទុករបាយការណ៏តារាងពេលវេលានេះដើម្បីបង្ហាញទៅអ្នកទទួលផលនិងគណៈកម្មាធិការសហគមន៍ផ្សេងៗដើម្បីបង្ហាញការទទួលខុសត្រូវ ។



## ២.តើយើងបានធ្វើអ្វីខុសគ្នាដែរឬទេ?

ដើម្បីឆ្លើយនឹងសំនួរនេះ ក្រុមសម្របសម្រួលមូលដ្ឋានចាំបាច់ត្រូវគិតអំពីឧបករណ៏ដែល នឹងប្រមូលភស្តុតាងដែលបង្ហាញថា ភាពខុសគ្នាត្រូវបានធ្វើ ។

### *ក.រឿងផ្លាស់ប្តូរសំខាន់*

មធ្យោបាយនេះជំរុញអោយមនុស្សគ្រប់រូបចូលរួមចំនែកចែកចាយបទពិសោធន៏នៃគំរោងក្នុងសហគមន៏របស់ពួកគេព្រមទាំងការផ្លាស់ប្តូរដែលគេគិតថាអាចកើតឡើងបាន ។ម្នាក់ៗដែលនៅក្នុងក្រុមត្រូវបានលើកទឹកចិត្តអោយនិយាយអំពីរបៀបដែលគេជួបប្រទះក្នុងគំរោងនិងភាពខុសគ្នាអ្វីខ្លះដែលបានកើតឡើងនៅក្នុងជីវិតរបស់ពួកគេ ។ ដំណើរការក្នុងការធ្វើរឿងនេះទាមទាអោយមនុស្សគ្រប់គ្នាដែលមានរឿងចែកចាយដោយផ្តល់ពេលគ្រប់គ្រាន់ ។



បន្ទាប់ពីពួកគេម្នាក់ៗបានចែកចាយរឿងហើយ ចូរសូមអោយពួកគេដាក់ចំនងជើងរឿងនិងប្រាប់អំពីហេតុអ្វីបានជាសំខាន់ ។ ចូរសរសេរលើក្រដាស់ធំដើម្បីអានហើយបិទវានៅលើជញ្ជាំងដើម្បីអោយមនុស្សគ្រប់គ្នាឃើញ ។




បន្ទាប់ពីរឿងទាំងអស់ត្រូវបានប្រាប់និងដាក់ចំនងជើងរួច សូមអោយជ្រើសរើសរឿងបីឬប្រាំដែលគេគិតថាមានការផ្លាស់ប្តូរខ្លាំងបំផុតដែលបានកើតឡើងនៅក្នុងសហគមន៏ ។ រឿងទាំងនោះគួរតែកត់ត្រាសំរាប់ប្រើជាភស្តុតាងក្នុងការសរសេររបាយការណ៏ ។

### ខ.ការគូរផែនទីសហគមន៍

នៅចុងបញ្ចប់នៃគំរោង ចូរសុំអោយក្រុមសម្របសម្រួលមូលដ្ឋាន  គូរផែនទីសហគមន៍ហើយប្រៀបធៀបទៅនឹងផែនទីដែលគេបានគូរមុនគំរោងចាប់ផ្តើម ។តើមានការផ្លាស់ប្តូរជាលទ្ធផលនៃគំរោងនៅក្នុងផែនទីដែរឬទេ?




### គ.ប្រើស្ថិតិក្នុងមូលដ្ឋាន

ផ្នែកសំខាន់នៃការវាយតំលៃគឺការប្រមូលស្ថិតិនៅក្នុងមូលដ្ឋានអំពីអ្វីដែលបានផ្លាស់ប្តូរ ។ ទាំងនេះអាចប្រមូលបានពីរបាយការណ៍របស់ការិយាល័យរដ្ឋាភិបាល ឬ មណ្ឌលសុខាភាពមូលដ្ឋាន។ ក្រុមសម្របសម្រួលមូលដ្ឋាន គួរតែប្រៀបធៀបស្ថិតិពីពេលមុនចាប់ផ្តើមគំរោងនិងស្ថិតិនៅពេលគំរោងបានបញ្ចប់ដើម្បីប្រៀបធៀប ។ អ្វីដែលសំខាន់គឺមើលទៅលើភាពប្រសើរឡើងនៃសុខភាពប្រជាជន កំនើនផលិតផលកសិកម្មនិងកំនើននៃការចូលរៀនក្នុងសាលារៀនមូលដ្ឋាន ។

ក្រុមសម្របសម្រួលមូលដ្ឋានក៏គួរតែមើលស្ថិតិទាំងនេះនិងធ្វើការសង្ខេបអំពីការផ្លាស់ប្តូរស្ថិតិនៅក្នុងសហគមន៍ហើយធ្វើការកត់ត្រានៅក្នុងរបាយការណ៍ ។



**៣.តើយើងបានប្រើជំនាញនិងធនធានអោយមានប្រសិទ្ធភាពដែរឬទេ?**

***ក.ត្រីកោណនៃធនធាន***

នេះគឺសកម្មភាពល្អមួយ ក្នុងការសំឡឹងមើលអំពីធនធានដែលត្រូវប្រើក្នុងការបង្កើតគំរោងសហគមន៍។

**តើយើងបានប្រើជំនួយខាងក្រៅអ្វីខ្លះ?**

**ហើយអ្វីខ្លះដែលយើងមានស្រាប់?**

**ឧ.**:ដំបូន្មានពីអាជ្ញាធរមូលដ្ឋាន ឬអង្គការមូលដ្ឋាន លើវិស័យ ទឹក អនាម័យនិងកសិកម្ម។

**តើក្រុមសហគមន៍ណាខ្លះដែលយើងបានធ្វើជាមួយ?**

**ហើយធនធានអ្វីខ្លះដែលពួកគេចែកចាយជាមួយយើង?**

**ឧ. :**និកាយនិងក្រុមសាសនាផ្សេងដែលចែកចាយបទពិសោធន៏និង ធនធានរបស់ពួកគេដូចជាអាគារនិងសំភារៈ។

**តើអ្វីដែលយើងធ្វើដោយខ្លួនយើងនិងធនធានអ្វីខ្លះ?**

**ឧ. :**ដីកអណ្តូង ដីចំការ អាគារ កំលាំពលកម្មនិងសំភារៈ

ចូរគូរត្រីកោណលើក្តាខៀនឺក្រដាស់ធំហើយសរសេរសំនួរទៅតាមផ្នែកដែលបានគូរបង្ហាញខាងលើបន្ទាប់មកអោយក្រុមប្រមូលគំនិតឆ្លើយទៅសំនួរនីមួយៗ ។ចំលើយទាំងនេះអាចសរសេរនៅក្នុងក្តាខៀន រឺក្រដាស់ធំ រឺក្រដាស់តូចហើយបិទវានៅលើត្រីកោណ បន្ទាប់មកធ្វើសេចក្តីសង្ខេបហើយអោយក្រុមគិតអំពីអ្វីដែលគេគួរធ្វើទៀតនៅពេលក្រោយ។



## ខ.ការវិភាគប្រអប់




សកម្មភាពនេះគឺល្អសំរាប់ការគិតពីគំរោងសហគមន៍ទាំងមូលដែលបានបញ្ចប់និងអាចត្រូវប្រើដើម្បីសួរសំនួរថាតើធនធានបានប្រើមានប្រសិទ្ធិភាពដែរឬទេ។

### *សេចក្តីណែនាំក្នុងការធ្វើការវិភាគប្រអប់*

១. បំបែកក្រុមទៅជាក្រុមតូចៗ។វាជាការល្អប្រសិនបើយើងបំបែកក្រុមទៅតាមតួរនាទីដែលគេធ្វើក្នុងគំរោង។
២. អោយក្រុមនីមួយៗគូររូប មធ្យោបាយធ្វើដំណើរ ដែលដំណាងអោយរបៀបដែលគំរោងបានបញ្ចប់។
៣. អោយក្រុមនីមួយៗនូវក្រដាស់ពណ៌សំរាប់សរសេរចំនុចខ្លាំង ចំនុចខ្សោយ ឳកាស និង ឧបសគ្គ។ហើយអោយពួកគេប្រមូលគំនិតនិងមតិទៅលើគំរោងសរសេរនៅលើក្រដាស់ទាំងនេះ។
៤. អោយក្រុមនីមួយៗបង្ហាញរូបភាពមធ្យោបាយធ្វើដំណើរនិង ការវិភាគប្រអប់ទៅក្រុមទាំងមូល។
៥. អោយក្រុមទាំងមូលប្រមូលគំនិតរួមហើយសរសេរនៅលើក្រដាស់ធំ។
៦. ពិភាក្សាសកម្មភាពរយៈខ្លីចាំបាច់ក្នុងការអនុវត្តក្នុងការកែលំអរគំរោង នៅ៦ខែក្រោយ។
៧. ពិភាក្សាសកម្មភាពរយៈខ្លីចាំបាច់ក្នុងការអនុវត្តក្នុងការកែលំអរគំរោង នៅ៨-១២ខែក្រោយ។

*អបអរសារទរបន្ទាប់ពីលំហាត់នេះបានបញ្ចប់ ។*

### ➡ គួរមេរៀនដែលបានរៀនពីអូម៉ូចា :

មុននឹងបង្ហាញទៅសហគមន៏នូវអ្វីដែលបានរកឃើញទាំងអស់គឺសំខាន់ ដែលក្រុមសម្របសម្រួលមូលដ្ឋានរំលឹកមេរៀនដែលបានរៀនពីដំណាក់កាលផ្សេងៗនៃកម្មវិធី ។ការងារនេះអាចធ្វើដោយមើលទៅអ្វីដែលគេបានសរសេរសំរាប់ការរៀននិងការឆ្លុះបញ្ចាំងនៅក្នុងដំណាក់កាលនីមួយៗឬការពិភាក្សាទូទៅក្នុងការប្រើតារាងពេលវេលាដែលងាយស្រួលជាងការធ្វើនៅក្នុងឧបករណ៏បង្ហាញ ។

***“គោលបំនងនៃការរៀនពិតប្រាកដគឺអោយគាត់នៅក្នុងបរិយាកាសមួយសួរសំនួរបន្ត ។”***

*ព្រឹទ្ធាចារ្យ ក្រេកតុន(១៨៤៣-១៩០១)*

### ចំលើយត្រលប់ពីសហគមន៏

នៅពេលក្រុមសម្របសម្រួលមូលដ្ឋានបានប្រមូលពតិមានទាំងអស់ហើយ គួរតែចែករំលែកវាជាមួយសហគមន៏ដើម្បីត្រួតពិនិត្យថាវាត្រឹមត្រូវដែរឬទេ ។នេះគឺជាការងារសំខាន់ដែលត្រូវធ្វើដើម្បីអោយពួកគេមានភាពម្ចាស់ការពតិមាននិងជួយអោយពួកគេចែកចាយពីសមិទ្ធផលរបស់គំរោងពួកគេ ។



### ➡ រចនាសម្ព័ន្ធរបាយការណ៍

នៅពេលពត៌មានទាំងអស់ត្រូវបានប្រមូលពីសំនួរគន្លឹះសំខាន់ទាំងបីរួចនិងពិនិត្យឡើងវិញដោយសហគមន៍ ហើយ អ្នកអាចដាក់បញ្ចូលវាជារបាយការណ៍មួយ ។ខាងក្រោមនេះជារចនាសម្ព័ន្ធដែលអាចប្រើក្នុងការសរសេររបាយការណ៍ ។របាយការណ៍នេះគួរតែរក្សាទុកដូចជារបាយការណ៍សហគមន៍ ហើយបញ្ជូនទៅអោយអាជ្ញាធរមូលដ្ឋានជាការផ្តល់ពត៌មាន ។

**របាយការណ៍វាយតំលៃ**

*ចំនុចគន្លឹះនៃរបាយការណ៍*

- ឈ្មោះគំរោងសហគមន៍
- គោលបំនងនៃគំរោងសហគមន៍
- ការបរិច្ឆេទនៃការចាប់ផ្តើមគំរោង
- កាលបរិច្ឆេទនៃការបញ្ចប់គមរោង
- ថវិការសរុបដែលរួមទាំងធនធានពីសហគមន៍
- លទ្ធផលដែលរកឃើញ

១. តើយើងបានធ្វើអ្វីដែលយើងបាននិយាយថាយើងត្រូវធ្វើដែររឺទេ ?

២. តើយើងបានធ្វើអ្វីអោយមានភាពខុសគ្នាដែររឺទេ?

- ○ ស្ថិតិ
- ○ រឿងដែលផ្លាស់ប្តូរ
- ○ មុននិងបន្ទាប់នៃផែនទី

៣. តើយើងបានប្រើជំនាញនិងធនធានរបស់យើងអោយមានប្រសិទ្ធភាពដែររឺទេ?

- ○ ការពិនិត្យថវិការនិង ការចំនាយ
- ○ ចំលើយតបពីការសម្របសម្រួលក្នុងមូលដ្ឋាន

៤. មេរៀនដែលបានរៀន

- ○ ចូរគូរពីរមេរៀនដែលបានរៀនពីដំណាក់កាលទីមួយដល់ទីបួន
- សេចក្តីសន្និដ្ឋាន
- អនុសាសន៍

## ➡ តើអ្វីដែលយើងត្រូវធ្វើបន្ទាប់?

បន្ទាប់ពីបានបញ្ចប់ការវាយតំលៃ គឺជាការសំខាន់ក្នុងការអបអរសាទរសមិទ្ធផលដែលបានសំរេចនិងគិតអំពីមេរៀនដែលបានរៀនដែល អាចយកមកប្រើប្រាស់នៅពេលចាប់ផ្តើមអនុវត្តគំរោងថ្មី។




ចំនុចខាងក្រោមនេះចាំបាច់ត្រូវពិចារណានៅពេលចាប់ផ្តើមវដ្តគំរោងថ្មី :

១. តើយើងមានតារាងអំពីអ្វីដែលបានរៀនពីការធ្វើការជាមួយគ្នានៅក្នុងគំរោងពីមុនដែរឬទេ ?
២. តើយើងចាំបាច់ត្រូវមើលបញ្ហាសំខាន់ដែលមាននៅក្នុងបញ្ជីដែលសហគមន៍បានធ្វើក្នុងដំណាក់កាលនៃការធ្វើវិភាគដែរឬទេ ?
៣. តើយើងនៅតែប្រើពត៌មានដំបូងដែលយើងបានប្រមូលនៅពេលចាប់ផ្តើមគំរោងទីមួយរឺក៏យើងចាំបាច់ត្រូវធ្វើម្តងទៀត ?
៤. តើយើងនៅតែប្រើក្រុមគំរោងដូចគ្នារឺក៏យើងចាំបាច់ត្រូវបង្កើតក្រុមគំរោងថ្មី ?
៥. តើយើងត្រូវការការផ្គត់ផ្គង់រឺការបណ្តុះបណ្តាលបន្ថែមសំរាប់គំរោងក្រោយដែរឬទេ ?

នៅពេលគេពិភាក្សានូវសំនួរទាំងឡាយ ចូរគិតអំពីកម្មវិធីអបអរសាទរចំពោះការសំរេចសមិទ្ធិផលរបស់ពួកគេដូចជាកម្មវិធីជប់លៀងសហគមន៍ជាដើម។



➡ **ការគិតតចុងក្រោយ**

***អេសាយ៦១:១-៣***

*ព្រះវិញ្ញាណនៃព្រះអម្ចាស់យេហូវ៉ា ទ្រង់សណ្ឋិតលើខ្ញុំ ពីព្រោះព្រះយេហូវ៉ាទ្រង់បានចាក់ប្រេងតាំងខ្ញុំអោយផ្សាយដំណឹងល្អដល់មនុស្សទាល់ក្រ ទ្រង់បានចាត់ខ្ញុំអោយមក ដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង និងប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយ ហើយពីការដោះលែងដល់ពួកអ្នកដែលជាប់ចំណង ប្រមទាំងប្រកាសប្រាប់ពីឆ្នាំដែលព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យ និងពីថ្ងៃ ដែលព្រះនៃយើងខ្ញុំនឹងសងសឹកផង ហើយអោយកំសាន្តចិត្តនៃអស់អ្នកណាដែលសោយសោក និងចែកអោយដល់ពួកអ្នកដែលសោយសោកនៅក្រុងស៊ីយ៉ូន បានភួងលំអជំនួសផេះ ហើយប្រេងនៃសេចក្តីអំណរជំនួសសេចក្តីសោកសៅ ព្រមទាំងអាវពាក់នៃសេចក្តីសរសើរ ជំនួសទុក្ខធ្ងន់ដែលគ្របសង្កត់ដើម្បីអោយគេបានហៅថា ជាដើមឈើនៃសេចក្តីសុចរិត គឺជាដើមឈើដែលព្រះយេហូវ៉ាបានដាំ មានប្រយោជន៍អោយទ្រង់បានថ្កើងឡើង ។*

**សេចក្តីអធិស្ឋាន**

ឱ ព្រះគ្រីស្ទជាពន្លឺនៃយើងខ្ញុំអើយ! សេចក្តីស្រឡាញ់របស់ទ្រង់បានឆេះពេញក្នុងចិត្តទូលបង្គំ អោយបានធ្វើអោយយើងខ្ញុំស្រេកឃ្លានសេចក្តីយុត្តិធម៌ ។

ឱ ព្រះយេស៊ូចាពន្លឺនៃពិភពលោកអើយ! ទ្រង់បានបង្រៀនទូលបង្គំយើងខ្ញុំពីរបៀបគិតពីអ្នកដទៃ បើកត្រចៀកយើងខ្ញុំអោយស្តាប់រឿងអ្នកដែលចង់អោយគេស្តាប់ ។

ទ្រង់ជាពន្លឺនិងជាអ្នកដែលផ្តល់ភាពកក់ក្តៅដល់អ្នកដែលត្រូវគេបោះបង់ចោលនិងអ្នកដែលនៅក្នុងភាពងងឹត ប្រមទាំងផ្តល់សេចក្តីសង្ឃឹមដល់យើង ។

ឱ ព្រះអង្គម្ចាស់យេស៊ូវអើយ! ទ្រង់ជាពន្លឺជីវិត សូមទ្រង់រុំព័ទ្ធទូលបង្គំដោយសេចក្តីស្រឡាញ់របស់ទ្រង់និងបន្ទន់ចិត្តរឹងទទឹងទូលបង្គំអោយព្រះវិញ្ញាណដ៏ជាឱសថរបស់ទ្រង់ ដឹកនាំទូលបង្គំវិញ ។ អាម៉ែន !

# សេចក្ដីបន្ថែម

## ក.ការតាក់តែងច្បាប់អង្គការដែលមានមូលដ្ឋានក្នុងសហគមន៍

## ខ.អភិបាលកិច្ចល្អ

### ❖ ក.ការតាក់តែងច្បាប់អង្គការដែលមានមូលដ្ឋានក្នុងសហគមន៍ :

ការងារដំបូងដែលអង្គការចាំបាច់ត្រូវធ្វើគឺការតាក់តែងច្បាប់ ។នេះគឺជាឯកសារផ្លូវការនិងស្របច្បាប់ដែលបញ្ជាក់ថាអង្គការរបស់អ្នកអាចដំណើរការបាន ។

ចូរសំរេចចិត្តថា ប្រភេទអង្គការអ្វីដែលអ្នកនឹងតាក់តែច្បាប់ ។ចូរពិភាក្សាពីគោលបំនងនិងទិសដៅដែលអង្គការរបស់អ្នក និងប្រភេទរចនាសមន្ទ័ដែលគួរតែមាននិងតួរនាទីអង្គការដែលអ្នកចង់ឃើញ ។ដើម្បីពិភាក្សាលើចំនុចទាំងនេះ គួរតែប្រើតាមសេចក្តីណែនាំខាងក្រោម:

**១.ឈ្មោះ:** ចូរសរសេរឈ្មោះពេញនិងអក្សរកាត់នៃអង្គការនិងប្រភេទនៃអង្គការ ។

**២.អត្តសញ្ញាណស្របច្បាប់:** ចូរបញ្ចូលប្រយោគអំពីអត្តសញ្ញាស្របច្បាប់ ។

**៣.បេសកកម្ម គោលដៅ និង គោលបំនង:** កំនត់ បេសកកម្ម គោលបំនង និង គោលដៅរបស់អង្គការ ។

**៤.សមាជិកភាព**

ចូរពិភាក្សា និង សរសេរ :

- តើអ្នកណាគួរចូលរួម និង ចូលរួមយ៉ាងដូចម្តេច?ឧ. ការបំពេញទំរង់សមាជិកភាព ។
- ភារកិច្ចនិងអភ័យឯកសិទ្ធិរបស់សមាជិក ។
- ចំនួនតំលៃសមាជិកភាពដែលត្រូវបង់ប្រសិនបើមាន ។
- តើមានអ្វីកើតឡើងប្រសិនបើសមាជិកមិនបង់តំលៃសមាជិកភាព?តើសម្រួលអោយគេជាសមាជិកភាពរឺទេ?

**៥.រចនាសមន្ទ័និងការធ្វើការសំរេចចិត្ត**

ចូរពិភាក្សា និង សរសេរ :

- តើរចនាសមន្ទ័អ្វីដែលគួរកើតមានឡើង?ដូចជាការប្រជុំប្រចាំឆ្នាំ ការប្រជុំទូទៅ  ក្រុមប្រឹក្សាប្រតិបត្តិ អនុគណកម្មាធិការ ។ល ។
- រយៈពេលកំនត់មួយចាំបាច់ដើម្បីរៀបចំការប្រជុំ ។
- ចំនួនសមាជិកដែលចាំបាច់អោយការប្រជុំកើតមានឡើង ។
- ការទទួលខុសត្រូវរបស់តំណែងនីមួយៗ
- អំណាចនិងភារកិច្ចរបស់តំណែងនីមួយៗ

**៦.និតិវិធីនៃការប្រជុំ**

ចូរពិភាក្សា និង សរសេរ :

- តើអ្នកណាដឹកនាំការប្រជុំ ?
- តើមានរបៀបវារៈអ្វីខ្លះដែលគួរនឹងធ្វើតាម ?
- របៀបរៀបចំការបោះឆ្នោត ។
- របៀបកត់ត្រា អាន និងធ្វើការសំរេចយល់ព្រមអោយបានលឿន ។

**៧.ការបោះឆ្នោតជ្រើសរើស**

ចូរពិភាក្សា និង សរសេរ :

- កំរិតវប្បធម៌នៃនាយកអង្គការដែលត្រូវជ្រើសរើស ។
- របៀបជ្រើសរើសនាយក ។ ឧ. ដោយការតែងតាំង ឬ ដោយការបោះឆ្នោតយកសំលេងភាគច្រើន ។
- និតិវិធីនៃការបោះឆ្នោតត្រូវធ្វើយ៉ាងណា ។
- របៀបនៃការប្រកាសជ្រើសរើស ។

**៨.បុគ្គលិក**

ទីកន្លែងដែលអង្គការជួលបុគ្គលិក ត្រូវតែនិយាយពី :

- របៀបតែងតាំង ។
- មុខតំណែងនិងភារកិច្ចរបស់បុគ្គលិក ។
- អ្នកដែលពួកគេត្រូវទទួលខុសត្រូវជាមួយ ។

**៩.វិន័យ**

ចូរពិភាក្សា និង កត់ត្រា

- តើអាកប្បកិរិយាអ្វីខ្លះដែលយើងត្រូវការពីបុគ្គលិក ។
- តើអាកប្បកិរិយាបែបណាដែលមិនអាចទទួលយកបាន ។
- តើការសើបអង្កេតនិងការដាក់វិន័យធ្វើឡើងដោយរបៀបណា ។
- តើការបណ្ដេញចេញបុគ្គលិកដោយរបៀបណា ។

**១០.ការត្រួតពិនិត្យហិរញ្ញវត្ថុ**

ការពិភាក្សានិងការកត់ត្រា

- តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការកត់ត្រាហិរញ្ញវត្ថុហើយត្រូវទទួលខុសត្រូវជាមួយអ្នកណា ។
- តើអ្នកណាខ្លះអាចចុះហត្ថលេខាលើវិក្កយបត្រ័បាន ។
- តើការដកប្រាក់ពីធនាគារមានប៉ុន្មានដងហើយធ្វើដោយអ្នកណា ។
- តើអ្នកណាគួរយល់ព្រមក្នុងការដកប្រាក់ពីធនាគារ ប្រសិនបើចំនួនលើសការកំនត់ ។
- តើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំធ្វើឡើងនៅពេលណា ។
- តើរបាយការណ៍សវនកម្មគយរតែផ្ញើរនៅពេលណា ទៅអោយអ្នកណាខ្លះ?ឧ. មួយឆ្នាំម្ដងរៀងរាល់ការប្រជុំប្រចាំឆ្នាំ ។

**ការរួបរួមគ្នា**

ចូរកត់ត្រាចុះ

អ្នកដែលអង្គការត្រូវការរួបរួមជាមួយ ។

ការងារនិងភារកិច្ចអ្វីដែលត្រូវអនុវត្តន៏ ។

❖ **ខ.អភិបាលកិច្ចល្អ :**

**១.អភិបាលកិច្ចរបស់អង្គការសហគមន៏មូលដ្ឋានមួយ**

អង្គការសហគមន៏ទាំងអស់ចាំបាច់ត្រូវមានក្រុមប្រឹក្សាគ្រប់គ្រងមួយដែលទទួលខុសត្រូវស្របច្បាប់ចំពោះអង្គការ ។ការអភិបាលកិច្ចគឺជាមធ្យោបាយមួយដែលអង្គការមួយបែងចែកការទទួលខុសត្រូវ សិទ្ធិ និងអំណាចផ្លូវការ ។ ក្រុមប្រឹក្សាគ្រប់គ្រងរឺគណកម្មធិការគឺទទួលខុសត្រូវចំពោះអភិបាលនិងដឹកនាំអង្គការដើម្បីថានាថាការងាររបស់អង្គការអនុត្តន៏ទៅតាមការតាក់តែងច្បាប់របស់អង្គការ ។

អង្គការផ្សេងមានភាពមិនដូចគ្នាទេដូច្នោះហើយវាអាស្រយ័ទៅលើការបែងចែកតួនាទីរបស់ក្រុមប្រឹក្សាភិបាល ។ ទំហំការងារដែលក្រុមប្រឹក្សាភិបាលចូលរួមដំណើរការការងារប្រចាំថ្ងៃគឺមានភាពខុសគ្នានៅក្នុងអង្គការផ្សេង ។ ក្រុមប្រឹក្សាភិបាលគឺទទួលខុសត្រូវក្នុងការធ្វើអោយច្បាស់ថាសកម្មភាពអង្គការអនុវត្តន៏ទៅមានភាពត្រឹមត្រូវ ។

ម្យ៉ាងវិញទៀតពួកគេបានផ្ទេរភារកិច្ចនេះទៅអោយបុគ្គលិកដែលទទួលប្រាក់បៀវត្សនិងអ្នកស្ម័គចិត្ត ។ ឧទាហរណ៏ ក្រុមប្រឹក្សាភិបាលអាចស្នើសុំអោយគនេយ្យករធ្វើរបាយការណ៏គនេយ្យប៉ុន្តែត្រូវប្រាកដថារបាយការណ៏ត្រូវបង្ហាញនៅក្នុងការប្រជុំនីមួយៗ ។គឺបុគ្គលិកដែលទទួលប្រាក់បៀវត្សដែលផ្តល់សេវានិងចាត់ចែងការងាររដ្ឋបាលប្រចាំថ្ងៃនៃសកម្មភាពរបស់អង្គការហើយក្រុមប្រឹក្សាភិបាលមានភារកិច្ចគ្រប់គ្រងពីលើការងារនេះ ។

**២.តួនាទីរបស់ក្រុមប្រឹក្សាភិបាល**

➡ **ការធ្វើផែនការនិងគោលនយោបាយអង្គការ**

ផ្តល់ទិសដៅ ការដឹកនាំ ការណែនាំ គោលនយោបាយសំរាប់អង្គការដើម្បីថានាថា អង្គការនៅតែផ្តោតការយកចិត្តទុកដាក់ទៅលើវា ។

**ភាពស្របច្បាប់**



ដើម្បីធានាថា បទបញ្ជានិងច្បាប់មូលដ្ឋាន ខេត្តត្រូវបានគោរព ។
ឧ. កិច្ចសន្យាឬកិច្ចព្រមព្រៀងជាមួយអ្នកផ្តល់ជំនួយការចុះបញ្ជី ជាមួយរដ្ឋាភិបាល ពន្ធដាជាដើម ។

**ហិរញ្ញវត្ថុ**



ដើម្បីធានាថា អង្គការអាចបំពេញការប្តេជ្ញាចិត្តចំពោះការប្រើ ថវិកាអោយបានត្រឹមត្រូវនិងទទួលខុសត្រូវចំពោះម្ចាស់មូលនិធិ ។
ឧ. ប្រព័ន្ធគណនេយ្យ គណនេយ្យធនាគារ សវនកម្ម និងរបាយការណ៍ទៅម្ចាស់ជំនួយ ។

**បុគ្គលិក**



ដើម្បីធានាថា ទាំងបុគ្គលិកនិងអ្នកស្ម័គ្រចិត្តត្រូវបានផ្តល់ការងារ ដោយសុវត្ថិភាព ការគោរព ការអោយតំលៃ និងការផ្គត់ផ្គង់ការងាររបស់ពួកគេ ។

**ឧបករណ៏ប្រើប្រាស់**



ដើម្បីធានាថា កន្លែងធ្វើការរបស់បុគ្គលិកនិងអ្នកស្ម័គ្រចិត្តគឺមាន ឧបករណ៏ប្រើប្រាស់គ្រប់គ្រាន់ មានសុវត្ថិភាព ។



**ការផ្សព្វផ្សាយនិងទីផ្សារ**

ដើម្បីថានាថាអង្គការមានកេរ្តិ៍ឈ្មោះល្អទាំងសាធារណៈនិងសហគមន៍ ។

**ការធ្វើរបាយការណ៏និងការទទួលខុសត្រូវ**



ដើម្បីធានាថា អង្គការទទួលខុសត្រូវចំពោះ អ្នកស្ម័គ្រចិត្ត សមាជិក បុគ្គលិក ម្ចាស់មូលនិធិ អ្នកពាក់ពន្ធ័ទាំងឡាយ ដោយបំពេញតំរូវការក្នុងការធ្វើរបាយការណ៏បានទាន់ពេលវេលានិងត្រឹមត្រូវ ។ក្រុមប្រឹក្សាភិបាលគឺជារូបកាយក្នុងការទទួលខុសត្រូវក្នុងកាធ្វើ របាយការណ៏សកម្មភាពប្រចាំឆ្នាំរបស់អង្គការហើយបញ្ជូនទៅក្នុងការប្រជុំប្រចាំឆ្នាំ ។

**គ.តើអ្នកណាគួរពិចារណាជ្រើសរើសជាក្រុមប្រឹក្សាភិបាលរបស់របស់អ្នក ?**

- មនុស្សដែលចង់ចូលរួមនិងមានការប្តេជ្ញាចិត្តនិងចំនាប់អារម្មណ៍
- មនុស្សពីក្រុមអ្នកទទួលផល
- អ្នកដឹកនាំសាសនា ឬ ពលរដ្ឋនៅសហគមន៍មូលដ្ឋាន
- អ្នកពាណិជ្ជកម្មមូលដ្ឋាន
- មនុស្សពីអង្គការសហគមន៍ស្រដៀងគ្នាពីកន្លែងផ្សេង
- មនុស្សពីក្លឹប កីឡា រឺសង្គមមូលដ្ឋាន
- មនុស្សដែលមានជំនាញប្រាកដ ដូចជា ហិរញ្ញវត្ថុ ច្បាប់ រឺ ស្វែងរកមូលនិធិ
- មនុស្សដែលមានចំនេះដឹងនិងជំនាញជាក់ស្តែងនៅក្នុងតំបន់ដូចជា អ្នកធ្វើការផ្នែកសុខភាព ជាដើម
- អង្គការខ្លះអញ្ជើញសមាជិកពីអង្គការមូលនិធិរបស់ពួកគេ ប៉ុន្តែវាមានគុណសម្បត្តិនិងគុណវិបត្តិ។ តំនាងមូលនិធិអាចសមស្របដោយសារគាត់អាចយល់អំពីបញ្ហារបស់អ្នកបានច្បាស់។
- ទោះជាយ៉ាងណាក៏ដោយវាអាចមានជំលោះផលប្រយោជន៍និងអាចមានអទ្ធិពលទៅលើភាពឯករាជ្យនិងភាពស្វ័យតរបស់អង្គការអ្នក ។ចូរប្រុងប្រយ័តមុនធ្វើការនេះ។





**រៀបចំប្រែសំរួលដោយៈ បណ្តាញមីកាកម្ពុជា**

បណ្តាញមីកាកម្ពុជាគឺជាអង្គការគ្រីស្ទបរិស័ទ ដែលបម្រើក្នុងសកម្មភាពជួយសង្គ្រោះ ការអភិវឌ្ឍន៍និងរកយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។

Réseau Michée
Rede Miquéias
Red Miqueas
Micah Network

mosaic creative

Recycled
Supporting responsible use of forest resources
FSC